ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- វឌ្ឍនភាពវិទក្កុរបស់បណ្ណាល័យសម្តេចម៉ែ សម្រាប់ឆ្នាំ២០២១
- ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមនៅខេត្តកំពង់ចាម
- រឿងពិតរបស់ខ្ញុំ ជីវិតក្រោយថ្ងៃ ១៧ មេសា ឆ្នាំ១៩៧៥

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៥៣ ខែមករា ឆ្នាំ២០២១

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៥៣ ខែមករា ឆ្នាំ២០២១

## មាតិកា

**សំបុត្រ**

◆ វឌ្ឍនភាពវិវត្តរបស់បណ្ណាល័យសម្ដេចម៉ែ .....១

**ផ្នែកឯកសារ**

◆ ស្រេវ ផ្ទិស យុទ្ធនារីមន្ទីរក-១៦ ............... ៤

**ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ**

◆ ឆឹម ឆុនះ រៀនជំនាញនាវ៉ានៅប្រទេសចិន....៧

◆ ទស្សនកិច្ចសិក្សារបស់យុវជននៅ ..........១៦

◆ កងដឹកជញ្ជូនខ្មែរក្រហម .................... ២០

◆ ម៉ែន ម៉ូរ៉ះ ខ្ញុំបានចាប់ផ្ដើមកសាងជីវភាព...២៣

◆ ពេទ្យនារីខ្មែរក្រហម........................ ២៦

◆ វ៉ាន់ រឿន អតីតពេទ្យស្រុកពាមព្រួស ...... ៣០

**ផ្នែកច្បាប់**

◆ សាលក្រមសំណុំរឿង០០២/០២ ............ ៣៥

**ផ្នែកវេទិកាសាធារណៈ**

◆ ការចងចាំអំពីអំពើប្រល័យពូជសាសន៍ .....៤៨

**ផ្នែកស្រាវជ្រាវរកគ្រួសារ**

«ដេះដង់ធូលី» រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបប កម្ពុជាប្រជាធិបតេយ្យ

◆ ឡៅ ស៊ុនថារ៉េត ៖ សិស្ស..................៥២

◆ អែម ផល ៖ លេខាធិការ ..................៥៤

◆ សា សុន ៖ អ្នកបច្ចេកទេសកុន ............ ៥៤

◆ រឿងពិតរបស់ខ្ញុំ ជីវិតក្រោយថ្ងៃ ១៧........ ៥៦



សិល្បៈការិនីកំពុងហាត់សមសម្ដែងសិល្បៈនៅបណ្ណាល័យ «សម្ដេចម៉ែ»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ៣៧៥ព.មប្រក

ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្មេរលេខនេះ៖** ឆាំង យុ, ដាវ៉ារដ្ឋ មេត្តា, រី លក្ខិណា, វេនី ខកហ្គៀល, ប៉ាង ពីរ័ន្ត, ឡុង ដានី, សួត វិចិត្រ, គាត ស្រីឡែន, សុខ វណ្ណៈ, សូវិចិត្រ មេត្តា, ជាតិ ប៊ុណ្ណារី **អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដាវ៉ារដ្ឋ មេត្តា, **អ្នកបកប្រែ៖** ហួយ លីយាង **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន **ជំនួយការនិពន្ធនាយក៖** អ៊ុន សុដាវី **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# វឌ្ឍនភាពវិវត្តរបស់បណ្ណាល័យ សម្តេចម៉ែ សម្រាប់ឆ្នាំ២០២១

**ឆាំង យុ**



*ព្រះឆាយាលក្ខណ៍សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ដើម្បីជាកិច្ចចូលរួមលើកស្ទួយតម្លៃសិល្បៈ និងវប្បធម៌ជាតិខ្មែរដ៏ថ្កើងថ្កាន លោក ឆាំង យុ បានរៀបចំសម្តែងសិល្បៈគ្រប់ទម្រង់ទាំងរបាំក្បាច់បុរាណខ្មែរ (បុរបាំព្រះរាជទ្រព្យ) របាំសហសម័យ គំនូរ និងតន្ត្រីរៀងរាល់៣ខែម្តងនៅក្នុងបណ្ណាល័យសម្តេចម៉ែ ដើម្បីឲ្យបណ្ណាល័យសម្តេចម៉ែកាន់តែមានសកម្មភាពរស់រវើក និងក្លាយជាទីចាប់អារម្មណ៍ ក៏ដូចជា ការធ្វើការផ្សព្វផ្សាយជូនភ្ញៀវជាតិ និងអន្តរជាតិ នូវព្រះកិត្តិនាម និងភាពសម្បូរបែបនៃបណ្ណាល័យសម្តេចម៉ែ។

នៅខែមករា ឆ្នាំ២០២១ ក្រុមសិល្បៈមួយក្រុមដឹកនាំដោយ កញ្ញា សុខ ណាលីស បានមកទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែ និងពិនិត្យមើលទីកន្លែងសម្រាប់ហ្វឹកហាត់សម្តែងសិល្បៈរបាំក្បាច់បុរាណដែលនឹងចាប់ផ្តើមនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២១។ ក្រុមសិល្បៈនឹងសម្តែងសិល្បៈរបាំក្បាច់បុរាណដើម្បីអបអរខួបលើកទី១១០ នៃទិវាសិទ្ធិនារីអន្តរជាតិ ថ្ងៃទី៨ ខែមីនា ឆ្នាំ២០២១ នៅបណ្ណាល័យសម្តេចម៉ែ។ ភ្ញៀវជាតិដែលជាលោកជំទាវទូត ឯកអគ្គរាជទូត និងរដ្ឋទូតប្រចាំនៅ



*ព្រះឆាយាលក្ខណ៍សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*



*សិល្បៈករកំពុងកូតវីយ៉ូឡុងនៅបណ្ណាល័យ «សម្តេចម៉ែ» ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ព្រះរាជាណាចក្រកម្ពុជា នឹងត្រូវបានអញ្ជើញ និងយាងមកចូលរួមព្រឹត្តិការណ៍ និងទស្សនាកម្មវិធីសម្តែងសិល្បៈនៅបណ្ណាល័យ សម្តេចម៉ែ។

បណ្ណាល័យ សម្តេចម៉ែ បានដើរតួនាទីយ៉ាងសំខាន់សម្រាប់ដាក់តាំងពិព័រណ៍ព្រះឆាយាលក្ខណ៍ និងស្នាមព្រះហស្តរបស់ព្រះបរមរតនកោដ្ឋ ព្រះបាទនរោត្តម សីហនុ, កិច្ចការស្រាវជ្រាវ, កិច្ចការផ្សព្វផ្សាយ និងកិច្ចការបោះពុម្ពផ្សាយ រួមជាអាទិ៍មានសៀវភៅ ស្តីអំពីទំនាក់ទំនងសម្តេចព្រះនរោត្តម សីហនុ និងនាយរដ្ឋមន្ត្រី ជូ អេនឡាយ នៃប្រទេសចិន។

បណ្ណាល័យសម្តេចម៉ែ បានបង្កើតឡើងជាផ្លូវការដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីថ្វាយព្រះរាជកិត្តិយសជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ជូនសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ដែលបានខិតខំប្រឹងប្រែងដើម្បី សម្តេច ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ អតីតព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ ប្រទេសជាតិកម្ពុជា និងប្រជាជនកម្ពុជា។

សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល បានសព្វព្រះរាជហឫទ័យយាងសម្ពោធបណ្ណាល័យសម្តេចម៉ែ នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃច័ន្ទ ៤កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹងថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០២០ កន្លងមកនេះ។

បណ្ណាល័យសម្តេចម៉ែ មានតម្កល់ទុកសមុច្ច័យជាសៀវភៅប្រមាណជាង ៣០០០ក្បាល និងឯកសារចំនួន





សិល្បៈករកំពុងកូតវីយ៉ូឡុងនៅបណ្ណាល័យ «សម្តេចម៉ែ» ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



បណ្ណាល័យ «សម្តេចម៉ែ» ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

២៨០០ប្រអប់ ស្តីពីរាជវង្សានុវង្ស និងប្រវត្តិសាស្ត្រប្រទេសកម្ពុជា។ ឯកសារដែលតម្កល់នៅក្នុងបណ្ណាល័យសម្តេចម៉ែ ក៏រួមមានសៀវភៅជាច្រើនទៀតស្តីអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងឯកសារស្តីពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) យ៉ាងហោចណាស់១លាន៧សែន ដែលស្រាវជ្រាវដោយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាអស់រយៈពេលប្រមាណជាង២០ឆ្នាំកន្លងមក។

បណ្ណាល័យ សម្តេចម៉ែ ថែមទាំងមានតម្កល់នូវឯកសារក្នុងទម្រង់ដទៃទៀតដូចជា រូបថត ភាពយន្ត និងខ្សែអាត់សំឡេងជាច្រើនមុននាទីរបស់ជនរងគ្រោះក្នុងសម័យ ប៉ុល ពត ដែលត្រូវបានធ្វើឲ្យទៅជាទម្រង់ឌីជីថលមានគុណភាពខ្ពស់ ដើម្បីធានាដល់ការអភិរក្សលើឯកសារឲ្យបានគង់វង្ស និងផ្តល់ភាពងាយស្រួលដល់សាធារណជនក្នុងការប្រើប្រាស់។

ទោះបីប្រទេសកម្ពុជាកំពុងប្រឈមនឹងវិបត្តិនៃការរីករាលដាលជំងឺរាតត្បាត កូវីដ១៩ នៅពេលបច្ចុប្បន្នក៏ដោយ ក៏សកម្មភាពអប់រំ របស់បណ្ណាល័យសម្តេចម៉ែដល់ប្រជាជនកម្ពុជា និងអ្នកស្រាវជ្រាវជំនាន់ក្រោយតាមរយៈសិល្បៈ តន្ត្រី ខ្សែភាពយន្ត និងប្រវត្តិសាស្ត្រនៅតែមានសកម្មភាព និងបន្តទៅមុខ។

# ស្រេវ ផ្លិស

## យុទ្ធនារីមន្ទីរក-១៦ របស់តំបន់១០៥ ភូមិភាគឦសាន

*ដារ៉ាវឌ្ឍ មេត្តា*



*យុទ្ធនារីខ្មែរក្រហមនៅសមរភូមិមុខ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ស្រេវ ផ្លិស ហៅ សាវី ភេទស្រី គឺជាជនជាតិព្នង។ ខ្ញុំមានអាយុ២១ឆ្នាំនៅក្នុងឆ្នាំ១៩៧៧។ ខ្ញុំមានទីកន្លែងកំណើត នៅភូមិ ឡាំតឹក ឃុំ ឡាំតឹក ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី។ ឪពុករបស់ខ្ញុំឈ្មោះ ស្រេវ និងម្តាយឈ្មោះ យ៉េន។ ឪពុកម្តាយខ្ញុំប្រកបរបរធ្វើស្រែចម្ការ ហើយខ្ញុំតែងជួយធ្វើកិច្ចការរបស់គាត់។ នៅក្នុងឆ្នាំ១៩៧២ អង្គការបានចូលមកក្នុងភូមិរបស់ខ្ញុំហើយបានរៀបចំក្រុមប្រវាស់ដៃ ដែលជួយគ្នាទៅវិញទៅមក។ ខ្ញុំបានចូលរួមក្រុមប្រវាស់ដៃនៅក្នុងភូមិដែលមានអ្នកក្តោបរួមឈ្មោះ វន និង មានឈ្មោះ កឹ គឺជាប្រធានក្រុម។

នៅចុងខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានចូលធ្វើបដិវត្តន៍តាមរយៈឈ្មោះ សាវន គឺជាគណៈស្រុកពេជ្រាដា។ ខ្ញុំចូលដំបូងគឺខ្ញុំនៅក្នុងមន្ទីរក-១៦ របស់តំបន់១០៥។ នៅក្នុងមន្ទីរក-១៦ ខ្ញុំស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឈ្មោះ បូផា គឺជាជនជាតិលាវ និងជាប្រពន្ធរបស់ខាំភូន មានតួនាទីជាប្រធានមន្ទីរតំបន់១០៥។ ខ្ញុំបានធ្វើការជាមួយ បូផា បានរយៈពេល១០ថ្ងៃ ក៏ចាប់ផ្តើម

ជិតស្និទ្ធជាមួយគាត់។ បូជា បានបំផុសខ្ញុំឲ្យខ្ជិលធ្វើការងាររួម, មិនមានកម្មសិទ្ធិឯកជន និង បំផុសខ្ញុំឲ្យខូចសីលធម៌ជាមួយយុទ្ធជនចំនួន៥នាក់។ យុទ្ធទាំងនោះមានឈ្មោះ នាង អតីតធ្វើស្រែ, ឡឿន ជនជាតិលាវ យុទ្ធជននៅមន្ទីរក-១៦, កាន់ ជនជាតិស្ទៀង, ភន ជនជាតិព្នង និង ឡាន ជនជាតិទំពួន។

នៅខែមិថុនា ឆ្នាំ១៩៧៥ ឈ្មោះ និច គឺជាអ្នកបដិវត្តន៍ និងជាប្រធានមន្ទីរបានចាត់តាំងខ្ញុំ និងនារីចំនួន ១០នាក់ ឲ្យទៅធ្វើស្រែនៅស្រែឈើគុស។ ខ្ញុំស្ថិតនៅក្រោមការគ្រប់គ្រងរបស់ និច។ ខ្ញុំបានធ្វើស្រែនៅទីនោះរហូតដល់ខែមីនា ឆ្នាំ១៩៧៦។ នៅក្នុងឆ្នាំ១៩៧៦ ខាំភូន និង ប្រពន្ធរបស់គាត់ឈ្មោះ បូជា មកយកខ្ញុំនៅមន្ទីរស្រែឈើគុសឲ្យត្រឡប់មកនៅមន្ទីរក-១៦ វិញ។ ខ្ញុំត្រឡប់មកមន្ទីរក-១៦ បាន៥ថ្ងៃ ខាំភូនបានរៀបឲ្យខ្ញុំមានគ្រួសារ។ ប្តីរបស់ខ្ញុំឈ្មោះខ្វាក គឺជាជនជាតិព្នង (នៅឆ្នាំ១៩៧៧ គាត់បានរត់ទៅប្រទេសវៀតណាម)។ ក្រោយពីខ្ញុំរៀបការបានចំនួន៤ទៅ៥ថ្ងៃ បូជា បានមកអប់រំខ្ញុំម្តងទៀតអំពីធ្វើបដិវត្តន៍ មិនមានមុខមាត់បុណ្យស័ក្តិប្រាក់ខែ និងគ្មានសេរីភាពក្នុងការរស់នៅ។ មិនតែប៉ុណ្ណោះ បូជា បានបំភ័យខ្ញុំរឿងដែលខ្ញុំធ្លាប់ខូចសីលធម៌ ធ្វើឲ្យអង្គការមិនទុកចិត្ត។ ក្រោយមកនៅចុងខែមីនា ឆ្នាំ១៩៧៦ បូជា បានបញ្ចូលខ្ញុំជាសមាជិក សេ.អ៊ី.អា ដោយមានអ្នកទទួលស្គាល់ឈ្មោះ ញ៉ុន គឺជាប្រធានសេដ្ឋកិច្ចតំបន់១០៥។ ភារកិច្ចរបស់ សេ.អ៊ី.អា គឺកសាងកម្លាំង, បំផ្លាញសម្ភាររបស់បដិវត្តន៍, បំផុសយុវជន និង យុវនារីឲ្យខូចសីលធម៌ និងខ្ជិលធ្វើការងាររួម។ ក្រោយពីប្រជុំហើយ បូជា និង ញ៉ុន ប្រាប់ឲ្យខ្ញុំទាក់ទងជាមួយកម្លាំងចំនួន៧នាក់ទៀត មានឈ្មោះ ចាន់ ធី ជនជាតិព្នង ក្រោយមកត្រូវបានអង្គការចាប់ខ្លួន, ចាន់ ធឿន យុទ្ធនារី, អួយ ជនជាតិព្នង គឺជាយុទ្ធនារីមន្ទីរក-១៦, រ ហាញ, ហ៊ាង, រី គឺជាយុទ្ធជនមន្ទីរក-១៦ និង រ៉ុម ជនជាតិលាវ។ បន្ទាប់ពីបានស្គាល់គ្នាហើយ ខ្ញុំ, រ៉ុម និង រី បានរួមគ្នាដាំបាយឆៅចំនួន១០ឆ្នាំង ដើម្បីឲ្យយុវជន និងយុវនារីមិនសប្បាយចិត្តជាមួយបដិវត្តន៍ ដោយខ្លួនខិតខំធ្វើការយ៉ាងខ្លាំងហើយអង្គការនៅតែដាំបាយឆៅឲ្យហូប។ ក្រោយមកទៀត បូជា បានចាត់តាំងខ្ញុំ, ចាន់, ធឿន, ហ៊ាង, រ៉ុម និង ចាន់ ធី ឲ្យលួចអង្ករចំនួនពីរបាវ, អំបិលបីបាវតូច និងក្រមាចំនួន៣០ ទៅលាក់ទុកនៅក្នុងមន្ទីរក-១៦ ព្រៃអូប្រង់ដែលមានចម្ងាយបីគីឡូម៉ែត្រពីមន្ទីរក-១៦។

នៅក្នុងខែមេសា ឆ្នាំ១៩៧៦ បូជា បានចាត់តាំងខ្ញុំ, រី, ហ៊ាង ឲ្យលួចខោអាវចំនួន២០ សម្រាប់ទៅបោះចោលក្នុងទឹកនៅអូច្បារ។ បន្ទាប់មកយើងខ្ញុំទាំងបីនាក់កសាងបានកម្លាំងនារីបានចំនួនបីនាក់មានឈ្មោះ រន ជនជាតិឡាវ, លី ជនជាតិឡាវ និង វ៉ាន់ ជនជាតិទំពួន។ ក្រោយមក ញ៉ុន និង បូជា បានហៅខ្ញុំ និងមនុស្ស៨នាក់ទៀតទៅប្រជុំនៅក្នុងព្រៃអូច្បារ។ នៅក្នុងខ្លឹមសារប្រជុំនោះ គឺកសាងកម្លាំងរបស់ សេ.អ៊ី.អា, ធ្វើរដ្ឋប្រហារនៅខែមិថុនា ឆ្នាំ១៩៧៧, ត្រៀមគ្រាប់ និងស្បៀង, ត្រូវខិតខំបំផ្លាញសម្ភាររបស់បដិវត្តន៍។ ពេលវេលាវាយបដិវត្តន៍មានពីរមុខសញ្ញាគឺមាន ខាំភូន ជាអ្នកទាក់ទងជាមួយយួន តាមស្រុកកែវសីម៉ា និងមុខសញ្ញាទី២ មាន ញ៉ុន និង បូជា ដឹកនាំវាយពីមន្ទីរតំបន់ ១០៥ ។

នៅក្នុងខែឧសភា ឆ្នាំ១៩៧៦ បូជា បានចាត់តាំងខ្ញុំ, ចាន់ និង វុន ឲ្យទៅដុតស្រូវប្រជាជនអស់ចំនួន ២ ជង្រុក នៅអូទឹម។ ក្រោយមកទៀតខ្ញុំបានទាក់ទងជាមួយ ឆាន់ធី, លី ជាខ្មែរចាស់ និងបានសហការទំនាក់ទំនងជាមួយ សេ.អ៊ី.អា ចំនួន៤នាក់ រួមមាន រី ជនជាតិព្នង, រឿន ជនជាតិលាវ, រិប ជនជាតិលាវ និង ចាន់ ធឿង ជនជាតិលាវ។ បូជា បានចាត់តាំង ខ្ញុំ, ចាន់ ធឿន, រី, រឿន និង រន លី ឲ្យទៅលួចអង្ករនៅមន្ទីរក-១៦ ចំនួន៤បាវទៅលាក់នៅក្នុងព្រៃអូប្រង់ ដែលមានចម្ងាយ៣គីឡូម៉ែត្រពីមន្ទីរក-១៦។ នៅខែមិថុនា ឆ្នាំ១៩៧៦ បូជា បានចាត់តាំងខ្ញុំ, រី, ចាន់ធី, រឿន និង លី ឲ្យចូលរួមសកម្មភាពលួចដុតស្រូវទុំអស់ចំនួនពីរហិកតានៅពេលយប់ក្នុងមន្ទីរក-១៦។

នៅខែតុលា បូជា បានចាត់តាំងខ្ញុំ, វៀង, សារឿន, រី, លី, ចាន់ធី ឲ្យទៅច្រូតស្រូវទុំនៅស្រែឈើគុសរបស់តំបន់១០៥។ នៅពេលនោះ ម៉ី បូជា បានចាត់តាំងខ្ញុំ និង ម៉ីចាន់ធី ឲ្យធ្វើជាប្រធាន សេ.អ៊ី.អា ។ យើងបានឲ្យបក្ខពួកប្រឆាំងបដិវត្តន៍នៅកន្លែងនោះច្រូតស្រូវចំនួនប្រាំថ្ងៃ

ចាត់តាំងបក្ខពួកឲ្យដុតស្រូវ ទុំនៅពេលយប់អស់ចំនួនពីរហិកតា។ នៅខែវិច្ឆិកា ខ្ញុំបានទាក់ទង វៀង, ចាន់ធី គឺជាខ្មែរចាស់របស់ គេស៊ី ជនជាតិឡាវ គឺជាយុទ្ធនារីតម្បាញតំបន់១០៥, ភឿន ជនជាតិឡាវយុទ្ធនារីតម្បាញ, សុភី ជនជាតិលាវ គឺជាយុទ្ធនារីតម្បាញ។ ខ្លឹមសារនៅក្នុងការប្រជុំកសាង ខ្ញុំនិងបក្ខពួក បានលើកឡើងពីបញ្ហារស់នៅក្នុងសង្គមបដិវត្តន៍មិនមានសិទ្ធិសេរីភាព ម្យ៉ាងទៀតខ្ញុំធ្វើការងារគ្មានពេលសម្រាក និងគ្មានប្រាក់ខែ។ នៅក្នុងខែធ្នូ ខ្ញុំបានឈឺគ្រុនចាញ់, រាកមូល និងកើតខាន់លឿង ពេលនោះប្តីរបស់ខ្ញុំបាននាំខ្ញុំមកដេកសម្រាកពេទ្យរបស់តំបន់១០៥ ។ អំឡុងដែលខ្ញុំឈឺនេះ គឺអស់រយៈពេល៣ខែ ធ្វើឲ្យខ្ញុំត្រូវដាច់ខ្សែទាក់ទង។

នៅក្នុងកុម្ភៈ ឆ្នាំ១៩៧៧ ខ្ញុំបានធូរស្បើយ។ ខ្ញុំបានវិលត្រឡប់មកនៅក្នុងមន្ទីរក-១៦វិញ។ ពេលនោះខ្ញុំត្រូវមកភ្ជាប់ខ្សែចាស់របស់ខ្ញុំទាំងអស់។ ខ្ញុំនៅបានប្រហែលជា ៧ថ្ងៃ ម៉ី បូផា បានហៅខ្ញុំ, ចាន់ធី, ចាន់ធឿន, រ៉ុម, ហ៊ាង, រហាញ និង សារឿន មកប្រជុំដាក់ផែនការនៅក្នុងព្រៃអូច្បារ។ នៅក្នុងខ្លឹមសារប្រជុំគឺ កសាងកម្លាំង សេ.អ៊ី.អា ឲ្យបានច្រើនថែមទៀត, ឲ្យខ្ញុំខិតខំបំផ្លាញសម្ភាររបស់បក្ខតទៅទៀត, បំផុសយុវជននិងយុវនារី ឲ្យខូចសីលធម៌ ហើយបំផុសឲ្យខ្ជិលធ្វើការងាររួម, ត្រូវបន្តលាក់សម្ភារ និងគ្រាប់រំសេវ។ នៅក្នុងខែមីនា ម៉ី បូផា បានខទ្ទេសនាមប្រាប់ខ្ញុំ, ចាន់ធី ឲ្យនៅទាក់ទងខ្មែរពីរនាក់មានឈ្មោះ វ៉ាន់ ថា ជនជាតិទំពួន យុទ្ធនារី ខាងតម្បាញជនជាតិទំពួន, ឆែម ជនជាតិព្នង យុទ្ធនារីខាងតម្បាញ។ អ្នកទាំងពីរនាក់ធ្វើការជាមួយគ្នា។ ក្រោយមក ម៉ី បូផា បានចាត់តាំងខ្ញុំ, វ៉ាន់ឌី ជនជាតិស្ទៀងយុទ្ធនារីខាងតម្បាញ, វែត ជនជាតិទំពួន គឺជាយុទ្ធនារីខាងតម្បាញ និងឈ្មោះ លី ឲ្យធ្វើសកម្មភាពដាំបាយឲ្យខ្លោច និងឆៅអស់៣០ឆ្នាំង ធ្វើឲ្យយុវជននិងយុវនារីមានកំហឹងជាមួយបដិវត្តន៍ គឺខិតខំធ្វើការ ប៉ុន្តែឲ្យស៊ីដូចជ្រូក។ នៅខែឧសភា ម៉ី បូផា បានខទ្ទេសនាមប្រាប់ខ្ញុំ, ចាប់ធឿន, រន ឲ្យទាក់ទងខ្មែរ សេ.អ៊ី.អា ចំនួនពីរនាក់គឺ ឈ្មោះ រ៉ី ជនជាតិលាវ និង វៀ ជនជាតិស្ទៀង។ ពួកគាត់ទាំងពីរនាក់គឺជាយុវនារីខាងកាត់ដេររបស់តំបន់១០៥។ ក្រោយមកទៀត បូផា បានចាត់តាំង ខ្ញុំ, ចាន់ធី, រ៉ុម, រហាញ, រី ,សារឿនឲ្យលួចយកគ្រាប់កាំភ្លើងអាកាមួយ ឡាំង និងគ្រាប់អាកែង ចំនួនបី ឡាំង, អង្ករចំនួនបីបាវនៅក្នុងមន្ទីរក-១៦។ បន្ទាប់មកយើងបានដឹកសម្ភារទាំងនោះទៅលាក់ទុកនៅក្នុងព្រៃកអូប្រង នៅពេលយប់។ នៅខែមិថុនា ម៉ី បូផា បានប្រាប់ខ្ញុំឲ្យទៅទាក់ទងជាមួយខ្មែរ សេ.អ៊ី.អា ចំនួនពីរនាក់ទៀត។ ខ្ញុំបានបំផុសយុវជនមន្ទីរក-១៦ ឲ្យធ្វើពុតជាឈឺមិនឲ្យទៅធ្វើការងារ។ ក្រោយមក ម៉ី បូផា បានហៅខ្ញុំបក្ខពួកខ្ញុំមានឈ្មោះ វៀង ជនជាតិព្នងគឺជាយុទ្ធនារីមន្ទីរក-១៦, សារឿន, ដោក, សារឿន, ចំរើន, លី, គីម ហន, រន, ចានជី, មកប្រជុំនៅក្នុងព្រៃកអូរច្បា ដើម្បីប្រាប់ផែនការធ្វើរដ្ឋប្រហារ នៅខែមិថុនា ឆ្នាំ១៩៧៧ ។ បន្ទាប់មក ម៉ី បូផា បានប្រាប់ខ្ញុំ និងបក្ខពួកទាំងអស់ឲ្យខិតខំអនុវត្តផែនការកសាងកម្លាំង និងបំផ្លិចបំផ្លាញបំផុសបំផុលឲ្យបានខ្លាំងក្លាបន្តទៀត។ នៅក្នុងខែកក្កដា ម៉ី បូផា បានខទ្ទេសនាមប្រាប់ខ្ញុំនិង ចាន់ធី ឲ្យនៅទាក់ទងខ្មែរ សេ.អ៊ី.អា មានឈ្មោះសារឿន ជនជាតិព្នង និង សារ ម៉េង ជនជាតិទំពួន។ ក្រោយពីទាក់ទងគ្នារួចហើយ ម៉ី បូផា បានចាត់តាំងខ្ញុំ, លី, សាម៉េង ឲ្យទៅលួចដុតស្រូវទុំអស់ ៣ ហិកតានៅជិតមន្ទីរក-១៦ នៅពេលយប់។ ក្រោយមកទៀត ម៉ីបូផា ចាត់តាំងខ្ញុំ, សាម៉េត, សារឿនឲ្យយកថ្នាំអង់ទ្រីនដាក់ក្នុងបាយជ្រូកឲ្យជ្រូកស៊ីពុលងាប់អស់ចំនួន ៩ក្បាល។ នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៧៧ ប្តីរបស់ខ្ញុំបានរត់ទៅវៀតណាមនៅពេលយប់។ ស្អែកឡើងថ្ងៃទី ១ ខែសីហា ឆ្នាំ១៩៧៧ អង្គការបានមកចាប់ខ្ញុំមកដាក់នៅក្នុងសន្តិសុខតំបន់ ១០៥ រហូតដល់ ខែតុលា ឆ្នាំ១៩៧៧ អង្គការបញ្ជូនខ្ញុំមកភ្នំពេញតែម្តង។

*កំណត់ចំណាំ ៖ អត្ថបទនេះ ដកស្រង់ចេញពីចម្លើយសារភាពឯកសារ J០០១៣៣។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះ យើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ស្រេវ ផ្លិស ហៅ សាវី ពិតប៉ុណ្ណាណានោះទេ។*

# ឆឹម ឆុនៈ រៀនជំនាញនាវា នៅប្រទេសចិន

*វី លក្ខិណា*



ឆឹម ឆុន អាយុ៦៩ឆ្នាំ សព្វថ្ងៃរស់នៅសង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

អតីតកងទ័ពខ្មែរក្រហមបានរំឭកពីរឿងរ៉ាវជីវិតដែលបានឆ្លងកាត់សង្គ្រាម និងត្រូវបានរបបកម្ពុជាប្រជាធិបតេយ្យបញ្ជូនទៅរៀនផ្នែកបើកបរនាវានៅប្រទេសចិនថា ខ្ញុំមានឈ្មោះ ឆឹម ឆុន អាយុ៦៩ឆ្នាំ សព្វថ្ងៃរស់នៅសង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ ខ្ញុំមានស្រុកកំណើតនៅឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។ ប្រពន្ធរបស់ខ្ញុំឈ្មោះ ស៊ីវ អឿន អាយុ៥៩ឆ្នាំ និងមានកូនប្រុសម្នាក់។ កាលពីក្មេងៗខ្ញុំបានរៀនរហូតដល់ចប់ឌីប្លូមនៅស្រុកកំណើត ក៏មានរដ្ឋប្រហារពីសំណាក់លោកឧត្តមសេនីយ៍ លន់ នល់ ទម្លាក់សម្តេចព្រះបាទ នរោត្តម សីហនុ។ ខ្ញុំបានឈប់រៀន ហើយចូលធ្វើកងទ័ពជាមួយវៀតកុង ឬវៀតណាមខាងជើង។ នៅចុងឆ្នាំ១៩៧១ ខ្ញុំបានចេញពីកងទ័ពវៀតកុងមកនៅជាមួយខ្មែរក្រហមនៅខេត្តតាកែវ ដែលកាលនោះត្រូវបានហៅថាកងទ័ពតំបន់១៣។

នៅឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះទូទាំងប្រទេស ខ្ញុំបានផ្លាស់ពីកងទ័ពតំបន់ ១៣ ខេត្តតាកែវ មកធ្វើកងទ័ពជើងទឹក ក្នុងកងពល១៦៤ នៅកំពង់សោម ដែលមាន មាស មុត ជាប្រធានកងពល។ កងទ័ពតំបន់ ១៣ ជាទ័ពរបស់ តាម៉ុក ហើយកងទ័ពជើងទឹកកងពល១៦៤មួយចំនួនរើសចេញពីកងទ័ពតំបន់១៣។ ក្រោយមកទើបខ្មែរក្រហមបញ្ជូនកងទ័ពមកពីភូមិភាគបូព៌ា ចូលក្នុងកងពល១៦៤ដែរ។

ពេលទៅដល់កំពង់សោមដំបូង ខ្ញុំឈរជើងនៅរាម និងកោះតាគៀវ។ ខ្ញុំបានស្នាក់នៅកោះតាគៀវមួយរយៈ ក៏ប្តូរទៅឈរជើងនៅកោះរុងហ្វា ទល់មុខទីងក្រុងកំពង់សោម។ ក្រោយមក ខ្ញុំចេញពីកោះរុងហ្វា ទៅនៅកោះតាងវិញ។ នៅពេលនោះមេទាហាន លន់ នល់ ជាច្រើនត្រូវបានខ្មែរក្រហមយកមកឲ្យបង្រៀនកងទ័ពខ្មែរក្រហមពីរបៀបមើលផែនទីសម្គាល់ទីតាំងកោះរបស់ខ្មែរនៅកន្លែងណាខ្លះ និងបង្រៀនពីរបៀបបើកកប៉ាល់ ព្រោះខ្ញុំមិនដែលរៀនពីមុនមក ហើយខ្ញុំក៏មិនដឹងពីប្រវត្តិសាស្ត្រ

ទឹកដីដែរ។ ពេលដែលមើលក្នុងផែនទី ខ្ញុំឃើញកោះក្រូចកសេះជាកោះថ្មប៉ប្រះទឹក និងគ្មានមនុស្សរស់នៅឡើយ។ ខ្ញុំចង់ទៅលេងលើកោះក្រូចកសេះ ប៉ុន្តែមិនមានកប៉ាល់ចេញទៅទីនោះ។

នៅក្នុងខែឧសភា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាប់កប៉ាល់ម៉ាយ៉ាហ្គេសមួយគ្រឿង ប៉ុន្តែខ្ញុំមិនចូលរួមសកម្មភាពនោះទេ ព្រោះខ្ញុំបានឈរជើងនៅកោះតាងតែមួយរយៈខ្លីប៉ុណ្ណោះ។ ប្រធានវរសេនាតូច ៤៨០ របស់ខ្ញុំឈ្មោះរឿន ចំណែកខ្ញុំមានឋានៈត្រឹមតែជាជំនួយការរបស់គាត់ប៉ុណ្ណោះ។ នៅលើកោះតាងមានវរសេនាតូច ៤១០ និងវរសេនាតូច ៤៨០ នៅឈររួមគ្នា។ ក្នុងមួយកងវរសេនាតូចមានកងទ័ពមិនគ្រប់ចំនួនឡើយ គឺមានចន្លោះពីប៉ែតសិបនាក់ ទៅមួយរយនាក់ប៉ុណ្ណោះ។ វរសេនាតូច ៤១០ ឈរជើងនៅចុងខាងលិចកោះតាង ចំណែកវរសេនាតូច៤៨០ ឈរជើងនៅចុងខាងកើត។ នៅពេលដែលទាហានអាមេរិកមកវាយនៅកោះតាង គឺមានតែវរសេនាតូច៤១០ ប៉ុណ្ណោះដែលបានចូលរួមប្រយុទ្ធផ្ទាល់។ ចំណែកកងទ័ពនៃវរសេនាតូច ៤៨០ បានដកចេញពីកោះតាងមុនពេលទាហានអាមេរិកមកដល់។ សណ្ឋានរបស់កោះតាងរាងដូចជាកដប និងសុទ្ធតែជុំថ្មនៅចុងខាងកើត ឯខាងលិចសុទ្ធតែដីខ្សាច់។ បើខាងទ័ពខ្មែរក្រហមចង់ឡើងលើកោះតាង គឺត្រូវចូលចតនៅចុងខាងលិចដែលមានដីខ្សាច់។ ខ្ញុំបានដឹងថា មានឧទ្ធម្ភាគចក្ររបស់អាមេរិកមួយធ្លាក់នៅឆ្ងាយពីឆ្នេរ ប៉ុន្តែត្រូវរលកវាយមកដល់ប្រាំងទើរនៅលើខ្សាច់។

បន្ទាប់ពីមានព្រឹត្តិការណ៍កប៉ាល់ម៉ាយ៉ាហ្គេស កងទ័ពវៀតណាមបានវាយចូលមក និងចាប់កងទ័ពខ្មែរក្រហមនៅលើកោះពូលូវ៉ៃ ព្រោះកងទ័ពខ្មែរក្រហមមិនបានប្រុងប្រយ័ត្នខ្លួនដោយគិតថាមិនមាននរណាហ៊ានចូលមក។ កងទ័ពវៀតណាមជិះកប៉ាល់អាដេអា មួយគ្រឿងមកដល់លើកោះពូលូវ៉ៃ បន្ទាប់មកក៏ចាប់កងទ័ពខ្មែរក្រហមទាំងអស់ទៅដាក់លើកោះត្រល់។ រយៈពេលប្រហែលមួយខែក្រោយមក ទើបបានមេដឹកនាំប្រទេសទាំងពីរធ្វើការចរចាគ្នា។ បន្ទាប់មកកងទ័ពវៀតណាមក៏បានដោះលែងកងទ័ពខ្មែរក្រហម និងដកកងទ័ពចេញពីកោះ



នាវាល្បាតរបស់កងទ័ពជើងទឹកនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (ហ្គុនណា បឺយស្រ្តម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ពូលូវ៉ៃអស់។ នៅខណៈពេលដែលកងទ័ពវៀតណាមដកចេញនៅម៉ោង១១ ខ្ញុំរួមជាមួយវរសេនាតូច ៤៨០ ក៏ទៅកោះពូលូវ៉ៃនៅម៉ោង១១ដែរ។ កោះពូលូវ៉ៃបែងចែកជាពីរ គឺកោះខាងកើត និងកោះខាងលិច។ កោះខាងកើតហៅ កោះថ្មីមានព្រលានយន្តហោះ ក្រាលដែក ដែលអាចឲ្យយន្តហោះធុនអាគេ ៥៤ ចុះចតបាន។ ចំណែកកោះខាងលិច ហៅ កោះចាស់។ នៅពេលដែលមានកប៉ាល់ធំៗបើកមកជិតកោះពូលូវ៉ៃ នាវិកតែងតែវាស់ចម្ងាយផ្លូវដើម្បីឲ្យដឹងគោលដៅ មុននឹងធ្វើដំណើរទៅថៃ ម៉ាឡេស៊ី និងសិង្ហបុរី។ បើមិនបានវាស់ចម្ងាយផ្លូវ និងកំណត់ទីតាំងទេ ក្រុម នាវិកមិនដឹងថាកប៉ាល់របស់ខ្លួននៅកន្លែងណាឡើយ។ កាលពីមិនទាន់បានទៅរៀនជំនាញខាងជើងទឹក ខ្ញុំតែងតែឆ្ងល់ថាហេតុអីបានជាកប៉ាល់ធំៗបានបើកមកជិតកោះរបស់យើង។



ខ្ញុំបានឈរជើងនៅកោះពូលូវៃរហូតដល់ខែមិថុនា ឆ្នាំ១៩៧៦ ទើបខ្ញុំត្រូវបានជ្រើសរើសឲ្យទៅរៀនជំនាញខាងនាវានៅទីក្រុងសៀងហៃ ប្រទេសចិន។ ពេលទៅដល់សាលាដំបូងខ្ញុំត្រូវរៀនភាសាចិនរយៈពេលបីខែ ទើបបន្តរៀនខាងបច្ចេកទេសជួសជុលនាវា។

នៅក្នុងថ្នាក់រៀនមិនមែនមានតែនិស្សិតជាជនជាតិខ្មែរទេ គឺមាននិស្សិតមកពីប្រទេសដែលជាសម្ព័ន្ធមិត្តរបស់ចិនដូចជា ប៉ាគីស្ថាន, កុងហ្គោ និងប្រទេសផ្សេងៗទៀត។ នៅសាលាគ្រូបានបង្រៀនលើមុខជំនាញៗខុសគ្នា ដូចជា ខាងគ្រឿងម៉ាស៊ីន, ខាងបើកបរ, ខាងមើលផែនទី, ខាងប្រើរ៉ាដា, ខាងយុថ្កា និងខាងផ្នែកកាំភ្លើង។ ចិនបានបង្រៀនអំពីនាវាពីរប្រភេទ គឺនាវាមុជទឹក និងនាវាប្រឆាំង ចំណែកខ្ញុំរៀនខាងនាវាមុជទឹក ប៉ុន្តែខ្ញុំក៏ត្រូវដឹងពីការប្រើប្រាស់នាវាប្រឆាំងដែរ។ នៅក្នុងនាវាមួយគ្រឿងមាននិស្សិតមួយរយនាក់ សរុបមាននិស្សិតពីររយនាក់។ ខ្ញុំនៅចាំឈ្មោះគ្រូបង្រៀនរបស់ខ្ញុំពីរនាក់ មួយឈ្មោះអ្នកគ្រូ លីវ និងលោកគ្រូ យូ។ លោកគ្រូ យូ ជាគ្រូបង្រៀនភាសា។ នៅពេលរៀនចប់ នាវិកទាំងអស់បានទៅហាត់ជាក់ស្តែងនៅសមុទ្រលេខ៩ ជិតប្រទេសជប៉ុន។ ពេលនោះមានរលកធំៗ ដូច្នេះទាំងខ្មែរ ទាំងចិន បានពុលរលកបណ្តាលឲ្យរកកប៉ាល់ខ្មាំងមិនឃើញ យើងក៏បណ្តែតកប៉ាល់មុជទឹកមកលើផ្ទៃទឹកដើម្បីរកកប៉ាល់ខ្មាំង។ នៅពេលឃើញហើយ យើងក៏មុជទឹកម្តងទៀត ហើយគ្រូបញ្ជាឲ្យបាញ់ខ្មាំង។ ខ្ញុំនិងនិស្សិតផ្សេងៗទៀត បានពុលរលកក្អួតទាំងអស់គ្នានៅក្នុងកប៉ាល់ ដូច្នេះយើងបាននាំគ្នាមុជទឹកដោយមិនមានគោលដៅដើម្បីឲ្យចប់វិធីលំហាត់សមយុទ្ធយោធា។

ខ្ញុំរៀននៅស្រុកចិនបានជិត៣ឆ្នាំ រហូតដល់ខែតុលា ឆ្នាំ១៩៧៨ ទើបត្រឡប់មកខ្មែរវិញ ដោយខ្ញុំបានជិះយន្តហោះពីសៀងហៃមកប៉េកាំង ប្រទេសចិន។ ខ្ញុំបានដើរលេងរយៈពេលមួយសប្តាហ៍ ទើបជិះយន្តហោះចេញពីប៉េកាំងមកពោធិ៍ចិនតុងវិញ។ ពេលមកដល់ពោធិ៍ចិនតុង ខ្ញុំបានធ្វើដំណើរត្រឡប់ទៅអង្គភាពយោធានៅកំពង់សោមវិញ។ ខ្ញុំធ្វើការនៅឆ្នេរអូរឈើទាល ដោយមានតួនាទីពីរ គឺទីមួយជាប្រធានបច្ចេកទេស និងទីពីរខ្ញុំធ្វើការនៅបញ្ជាការដ្ឋានកងទ័ពជើងទឹក។ នៅពេលនោះ ខ្មែរក្រហមបានរៀបចំសង់កំពង់ផែយោធាមួយទៀតនៅស្ទឹងហាវ ដើម្បីចតនាវា ព្រោះនៅរាមមានទីតាំងចំហរពេក មិនអាចលាក់ការណ៍សម្ងាត់បាន។ ខ្ញុំធ្វើការនៅកំពង់សោមបានប្រហែលរយៈពេល៣ខែ កងទ័ពវៀតណាមក៏បានវាយចូលប្រទេសកម្ពុជានៅឆ្នាំ១៩៧៩។

នៅពេលកងទ័ពវៀតណាមចូលមកដល់កំពង់សោម ខ្ញុំបានរត់តាមឃុំថ្ម ស្រុកបទុមសាគរ ខេត្តកោះកុង និងបន្តដំណើរតាមព្រំដែនរហូតដល់តំបន់ថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ ដោយខ្ញុំចំណាយពេលអស់ប្រហែលបីខែដើរក្នុងព្រៃ។ ពេលទៅដល់តំបន់ថ្មដា ខ្ញុំកាន់វរសេនាតូច១០៧ ស្ថិតក្នុងកងពលទី៣ ដែលមាន ទឹម សេង ជាប្រធាន។ ទឹម សេង ក៏បានទៅរៀននៅប្រទេសចិនជាមួយខ្ញុំដែរ។ កងទ័ពនៅក្នុងវរសេនាតូច១០៧ មានចន្លោះពី

មួយរយហាសិបនាក់ ទៅមួយរយហុកសិបនាក់។ កម្លាំងរបស់ខ្ញុំមិនគ្រប់គ្រាន់សម្រាប់មួយវរសេនាតូចឡើយ។

បន្ទាប់មកខ្ញុំទទួលខាងទំនាក់ទំនងជាមួយខាងថៃ។ នៅពេលខ្មែរក្រហមត្រូវបញ្ជូនអ្នកជំងឺទៅព្យាបាលនៅថៃ គឺខ្ញុំត្រូវទំនាក់ទំនងជាមួយខាងភាគីថៃមុនថា ស្អែកខ្ញុំត្រូវនាំអ្នកជំងឺបួននាក់ ឬប្រាំនាក់យកទៅព្យាបាលនៅប្រទេសថៃ។ ពេលខ្លះ ប្រជាជនខ្មែររៀបចំពិធីការកូនឬបុណ្យ ក៏ខ្ញុំជួយទំនាក់ទំនងទៅខាងប្រទេសថៃដើម្បីទិញសាច់ បន្លែ គ្រឿងសម្រាប់ប្រើប្រាស់ក្នុងពិធីដែរ។ បន្ទាប់មកទៀតខ្ញុំបានឡើងជាប្រធានភស្តុភាប្រចាំកងពលទី៣។ ការងាររបស់ខ្ញុំ គឺទំនុកបម្រុងកងទ័ពនៅសមរភូមិមុខ និងត្រូវដឹកជញ្ជូន ស្បៀង គ្រាប់រំសេវខោអាវ ថ្នាំពេទ្យ និងប្រាក់។

មុខព្រួញរបស់ខ្ញុំ គឺប្រចាំនៅសមរភូមិកោះកុងដែលអ្នកនៅតំបន់ថ្មដាកត់ចំណាំថា សមរភូមិកោះកុងគឺមុខព្រួញចាប់ពីតំបន់ថ្មដាចូលមកក្នុងខេត្តកោះកុង។ ក្រោយឆ្នាំ១៩៧៩ កងទ័ពខ្មែរក្រហមភាគច្រើនមិនមានទីតាំងឈរជើងពិតប្រាកដឡើយ។ យើងបានប្តូរទីតាំងពីមួយកន្លែងទៅមួយកន្លែង ហើយនៅបានជួបជាមួយកងទ័ពខាងវៀតណាម យើងក៏វាយប្រយុទ្ធគ្នា។ ពេលខ្លះត្រូវកងទ័ពខាងវៀតណាមវាយរុញច្រានត្រឡប់



រថពាសដែករបស់កងទ័ពជើងទឹកនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មកជិតតំបន់ថ្មដាវិញ ដោយសារកងកម្លាំងខ្មែរក្រហមខ្វះស្បៀង ខ្វះគ្រាប់កាំភ្លើង ព្រោះកងដឹកជញ្ជូនរបស់ខ្មែរក្រហមស្ថិតនៅឆ្ងាយពីកន្លែងប្រយុទ្ធគ្នា។ កងដឹកជញ្ជូនរបស់ខ្មែរក្រហមត្រូវចំណាយពេលមួយខែ ទើបដឹកស្បៀង និងគ្រាប់កាំភ្លើងទៅដល់សមរភូមិមុខ។

នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ចន្លោះពីតំបន់ថ្មដា មកខេត្តកោះកុងមានភ្នំមួយឈ្មោះថា ភ្នំ១០០ ពីព្រោះនៅរវាងឆ្នាំ១៩៨៥ ដល់ឆ្នាំ១៩៨៦ យោធាខ្មែរក្រហមបានដាក់កាំភ្លើងត្បាល់ធុន១០០មីលីម៉ែត្រនៅលើកំពូលភ្នំនេះ ដើម្បីបាញ់គាំទ្រខ្សែត្រៀមនៅខាងមុខ។ ភ្នំនេះត្រូវបានខ្មែរក្រហមនិងប្រជាជនហៅថា ភ្នំ១០០ រហូតដល់សព្វថ្ងៃ។ នៅលើភ្នំ១០០ មិនមានសំណង់ធំទេ មានតែខ្ទមសម្រាប់បាំងកម្តៅ និងជីកជាលេណដ្ឋានសម្រាប់ការពារគ្រាប់។ ចំណែកកងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានឈរជើងនៅខាងក្រោមជាប់នឹងស្ទឹងមេទឹក។ នៅពេលនោះកងទ័ពខ្មែរក្រហមហៅកងទ័ពរដ្ឋាភិបាលដែលឈរជើងនៅទីនោះថា «វរលិចទឹក» ពីព្រោះនៅខែប្រាំងអាចស្នាក់នៅបានតែបើខែវស្សាមានភ្លៀងធ្លាក់ គឺទឹកហូរមកពីភ្នំខ្លាំង បណ្តាលឲ្យលិចចាន ឆ្នាំង ជួនបណ្តាលឲ្យមនុស្សស្លាប់ទៀត។ ចំណែកភ្នំមើលឡាន ជាភ្នំមួយដែលយោធាខ្មែរក្រហមនិងក្រុមដឹកជញ្ជូនឆ្លងកាត់ និងឈប់សម្រាកនៅពេលនឿយហត់។ យោធាខ្មែរក្រហមទាំងនោះបានអង្គុយមើលឡានបើកលើផ្លូវនៅក្នុងទឹកដីថៃ មើលភ្លើង និងមើលផ្ទះប្រជាជន។ ចំណែកកងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានហៅថា ភ្នំគយគន់ឡាន។

បន្ទាប់ពីកងកម្លាំងខ្មែរក្រហមធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ១៩៩៦ ខ្ញុំ, តាឃន និង តាឡាយ បានដឹកនាំទាហានមួយចំនួនមកឈរជើងជាមួយកងទ័ពរាជរដ្ឋាភិបាលចាប់ពីកោះកុងមកតំបន់ថ្មដា។ ចំណែកមួយផ្នែកទៀតឈរជើងនៅតំបន់ថ្មដាតែម្តង។ នៅតំបន់ថ្មដា បានធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលចំនួនពីរលើក គឺលើកទី១ នៅក្នុងឆ្នាំ១៩៩៦ និងលើទី២នៅក្នុងឆ្នាំ១៩៩៨។ ខ្ញុំបានសម្រេចចិត្តធ្វើកងទ័ព និងរស់នៅខេត្តកោះកុងរហូតដល់សព្វថ្ងៃ។

# ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យ ឯកសារខ្មែរក្រហមនៅខេត្តកំពង់ចាម

*សោម ប៊ុនថន*



*អ្នកស្រី វីណា វេដឌី នាយិកា «ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ» និង លោក ផេង ពង្ស៍រ៉ាស៊ី នាយកកម្មវិធីអប់រំស្តីអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា នៃមជ្ឈមណ្ឌលឯកសារកម្ពុជា នៅ«ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» ខេត្តកំពង់ចាម។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំពិធីសម្ពោធ «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» នៅក្នុងបរិវេណគរុកោសល្យភូមិភាគខេត្តកំពង់ចាម នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ ក្រោមអធិបតីភាពរបស់លោកជំទាវ ទន់ សាអ៊ុម អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា, លោក សេង ស៊ីម នាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ កំពង់ចាម, អ្នកស្រី វីណា វេដឌី នាយិកា «ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ», អ្នកស្រី អមរា បូ តំណាង «កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ» និង លោក ផេង ពង្ស៍រ៉ាស៊ី នាយកកម្មវិធីអប់រំស្តីអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជានៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ កម្មវិធីសម្ពោធនេះមានការចូលរួមពីភ្ញៀវដែលជាគរុសិស្ស លោកគ្រូអ្នកគ្រូនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ខេត្តកំពង់ចាម និងបានអនុវត្តវិធានរបស់



អ្នកស្រី វីណា រេដឌី នាយិកា «ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ» ថ្លែងសុន្ទរកថានៅក្នុងពិធីសម្ពោធ «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» នៅក្នុងបរិវេណគរុកោសល្យភូមិភាគខេត្តកំពង់ចាម នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)



លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា ថ្លែងសុន្ទរកថានៅក្នុងពិធីសម្ពោធ «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» នៅក្នុងបរិវេណគរុកោសល្យភូមិភាគខេត្តកំពង់ចាម នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)



អ្នកស្រី អមរា បូ តំណាង «កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ» ថ្លែងសុន្ទរកថានៅក្នុងពិធីសម្ពោធ «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» នៅក្នុងបរិវេណគរុកោសល្យភូមិភាគខេត្តកំពង់ចាម នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)



លោក សេង ស៊ីម នាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ កំពង់ចាម ថ្លែងសុន្ទរកថានៅក្នុងពិធីសម្ពោធ «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» នៅក្នុងបរិវេណ គរុកោសល្យភូមិភាគខេត្តកំពង់ចាម នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)



គរុសិស្ស លោកគ្រូ អ្នកគ្រូ នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ចូលរួមពិធីសម្ពោធ «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» នៅក្នុងបរិវេណគរុកោសល្យភូមិភាគខេត្តកំពង់ចាម នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រសួងសុខាភិបាល ដោយពាក់ម៉ាស់ លាងដៃជាមួយ អាល់កុល និងរក្សាគម្លាតដើម្បីការពារការឆ្លងរីករាលដាលជំងឺកូវីដ១៩។

មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានការសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំបង្កើត «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» ខេត្តកំពង់ចាម ចាប់តាំងពីចុងឆ្នាំ២០១៩មកម្ល៉េះ តាមរយៈការធ្វើការជាដៃគូលើកិច្ចការរដ្ឋបាល និងបច្ចេកទេសមួយចំនួន ដូចជា ការស្នើសុំបង្កើតការិយាល័យ, ការដាក់ឈ្មោះការិយាល័យ, ការជួបប្រជុំដើម្បីពិភាក្សាពីវត្ថុបំណងជាក់លាក់ក្នុងការបង្កើត និងដំណើរការការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម, ការកំណត់ទីតាំងការិយាល័យ, ការកែលម្អអគារ ព្រមទាំងការរចនាផ្ទៃខាងក្នុងពណ៌បៃតងដែលរួមមាន ការបំពាក់គ្រឿង



ផែនទីស្រាវជ្រាវ និងសិក្សាពីរបបខ្មែរក្រហមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ពីឆ្នាំ២០២០ ដល់ ឆ្នាំ២០២២។ (លី កុកឆាយ/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



បរិក្ខាការិយាល័យ និងការដាក់តាំងពិព័រណ៍រូបថតស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ការិយាល័យនេះ មានបន្ទប់ប្រជុំអនឡាញដែលស្ថិតនៅជាប់គ្នានឹងបន្ទប់ធំ ព្រមទាំងមានឯកសារខ្មែរក្រហមដែលជាប់ទាក់ទងនឹងភូមិភាគឧត្តរចំនួន ៧៤៧៥ ឯកសារ ប្រស្មើនឹងជិត៩ម៉ឺនទំព័រ។ កិច្ចការទាំងអស់ខាងលើនេះត្រូវបានបញ្ចប់នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២០។

«ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» នៅខេត្តកំពង់ចាម គឺជាកន្លែងផ្សព្វផ្សាយ និងទទួលព័ត៌មានស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដែលរួមបញ្ចូលទាំងកិច្ចការបង្រៀនពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងសាលារៀន និងនៅតាមសហគមន៍ និងលើកកម្ពស់កិច្ចការស្រាវជ្រាវ និងចងក្រងពីបទពិសោធន៍





គរុសិស្ស លោកគ្រូ អ្នកគ្រូនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចូលរួមពិធីសម្ពោធ «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» នៅក្នុងបរិវេណគរុកោសល្យភូមិភាគខេត្តកំពង់ចាម នៅថ្ងៃទី ២៩ ខែមករា ឆ្នាំ២០២១។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

របស់អ្នករស់រានមានជីវិតក្រោយរបបខ្មែរក្រហមក្នុងខេត្តកំពង់ចាមដើម្បីទុកជាមេរៀនបន្ថែមសម្រាប់ការបង្រៀនរបស់គ្រូ និងការសិក្សារបស់សិស្ស។

កិច្ចការទាំងអស់នេះ គឺជាការឆ្លើយតបទៅនឹងសំណើររបស់អង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម) ដោយមានការឯកភាពពីប្រមុខរាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា តាមរយៈលិខិតផ្លូវការរបស់អង្គភាពទាំងបីកាលពីឆ្នាំ២០១៣ ក្នុងន័យបម្រើដល់សេចក្ដីត្រូវការរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងជនរងគ្រោះនៃរបបខ្មែរក្រហមទាំងអស់ រួមមាន ជួយផ្សព្វផ្សាយឲ្យបានទូលំទូលាយពីប្រវត្តិសាស្ត្រនេះទៅកាន់ក្មេងៗជំនាន់ក្រោយ និងទទួលយកបទពិសោធន៍ និងទស្សនៈយល់ឃើញផ្ទាល់ខ្លួនចំពោះរបបខ្មែរក្រហមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះ សម្រាប់យុទ្ធសាស្ត្រផ្សះផ្សា និងព្យាបាលរបួសផ្លូវចិត្ត និងដើម្បីធ្វើជាមេរៀនបន្ថែមសម្រាប់យុវវ័យជំនាន់ក្រោយ ក្នុងការចូលរួមទប់ស្កាត់ការវិលត្រឡប់អំពើប្រល័យពូជសាសន៍ជាលើកទី២នៅកម្ពុជា។

ដើម្បីបម្រើដល់គោលបំណងដូចបានរៀបរាប់ខាងលើបន្ទប់ «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» នឹងត្រូវប្រើប្រាស់ជាថ្នាក់រៀនប្រវត្តិសាស្ត្រ ដែលចាប់ផ្ដើមពីប្រវត្តិសាស្ត្រពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។ សិស្សានុសិស្ស គរុសិស្ស និងគ្រូបង្រៀន នឹងត្រូវអញ្ជើញឲ្យចូលរួមនៅក្នុងសកម្មភាពការងារមួយចំនួននៅក្នុងបន្ទប់ថ្នាក់រៀនប្រវត្តិសាស្ត្រនេះ រួមមាន៖

១) កម្មវិធីវេទិកាថ្នាក់រៀនស្ដីអំពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម និងវិធានការទប់ស្កាត់អំពើប្រល័យពូជសាសន៍។

២) កម្មវិធីវេទិកាអប់រំសាធារណជាមួយជនរងគ្រោះនៃរបបខ្មែរក្រហម។

៣) កម្មវិធីវេទិកាប្រវត្តិសាស្ត្រគ្រួសារ ជាមួយគ្រូបង្រៀន និងជនរងគ្រោះនៃរបបខ្មែរក្រហមដើម្បីពិភាក្សាបទពិសោធន៍គ្រួសារឆ្លងកាត់របបខ្មែរក្រហម និងការអប់រំពីប្រវត្តិសាស្ត្រខ្មែរក្រហម



### ៤) កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន ស្តីអំពីការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហម។

ដើម្បីឲ្យការអនុវត្តកិច្ចការគម្រោងប្រកបដោយជោគជ័យ «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» ខេត្តកំពង់ចាម បានស្នើសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ដោយមានកិច្ចសហការពីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ក៏ដូចជាមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម ក្នុងការប្រតិបត្តិគម្រោងដូចបានរៀបរាប់ខាងលើឲ្យមានប្រសិទ្ធភាព និងគុណភាព ដើម្បីធានាឲ្យបានពីការអប់រំឆ្ពោះទៅការរក្សាសន្តិភាពដែលមានស្រាប់ ការលើកតម្កើងសិទ្ធិមនុស្ស និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ សម្រាប់ការចូលរួមក្នុងការអភិវឌ្ឍប្រទេសដោយគ្មានសង្គ្រាម។

ក្រៅពី «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» នៅខេត្តកំពង់ចាម មជ្ឈមណ្ឌលឯកសារកម្ពុជាមាន«ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» ចំនួន៩ទៀត គឺ ១) «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» នៅខេត្តព្រៃវែង ២)«ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» នៅខេត្តតាកែវ ៣) «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» នៅខេត្តត្បូងឃ្មុំ ៤)«ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» នៅខេត្តកំពង់ចាម ៥) «មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង» នៅខេត្តឧត្តរមានជ័យ ៦) «បណ្ណាល័យសម្តេចម៉ែ» នៅទីក្រុងភ្នំពេញ ៧) «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» នៅខេត្តបាត់ដំបងដែលនឹងរៀបចំធ្វើនៅក្នុងឆ្នាំ២០២១នេះ ៨) «បណ្ណាល័យសម្តេចឳសម្តេចម៉ែ» នៅស្រុកគិរីវង់ និង ៩) «ការិយាល័យព័ត៌មានសាធារណៈ នៅទីក្រុងភ្នំពេញ។

ថវិកាដែលចំណាយលើការរៀបចំទាំងអស់បានទទួលការឧបត្ថម្ភពី USAID «ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ», UNDP «កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ» និង EU «សហគមន៍អឺរ៉ុប»។

# ទស្សនកិច្ចសិក្សារបស់យុវជននៅមជ្ឈមណ្ឌលឯកសារកោះថ្មខេត្តត្បូងឃ្មុំ

ឡុង ដានី



ក្រុមយុវជនមកពីវិទ្យាល័យក្រូចឆ្មារ, វិទ្យាល័យសម្តេច ហ៊ុន សែន ប៉ើស២ និងអនុវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ឈូក រួមជាមួយលោកគ្រូ អ្នកគ្រូ មន្ត្រីសាលាស្រុកមេមត់ និងមន្ទីរអប់រំ យុវជន និងកីឡា ខេត្តត្បូងឃ្មុំ ធ្វើទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកោះថ្ម នៅពេលព្រឹកថ្ងៃទី៣១ ខែមករា ឆ្នាំ២០២១។ (ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

យោងតាមសំណើររបស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្តត្បូងឃ្មុំ ដែលសហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជាខេត្ត និងមានការឯកភាពពីរដ្ឋបាលខេត្តត្បូងឃ្មុំលេខ ០០១៧ លសតឃ ២១ ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២១ ស្នើសុំឲ្យយុវជននៅក្នុងខេត្តត្បូងឃ្មុំ បានចុះមកទស្សនកិច្ចសិក្សាក្រោមប្រធានបទ «គុណធម៌ប្រវត្តិសាស្ត្រ» នៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ ចំនួន១៨វគ្គ ក្នុងឆ្នាំសិក្សា២០២១ ដោយក្នុងមួយវគ្គៗមានយុវជនចូលរួមចំនួន ៥០នាក់ៗ សរុបមានយុវជន ៧០០នាក់ គិតចាប់ពីខែមករា រហូតដល់ខែធ្នូ ឆ្នាំ២០២១។

នៅវេលាម៉ោង៨ព្រឹកថ្ងៃទី៣១ ខែមករា ឆ្នាំ២០២១ គឺជាវគ្គទី១ ដែលយុវជនជាសិស្សានុសិស្សមកពីវិទ្យាល័យក្រូចឆ្មារ វិទ្យាល័យសម្តេច ហ៊ុន សែន ប៉ឹស២ និងអនុវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ឈូកចំនួន៤៧នាក់ (ស្រី ៣២នាក់) រួមជា មួយលោកគ្រូ អ្នកគ្រូ ចំនួន ៣នាក់ (ស្រី ២នាក់) និងមន្ត្រីសាលាស្រុកមេមត់ និងមន្ទីរអប់រំ

យុវជន និងកីឡា ខេត្តត្បូងឃ្មុំចំនួន១១នាក់ (ស្រី២នាក់) ធ្វើទស្សនកិច្ចសិក្សារៀនសូត្រនៅមជ្ឈមណ្ឌលឯកសារកោះថ្មៗ

ដើម្បីអនុវត្តវិធានការរបស់ក្រសួងសុខាភិបាល ជាដំបូងយុវជន និងអ្នកចូលរួមទាំងអស់បានពាក់ម៉ាស់លាងដៃជាមួយអាកុល និងរក្សាគម្លាត ដើម្បីការពារការឆ្លងរាលដាលជំងឺកូវីដ១៩ៗ

ជាការចាប់ផ្តើមកម្មវិធីទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកោះថ្មនេះលោក ញឹក នៅ អភិបាលរង និងជាប្រធានសហភាពសហព័ន្ធយុវជនកម្ពុជាស្រុកមេមត់បានឡើងមានមតិផ្តាំផ្ញើដល់យុវជនទាំងអស់ត្រូវចិត្តទុកដាក់រៀនសូត្រ និងស្តាប់ការធ្វើបទបង្ហាញរបស់លោក ដេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំអំពើប្រល័យពូជសាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីស្វែងយល់អំពីពេលវេលា ទីតាំងប្រវត្តិសាស្ត្រ និងការបញ្ចប់សង្គ្រាមនៅកម្ពុជាដែលបានផ្តួចផ្តើមឡើងដោយសម្តេចតេ ជោ ហ៊ុន សែនៗ បន្ទាប់មកលោក អ៊ិន ពៅសម្បត្តិ ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តត្បូងឃ្មុំ បានមានមតិផ្តាំផ្ញើ និងចែករំលែកបទពិសោធន៍អំពីការរស់នៅក្នុងរបបខ្មែរក្រហម និងបានលើកទឹកចិត្តយុវជនទាំងអស់ឲ្យស្វែងយល់អំពីដំណើររបស់សម្តេចតេជោ ហ៊ុន សែន ដែលបានយកអាយុជីវិតធ្វើជាដើមទុនឆ្ពោះទៅការតស៊ូផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពតៗ នៅពេលចុងក្រោយលោក ដេង ពង្សរ៉ាស៊ី បានធ្វើបទបង្ហាញលម្អិតអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗ ក្នុងប្រទេសកម្ពុជាចាប់ពីជម្លោះរវាងទាហានសហរដ្ឋអាមេរិកដែលសហការជាមួយទាហានធីវគី បានប្រយុទ្ធទល់នឹងកងទ័ពវៀតកុងដែលគាំទ្រដោយខ្មែរក្រហមក្នុងទឹកដីស្រុកមេមត់ ចាប់ពីចុងទសវត្សរ៍ឆ្នាំ១៩៦០, ព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ របបខ្មែរក្រហម (ពីឆ្នាំ១៩៧៥-១៩៧៩) ដែលបានធ្វើឲ្យប្រជាជនកម្ពុជាប្រមាណ ២ លាន់នាក់បានស្លាប់បាត់បង់ជីវិតតាមរយៈគោលនយោបាយ ៨ចំណុចរួមមាន១)ការជម្លៀសប្រជាជនដោយបង្ខំ ២)ការលុបបំបាត់លុយ ផ្សារ ទ្រព្យសម្បត្តិឯកជន ប្រពៃណី សាសនា ទំនៀមទម្លាប់ បំផ្លាញសាលារៀន វត្តអារាម និងកន្លែងលក់ដូរផ្សេងៗ ៣)ការបង្កើតសហករណ៍ និងការដ្ឋានការងារ ៤)ការបំបាត់សិទ្ធិសេរីភាពប្រជាជន បំបែកបំបាក់ក្រុមគ្រួសារ និងបង្ខំឲ្យធ្វើការហួសកម្លាំង ៥)ការសម្លាប់អ្នកចេះដឹង អតីតទាហាន លន់ នល់ ជនជាតិចាម វៀតណាម និង ចិន ៦)ការបង្កើតមន្ទីរឃុំឃាំង ដើម្បីឃុំឃាំងប្រជាជនដែលត្រូវបានចោទថាក្បត់ ៧)ការបង្កសង្គ្រាមជាមួយវៀតណាមនៅតាមព្រំដែន និងព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ដែលសម្តេចតេជោ ហ៊ុន សែន បានយកអាយុជីវិតធ្វើជាដើមទុនឆ្ពោះទៅការតស៊ូផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ៨)ពេលវេលាប្រវត្តិសាស្ត្រនៃថ្ងៃ៧មករាៗ បន្ទាប់មកលោក ដេង ពង្សរ៉ាស៊ី បានចាក់បញ្ចាំងភាពយន្តឯកសារចំនួន ២ដល់យុវជនបានទស្សនា គឺខ្សែភាពយន្តឯកសារស្តីពីដំណើររបស់សមមិត្ត ហ៊ុន សែន ទៅប្រទេសវៀតណាម ដើម្បីប្រមែប្រមូលកងកម្លាំងវាយបកមកលើរបបប្រល័យពូជសាសន៍ ប៉ុល ពត វិញនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ និងភាពយន្តមួយទៀត គឺខ្សែភាពយន្តស្តីអំពីមរតក និងការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ៗ នៅពេលបញ្ចប់លោក រ៉ាស៊ី ក៏បានធ្វើពន្យល់ណែនាំដល់យុវជនទាំងអស់អំពីសារសំខាន់នៃការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងផលប៉ះពាល់នៃអំពើប្រល័យពូសាសន៍ជាលក្ខណៈបុគ្គលម្នាក់ ក្រុមគ្រួសារ សហគមន៍ និងសង្គមជាតិទាំងមូលៗ

សេន ម៉ារីយ៉ះ ភេទស្រីរៀនថ្នាក់ទី១២ នៅវិទ្យាល័យសម្តេច ហ៊ុន សែន ប៉ឹស២បានរៀបរាបថា នៅក្នុងសាលានាងខ្ញុំបានរៀនប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមមួយចំនួនហើយក៏ធ្លាប់បានស្តាប់ឪពុកម្តាយ ជីដូនជីតា និយាយប្រាប់អំពីការរស់នៅលំបាកវេទនាក្នុងរបបខ្មែរក្រហមដែរ ប៉ុន្តែបន្ទាប់ពីបានមកទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកោះថ្មរួចហើយ នាងខ្ញុំបានយល់ដឹងអំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមកាន់ច្បាស់ជាងមុន ដោយសារការបង្រៀនមានបញ្ចាំងខ្សែភាពយន្តឯកសារ និងមានរូប

ថតអំពីរបបខ្មែរក្រហមជាច្រើននៅក្នុងបន្ទប់មជ្ឈមណ្ឌលនេះ។ នៅពេលនាងខ្ញុំត្រឡប់ទៅផ្ទះវិញ នាងខ្ញុំនឹងចែករំលែកចំណេះដឹងអំពីរឿងរ៉ាវប្រវត្តិសាស្ត្រខ្មែរក្រហមនេះដល់មិត្តភក្តិ និងក្រុមគ្រួសារ។

ចាន់ ម៉េងជី ភេទប្រុស រៀនថ្នាក់ទី១២ នៅវិទ្យាល័យក្រូចឆ្មារ បានមានប្រសាសន៍ថា ខ្ញុំមិនធ្លាប់បានចូលរួមកម្មវិធីទស្សនកិច្ចសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហមពីមុនមកទេ នេះជាលើកទី១ហើយ ខ្ញុំធ្លាប់បានរៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងសាលា ហើយមានការជឿជាក់ថា ពិតជាមានរបបយោរយៅ វេទនាអីចឹងមែន ពីព្រោះឪពុកម្តាយខ្ញុំធ្លាប់និយាយប្រាប់ពីបទពិសោធន៍រស់នៅពិបាកវេទនាក្នុងរបបខ្មែរក្រហមហ្នឹងដែរ។ ការដែលបានមកទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកោះថ្មថ្ងៃនេះគឺពិតជាមានប្រយោជន៍សជាពិសេសយុវជនជំនាន់ក្រោយដូចរូបខ្ញុំ។ ការយល់ដឹងពីប្រវត្តិសាស្ត្រដ៏លំបាកវេទនានេះគឺជាការទប់ស្កាត់កុំឲ្យរបបនោះកើតឡើងវិញម្តងទៀត។

មជ្ឈមណ្ឌលឯកសារកោះថ្មខេត្តត្បូងឃ្មុំ គឺជាការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមមួយក្នុងចំណោមការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមទាំង ៩ របស់មជ្ឈមឯកសារកម្ពុជា៖ ១)ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម នៅខេត្តព្រៃវែង ២) ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមនៅខេត្តតាកែវ ៣) ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមនៅខេត្តត្បូងឃ្មុំ ៤) ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមនៅខេត្តកំពង់ចាម ៥) មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៅខេត្តឧត្តរមានជ័យ ៦) បណ្ណាល័យសម្តេចម៉ែនៅទីក្រុងភ្នំពេញ ៧) ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមនៅខេត្តបាត់ដំបង ៨) បណ្ណាល័យសម្តេចឪ សម្តេចម៉ែ នៅស្រុកគិរីវង់ និង ៩) ការិយាល័យព័ត៌មានសាធារណៈនៅទីក្រុងភ្នំពេញ ។

មជ្ឈមណ្ឌលឯកសារកោះថ្ម ក៏ជាកន្លែងតាំងពិពណ៌បង្ហាញអំពីបណ្តុំរូបថតដែលបន្សល់ទុកពីទសវត្សរ៍ឆ្នាំ ១៩៦០ ដល់ទសវត្សរ៍ឆ្នាំ១៩៩០។ រូបថតទាំងអស់នោះ





បានបង្ហាញពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ដោយចាប់ផ្តើមចេញពីតំបន់កោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងស្រុកស្នួលខេត្តក្រចេះ។ រូបថតនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលបានធ្វើឲ្យដែលបានធ្វើឲ្យប្រជាជនកម្ពុជាប្រមាណ២លាន់នាក់បានស្លាប់។ រូបថតភស្តុតាងមួយចំនួនអំពីបទឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមមកលើប្រជាជនកម្ពុជា។ រូបគំនូរបង្ហាញអំពីដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យ







ពូជសាសន៍ ប៉ុល ពត នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ និងចុងក្រោយ គឺរូបថតស្ដីអំពីការផ្ដួចផ្ដើមបង្កើតគោលនយោបាយ ឈ្នះ ឈ្នះ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងក្នុងទសវត្សរ៍ឆ្នាំ១៩៩០ និងការទទួលបានសន្តិភាពពេញលេញនៅក្នុងឆ្នាំ១៩៩៨។ កោះថ្ម គឺជាទីតាំងប្រវត្តិសាស្ត្រនៃដំណើរផ្សងគ្រោះថ្នាក់ដល់អាយុជីវិតរបស់សម្ដេចតេជោ ហ៊ុន សែន និងយុទ្ធមិត្ត៤នាក់ផ្សេងទៀតរួមមាន៖ នុប ថន, ញឹក ហួន, សាន សាញ់ និង វ៉ា ប៉ោអៀន ដើម្បីស្វះស្វែងរកកិច្ចអន្តរាគមន៍ និងកសាងកម្លាំងវាយផ្ដួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត។ នៅយប់ថ្ងៃទៅ២០ ខែមិថុនា ឆ្នាំ១៩៧៧ សម្ដេចតេជោ ហ៊ុន សែន និងយុទ្ធមិត្ត៤នាក់ទៀត បានសម្រេចចិត្តក្នុងស្ថានភាពដ៏លំបាកជាទីបំផុត ដោយបានធ្វើដំណើរចាកចេញពីទីបញ្ជាការដ្ឋានវរសេនាធំតំបន់ ២១ ស្ថិតនៅក្នុងភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំទាំងយប់ឆ្ពោះទៅកាន់ខេត្តប៊ិញហ្វឿក ប្រទេសវៀតណាម។

មជ្ឈមណ្ឌលឯកសារកោះថ្មត្រូវបានបង្កើតឡើង និងដាក់ដំណើរប្រើប្រាស់ជាសាធារណៈចាប់ពីថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០២០ ក្រោមការសហការយ៉ាងជិតស្និទ្ធរវាងក្រសួងអប់រំយុវជន និងកីឡា ក្រសួងការពារជាតិ និងមជ្ឈ-មណ្ឌលឯកសារកម្ពុជាក្នុងគោលបំណងដូចខាងក្រោម៖

១) ដើម្បីបង្ហាញពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រប្រទេសកម្ពុជាចាប់ពីទសវត្សរ៍ឆ្នាំ ១៩៦០រហូតដល់ទសវត្សរ៍ឆ្នាំ១៩៩០។

២) ដើម្បីពង្រឹងដល់ដំណើរការសន្តិភាព និងទប់ស្កាត់ជម្លោះនានាតាមរយៈកម្មវិធីអប់រំ។ កម្មវិធីអប់រំនេះនឹងផ្ដល់ឱកាសឲ្យយុវជនជំនាន់ក្រោយដែលភាគច្រើនរស់នៅតាមជនបទបានចូលរួមរៀនសូត្រ។

៣) លើកទឹកចិត្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងការចែករំលែកអំពីរឿងរ៉ាវបុបទពិសោធន៍ផ្ទាល់ខ្លួនដល់ក្មេងៗជំនាន់ក្រោយ។

៤) ប្រមែប្រមូលរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងទីតាំងបទឧក្រិដ្ឋដែលបានបន្សល់ពីរបបខ្មែរក្រហម។

# កងដឹកជញ្ជូនខ្មែរក្រហម

សុខ វណ្ណៈ

ខ្ញុំឈ្មោះ ចាន់ ហា អាយុ៧៧ឆ្នាំ។ ប្រពន្ធទីមួយរបស់ខ្ញុំឈ្មោះ ភឿ មានកូនចំនួន៣នាក់ ក្រោយមកខ្ញុំបានរៀបការជាមួយប្រពន្ធទីពីរឈ្មោះ ជួន ច្រិច គឺជាជនជាតិទំពួន មានកូន៤នាក់ថែមទៀត។ ខ្ញុំគឺជាជនជាតិលាវ មានស្រុកកំណើតនៅ ប៉ាំងបាត ប្រទេស ឡាវ។ កាលខ្ញុំមានអាយុ៧ឆ្នាំ ឪពុកម្តាយរបស់ខ្ញុំបានចាកចេញពីស្រុកកំណើតជាមួយបងប្អូនលាវដ៏ទៃទៀតមករស់នៅប្រទេសកម្ពុជា។

ឪពុកខ្ញុំបានដំណាល់ប្រាប់ថា ក្រុមគ្រួសារខ្ញុំ និងក្រុមគ្រួសារ លាវដ៏ទៃទៀតបានធ្វើដំណើរតាមរទេះគោចំនួន១២គ្រឿងកាត់ព្រៃ និងផ្លូវលំយ៉ាងលំបាកទំរាំមកដល់ទឹកដីប្រទេសកម្ពុជា។ ឪពុកម្តាយរបស់ខ្ញុំបានជ្រើសរើសរស់នៅក្នុងភូមិពាមជីមៀត ឃុំណងឃីលិក ស្រុកកោះញែក ខេត្តមណ្ឌលគិរី។

ខ្ញុំមានបងប្អូនបង្កើតចំនួន៦នាក់ ហើយខ្ញុំគឺជាកូនទី៣។ កាលពីកុមារភាពខ្ញុំបានរស់នៅជាមួយឪពុកឈ្មោះ ចាន់ ម្តាយឈ្មោះ ផង គឺជាជនលាវដូចគ្នា។ ខ្ញុំបានរៀនសូត្រនៅសាលាបឋមសិក្សាក្នុងភូមិពាមជីមៀត។ ខ្ញុំចេះអាននិងសរសេរអក្សរខ្មែរបានបន្តិចបន្តួច។ នៅឆ្នាំ១៩៥០ ខ្ញុំបានបួសជាព្រះសង្ឃនៅវត្តពាមជីមៀតប្រហែល៤វស្សាក៏បានលាចាកសិក្ខាបទរួចហើយបានចូលធ្វើទាហាននៃរបបសង្គមរាស្ត្រនិយម។ ខ្ញុំបានចូលធ្វើទាហានមួយឆ្នាំកន្លះក៏ឈប់ និងវិលត្រឡប់មកស្រុកកំណើតរៀបការប្រពន្ធ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក៏មានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុហើយប្រទេសជាតិចាប់កើតមានសង្គ្រាមជាបន្តបន្ទាប់រវាងខ្មែរនិងខ្មែរ និងមានការចូលរួមពីកងទ័ពយួនវៀតកុង។ កាលនោះខ្ញុំបានស្ម័គ្រចូលបម្រើចលនាបដិវត្តន៍ខ្មែរក្រហមតាមរយៈឈ្មោះ ខៀវ ប៊ុន គឺជាចៅហ្វាយខេត្តមណ្ឌលគិរី។ នៅអំឡុងឆ្នាំ១៩៧០ ចលនាបដិវត្តន៍ខ្មែរក្រហមបានវាយប្រយុទ្ធជាមួយទាហាន លន់ នល់ តាមយុទ្ធវិធីធ្វើសង្គ្រាមឈ្លប ប៉ុន្តែមានសកម្មភាពអង់អាចខ្លាហាន តស៊ូ លះបង់ រហូតទទួលជ័យជម្នះលើទាហាន លន់ នល់ ជាបន្តបន្ទាប់។



ចាន់ ហា អាយុ៧៧ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិពាមជីមៀត ឃុំណងឃីលិក ស្រុកកោះញែក ខេត្តមណ្ឌលគិរី។ (សុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

*នៅក្នុងរយៈពេលសង្គ្រាម៥ឆ្នាំ ខ្ញុំបានស្គាល់ តាសារុន តាខាំភួន និងតាឡាំង ដែលជាអ្នកដឹកនាំកងកម្លាំងខ្មែរក្រហមប្រចាំនៅខេត្តមណ្ឌលគិរី តំបន់១០៥។*

*នៅឆ្នាំ១៩៧៥ ពេលខ្មែរក្រហមឡើងកាន់អំណាច ខ្ញុំបានត្រឡប់មកស្រុកកំណើតវិញ។ ពេលនោះអង្គការបានប្រជុំប្រាប់ថា ប្រជាជនទាំងអស់មានសិទ្ធិស្មើៗគ្នា គ្មានអ្នកមានគ្មានអ្នកក្រ។ យើងរស់នៅមានជីវភាពស្មើគ្នា បើបងប្អូនណាមានទ្រព្យសម្បត្តិផ្ទាល់ខ្លួន ដូចជា មាសប្រាក់ ដីស្រែចម្ការ គោក្របី ត្រូវតែប្រគល់ជូនអង្គការ។ ពេលនោះគណៈតំបន់១០៥ មានឈ្មោះតាឡាំង និងតាខាំភួន ចំណែកគណៈស្រុកកោះញែក មានឈ្មោះ តាផាក, តាធុច, តាសារុន និងខ្ញុំផ្ទាល់។*

*នៅឆ្នាំ១៩៧៧ កម្មាភិបាលថ្នាក់ស្រុកថ្នាក់តំបន់១០៥មួយចំនួន ត្រូវអង្គការហៅទៅរៀនសូត្រនៅទីក្រុងភ្នំពេញ និងក្រោយមកបាត់ខ្លួនរហូត។ បន្ទាប់មក តាសារុន និង តាអនស៊ីដែលជាអតីតគណៈស្រុកកែវសីមា បានឡើងជាគណៈតំបន់១០៥ ជំនួសវិញ។*

*នៅឆ្នាំ១៩៧៩ ខ្ញុំបានរត់ចូលព្រៃជាមួយកងទ័ពខ្មែរក្រហមដែលដឹកនាំដោយ តាសារឿន និងបានធ្វើដំណើររហូតដល់ភ្នំដងរែង ក្នុងស្រុកអន្លង់វែងខេត្តឧត្តរមានជ័យ។ នៅឆ្នាំ១៩៨២ ខ្ញុំបានមកដល់ភ្នំដងរែក និងបានផ្លាស់មកនៅជាមួយ តាវៀង, តាសារុន និងតាអនស៊ុ ក្នុងកងពល១០៥វិញ។ ចំណែក តាសារឿន (០៥) និងតាសាន (០៦) គឺជាថ្នាក់ដឹកនាំកម្លាំង និងចលនាខ្មែរ*



*ព្រះវិហារវត្តអន្ទ្រងសែនជ័យ ស្ថិតនៅក្នុងឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី។ (សុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*





*សាលាបឋមសិក្សាអន្ទ្រងសែនជ័យ ស្ថិតនៅក្នុងឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី។ (សុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ក្រហមប្រចាំភូមិភាគឦសានដើម្បីធ្វើការប្រឆាំងនឹងវត្តមានកងទ័ពវៀតណាមនៅលើទឹកដីកម្ពុជា។ នៅពេលនោះកងកម្លាំងខ្មែរក្រហមបានធ្វើការឃោសនាក្នុងចំណោមប្រជាជននៅតាមភូមិស្រុក និងប្រយុទ្ធជាមួយកងទ័ពវៀតណាមដែលសហការជាមួយកងទ័ពរដ្ឋាភិបាលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។

នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ និង ១៩៩០ ខ្ញុំមានតួនាទីជាគណៈវរសេនាធំទទួលផ្នែកដឹកជញ្ជូនស្បៀងដល់កងពល១០៥ ដែលប្រចាំការនៅសមរភូមិក្នុងខេត្តក្រចេះ និងខេត្តមណ្ឌលគិរី។ នៅពេលនោះខ្មែរក្រហមទទួលបានជំនួយជាសព្វាវុធធំតូច សម្ភារ ស្បៀងអាហារ និងថ្នាំពេទ្យមកពីប្រទេសចិន។

នៅពាក់កណ្តាលឆ្នាំ១៩៩០ រាជរដ្ឋាភិបាលកម្ពុជា និងសម្តេច ហ៊ុន សែន បានបង្កើតគោលនយោបាយ ឈ្នះ ឈ្នះ ដែលមានន័យថា ឈ្នះទាំងអស់គ្នា គឺគ្មានអ្នកឈ្នះ គ្មានអ្នកចាញ់ ស្របពេលដែលក្រុមខ្មែរក្រហមកំពុងបែកបាក់គ្នាផងនោះ កងកម្លាំងខ្មែរក្រហមនៅតាមតំបន់នីមួយៗបានធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជាជាបន្តបន្ទាប់។ ប្រទេសកម្ពុជាបានបញ្ចប់សង្គ្រាមស៊ីវិលទាំងស្រុងនៅចុងឆ្នាំ១៩៩៨។

ខ្ញុំមានការសប្បាយចិត្តយ៉ាងខ្លាំងដែលថ្នាក់ដឹកនាំបានបង្រួមបង្រួមជាតិ។ បន្ទាប់ពីសមាហរណកម្មជាមួយរាជរដ្ឋាភិបាល ខ្ញុំបានបន្តធ្វើទាហាននៅក្នុងក្របខណ្ឌកងយោធពលខេមរភូមិន្ទរហូតដល់ឆ្នាំ ២០០០ ទើបចូលនិវត្តន៍ និងបាននាំក្រុមគ្រួសារប្រកបមុខរបរធ្វើស្រែចម្ការដូចបងប្អូនជនជាតិភាគតិចដ៏ទៃទៀត។ សព្វថ្ងៃខ្ញុំសប្បាយចិត្តព្រោះបានឃើញកូនចៅចូលរៀន មានផ្លូវថ្នល់ស្អាត មានមន្ទីរពេទ្យ មានផ្សារលក់ដូរមានមនុស្សអ៊ូអរច្រើន មិនដូចសម័យមានសង្គ្រាមឡើយ។



ព្រៃជឿរបស់ជនជាតិភាគតិចក្នុងខេត្តមណ្ឌលគិរី។ (សុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ម៉ែន ម៉ូវ ៖ ខ្ញុំបានចាប់ផ្តើមកសាងជីវភាពពីបាត់ដៃទទេ

គាត ស្រីឡែន



ម៉ែន ម៉ូវ ជនជាតិស្ទៀង អាយុ៨២ឆ្នាំ
រស់នៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ភូមិក្តុលលើ គឺជាតំបន់សង្គ្រាមក្តៅមួយដោយមានវត្តមានទាហានសហរដ្ឋអាមេរិកទាហានវៀតណាមខាងត្បូង (ធីវ-គី) កងទ័ពវៀតកុង និងកងទ័ពខ្មែរក្រហមតាំងពីចុងទសវត្សរ៍ឆ្នាំ១៩៦០។ ប្រជាជនរស់នៅភូមិក្តុលលើ និងភូមិជិតខាងនេះសុទ្ធតែធ្លាប់ទទួលរងគ្រោះនៃការទម្លាក់គ្រាប់បែក ការរត់គេចពីគ្រាប់កាំភ្លើង និងត្រូវបានជម្លៀសចេញពីភូមិស្រុកឲ្យទៅរស់នៅតំបន់ និងខេត្តឆ្ងាយៗ លោកយាយម្នាក់រស់ភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ មានសម្បុរសណ្តែកបាយ មាឌតូចល្អិត និងដំណើរមួយៗ បានរៀបរាប់ពីរៀបរាប់រឿងរ៉ាវជីវិតរបស់គាត់ដែលបានឆ្លងកាត់ក្នុងសង្គ្រាមដ៏កាចសាហាវដូចខាងក្រោម ៖

ខ្ញុំឈ្មោះ ម៉ែន ម៉ូវ ជនជាតិដើមភាគតិចស្ទៀង មានអាយុ ៨២ឆ្នាំ ខ្ញុំមានស្រុកកំណើតនៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម ដែលបច្ចុប្បន្នគឺខេត្តត្បូងឃ្មុំ។ សព្វថ្ងៃខ្ញុំរស់នៅភូមិឃុំដដែល។ ខ្ញុំមានឪពុកឈ្មោះ ម៉ែ (ស្លាប់) និងមានម្តាយឈ្មោះ ខួច (ស្លាប់)។ ខ្ញុំមានបងប្អូន៧នាក់ ក្នុងនោះមានស្រី៥នាក់ និងប្រុស២នាក់។ ប្អូនប្រុសរបស់ខ្ញុំម្នាក់បានស្លាប់ដោយសារតែជំងឺគ្មានថ្នាំព្យាបាលនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំគឺជាកូនទី៥ នៅក្នុងគ្រួសារ។ ខ្ញុំមានប្តីឈ្មោះ ហានយុន និងមានកូនប្រុស២នាក់។

កាលពីខ្ញុំនៅក្មេង ខ្ញុំមិនបានរៀនសូត្រទេដោយសារតែសម័យនោះមិនមានសាលារៀន។ ប្រសិនបើសិស្សចង់រៀនសូត្រ ត្រូវទៅរៀននៅតាមវត្ត ឬក្រោមម្លប់ឈើ។ នៅក្នុងភូមិរបស់ខ្ញុំមិនសូវមានមនុស្សរៀនសូត្របានច្រើនទេដោយសារមិនមានសាលារៀន ហើយឪពុកម្តាយមានជីវភាពខ្វះខាត។ នៅសម័យនោះក្មេងបានរៀនសូត្រ ចេះអាន និងចេះសរសេរគឺតិចតួចណាស់។ ដោយសារតែខ្ញុំមិនបានចូលរៀន ដូច្នេះខ្ញុំត្រូវជួយឪពុកម្តាយធ្វើស្រែចម្ការ ដាំបន្លែបង្ការ ហើយពេលទំនេរត្រូវជួយមើលប្អូនតូចៗ។

ខ្ញុំរៀបការនៅអាយុ២០ឆ្នាំ។ បន្ទាប់ពីខ្ញុំសម្រាលបានកូនប្រុសមួយ ទើបរាជរដ្ឋាភិបាលសាងសង់សាលាបឋមសិក្សាមួយនៅក្នុងភូមិក្ដុលលើ។ សាលានោះបានបើកឲ្យសិស្សបានចូលរៀនរហូតមកដល់សព្វថ្ងៃ។ នៅពេលនោះ ខ្ញុំនិងប្ដីបានប្រកបរបរធ្វើចម្ការ ដាំបន្លែបង្ការសម្រាប់ហូបចុកប្រចាំថ្ងៃ។ យើងមានជីវភាពមធ្យមហូបគ្រប់គ្រាន់ និងមិនលំបាកទេ។ នៅកាលសម័យនោះមានប្រជាជនភាគច្រើនរស់នៅប្រកបរបរកសិកម្ម ធ្វើចម្ការ ដាំស្រូវតាមព្រៃ និងដាំបន្លែបង្ការនៅក្បែរផ្ទះរៀងៗខ្លួន។

នៅចុងទសវត្សរ៍ឆ្នាំ១៩៦០ ក៏កើតមានសង្គ្រាម ទាហានអាមេរិកបានមកទម្លាក់គ្រាប់បែកនៅភូមិក្ដុលលើ និងភូមិមួយចំនួននៅក្បែរនោះ។ ខ្ញុំមានការភ័យខ្លាចខ្លាំងណាស់ព្រោះមិនដឹងថានឹងមានអ្វីបានកើតឡើងនៅក្នុងភូមិរបស់ខ្ញុំឡើយ។ បន្ទាប់មកទាហានអាមេរិក និងរថក្រោះអាមេរិក បានចូលមកដល់ភូមិក្ដុលលើ។ មានមនុស្សជាច្រើនបានត្រូវគ្រាប់រងរបួស និងបាត់បង់ជីវិតដោយសារការទម្លាក់គ្រាប់បែក និងការប្រយុទ្ធគ្នារវាងទាហានអាមេរិកសហការជាមួយទាហានវៀតណាមខាងត្បូង (ធីវគី) វាយប្រយុទ្ធតទល់ជាមួយកងទ័ពវៀតកុងដែលមានការគាំទ្រពីសំណាក់ខ្មែរក្រហម។ ដោយសារតែសង្គ្រាមបានបណ្ដាលឲ្យប្រជាជនមួយចំនួនត្រូវពិការដៃ ពិការជើង និងភ្នែករហូតមកដល់សព្វថ្ងៃ។ ពិការភាពទាំងនេះបានធ្វើឲ្យប៉ះពាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេផងដែរ។

បន្ទាប់ពីសង្គ្រាមជាមួយទាហានអាមេរិកបានបញ្ចប់ នៅក្នុងស្រុកភូមិរបស់ខ្ញុំ ត្រូវធ្លាក់ចូលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ខ្មែរក្រហមបានបង្ខំឲ្យប្រជាជនដែលរស់នៅក្នុងភូមិធ្វើស្រែចម្ការ និងហូបចុករួមគ្នានៅក្នុងសហករណ៍។ នៅក្នុងសម័យនោះខ្មែរក្រហមបានជម្លៀសប្រជាជនថ្មីចំនួន ៥គ្រួសារ មកពីភ្នំពេញឲ្យមករស់នៅក្នុងភូមិក្ដុលលើ។ ក្នុងនោះមានប្រជាជនថ្មីមួយគ្រួសារត្រូវបានចាត់តាំងឲ្យស្នាក់នៅក្នុងផ្ទះជាមួយគ្រួសារខ្ញុំ។ ខ្មែរក្រហមបានចាត់តាំងឲ្យប្រជាជនថ្មីធ្វើការងារដូចប្រជាជនមូលដ្ឋានដែរ គឺត្រូវទៅធ្វើស្រែចម្ការ ដកស្ទូង និងធ្វើការងារកសិកម្មផ្សេងៗទៀត។



ផ្លូវលំចូលទៅផ្ទះ ម៉ែន ម៉ូវ ស្ថិតនៅភូមិក្ដុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ (កាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រជាជនថ្មីក៏ត្រូវរស់នៅ និងហូបចុករួមនៅក្នុងសហករណ៍ដូចគ្នា។

នៅក្នុងរបបខ្មែរក្រហមប្រជាជននៅភូមិក្ដុលលើត្រូវបានកម្មាភិបាលឲ្យហូបបបរនៅពេលថ្ងៃត្រង់ និងហូបបាយនៅពេលល្ងាច។ ប្រជាជនបានចាញ់ការឃោសនាខ្មែរក្រហម ដោយជឿថា ពេលខ្មែរក្រហមបានឡើងកាន់អំណាចនឹងមានបាយហូបគ្រប់គ្រាន់ ប៉ុន្តែជាក់ស្តែងមិនដូចការគិតរបស់ប្រជាជនឡើយ។ នៅក្នុងរបបខ្មែរក្រហម ប្រជាជនជួបការលំបាក និងវេទនាខ្លាំង គឺផ្ទុយស្រឡះពីការរស់នៅជាឯកជនតាមគ្រួសារប្រកបរបររកស៊ីដោយខ្លួនឯង គឺប្រជាជនបានហូបចុកគ្រប់គ្រាន់ និងមិនធ្វើការងាររួមគ្នានៅក្នុងសហករណ៍ឡើយ។ នៅក្នុងរបបខ្មែរក្រហម ប្រជាជនត្រូវធ្វើការងារពលកម្ម



ផ្ទះរបស់ ម៉ែន ម៉ូរ ស្ថិតនៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ (គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ច្រើនម៉ោង និងធ្ងន់ធ្ងរ ហើយហូបចុកមិនគ្រប់គ្រាន់។ ប្រជាជនមួយចំនួនមានជំងឺ និងស្លាប់ដោយសារខ្វះចំណីអាហារ។

នៅអំឡុងចុងឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨ ខ្មែរក្រហមបានជម្លៀសប្រជាជននៅភូមិក្តុលលើ និងភូមិមួយចំនួនទៀតឲ្យទៅរស់នៅភូមិស្រែតាពិច និងភូមិកូនក្រពើ ក្នុងឃុំជាំតាម៉ៅ។ ខ្ញុំនិងក្រុមគ្រួសារបានរស់នៅភូមិស្រែតាពិច បានជិតមួយវស្សា។ នៅទីនោះ គ្រួសារខ្ញុំ និងអ្នកភូមិទាំងអស់កាន់តែមានជីវភាពខ្វះខាត និងវេទនាជាងមុនទៅទៀត។ ប្រជាជនបានស្លាប់កាន់តែច្រើនដោយសារអស់កម្លាំង ទៀយហត់ ខ្វះចំណីអាហារ ឈឺថ្កាត់គ្មានថ្នាំសង្កូវព្យាបាល។ ចំណែកការងារពលកម្មវិញ គឺមិនខុសគ្នាពីការងារដែលខ្ញុំ និងអ្នកភូមិដទៃទៀតធ្លាប់បានធ្វើកាលនៅភូមិក្តុលលើទេ គឺខ្មែរក្រហមបានបង្ខំឲ្យយើងធ្វើការងារពលកម្មគ្រប់បែបយ៉ាងដូចជា ដកស្ទូង កាប់ដី ធ្វើស្រែចម្ការស្ទើរគ្មានពេលសម្រាក។ ភូមិស្រែតាពិច គឺជាទីកន្លែងដែលប្អូនប្រុសរបស់ខ្ញុំម្នាក់បានស្លាប់បាត់បង់ជីវិតដោយជំងឺគ្មានថ្នាំព្យាបាល។ ចំណែក ខ្ញុំមិនបានរស់នៅជួបជុំប្តី និងកូនទេ ប្តីរបស់ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យចេញទៅធ្វើការងារនៅឃុំចាន់មូល ស្រុកត្រាមូង តំបន់២១ ភូមិភាគបូព៌ា។

ខ្ញុំបានជួបជុំប្តីខ្ញុំវិញនៅពេលដែលខ្មែរក្រហមបន្តជម្លៀសប្រជាជនពីស្រែពិជទៅស្រុកស្នួលខេត្តក្រចេះ។ គ្រួសារខ្ញុំ និងអ្នកភូមិដទៃទៀតបានមករស់នៅ និងធ្វើការងារពលកម្មនៅឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះមួយរយៈ ទើបខ្មែរក្រហមបន្តជម្លៀសទៅទីរួមខេត្តក្រចេះទៀត។ ខ្ញុំ និងប្តីបានស្នាក់នៅម្តុំថ្មគ្រែមិនបានប៉ុន្មានថ្ងៃផង ក៏ត្រូវបានខ្មែរក្រហមបញ្ជូនឡើងកាណូតធ្វើដំណើរមកកាន់ស្រុកស្ទឹងត្រង់ភូមិភាគកណ្តាលវិញ។ បន្ទាប់មកខ្មែរក្រហមបានយករថយន្តដឹកខ្ញុំនិងគ្រួសារឲ្យមករស់នៅក្នុងស្រុកចម្ការលើ។

នៅខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានវាយចូលមកដល់ស្រុកចម្ការលើខ្មែរក្រហមក៏បានរត់ចេញទៅបាត់អស់។ នៅខណៈពេលនោះខ្ញុំរួមជាមួយក្រុមគ្រួសារ និងអ្នកភូមិផ្សេងដទៃទៀតបានធ្វើដំណើរត្រឡប់មកស្រុកកំណើតវិញ។ ពេលត្រឡប់មកដល់ផ្ទះវិញ គឺមានភាពស្ងប់ស្ងាត់និងគ្មានមនុស្សរស់នៅឡើយ។ ចំណែកឯផ្ទះសម្បែងវិញ គឺព្រៃដុះព័ទ្ធជុំវិញ ពីព្រោះគ្មានមនុស្សរស់នៅយូរឆ្នាំមកហើយ។ ខ្ញុំនិងក្រុមគ្រួសារបានកាប់ឆ្ការព្រៃ និងរៀបចំផ្ទះឡើងវិញ។ គ្រួសារខ្ញុំបានចាប់ផ្តើមកសាងជីវភាពពីបាត់ដៃទទេ ដោយធ្វើស្រែចម្ការដាំដុះដំណាំផ្សេងៗដើម្បីចិញ្ចឹមជីវិតរហូតមកដល់សព្វថ្ងៃនេះ។

# ពេទ្យនារីខ្មែរក្រហម

ស្ងួត វិចិត្រ



*កងនារីពេទ្យក្មេងៗនៅក្នុងរបបខ្មែរក្រហមកំពុងផលិតថ្នាំពេទ្យដែលផ្សំចេញពីរុក្ខជាតិ។ ថ្នាំនេះត្រូវបានខ្មែរក្រហមយកទៅព្យាបាលជំងឺជាច្រើនមុខ ដែលប្រជាជនហៅឈ្មោះថា ថ្នាំអាចម៍ទន្សាយ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ឡាយ ណាត ភេទស្រី អាយុ៦១ឆ្នាំ មានទីកន្លែងកំណើតនៅភូមិដំណាក់សង្កែ ឃុំស្ដើងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។ ណាត បានរៀបរាប់ពីបទពិសោធន៍នៃជីវិតជាពេទ្យនារីខ្មែរក្រហម និងការមកដល់តំបន់អន្លង់វែងដូចខាងក្រោម៖

« នៅមុនឆ្នាំ១៩៧៥ គ្រួសាររបស់ខ្ញុំជាកសិករ ហើយយើងបានរស់នៅជួបជុំគ្នាយ៉ាងកក់ក្ដៅ។ ជីវិតរស់នៅប្រចាំថ្ងៃរបស់យើង គឺពឹងផ្អែកជាចម្បងទៅលើការងារធ្វើស្រែ។ យើងបានប្រើប្រាស់ចបកាប់ដើម្បីបង្កបង្កើនផល ពីព្រោះយើងមិនមានគោ ឬក្របីទេនៅពេលនោះ។ យើងបានរស់នៅ និងធ្វើស្រែរហូតដល់ពេលខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុងនៅទូទាំងប្រទេសក្នុងឆ្នាំ១៩៧៥។ ខ្ញុំមានការត្រេកអរខ្លាំងណាស់អំឡុងនោះ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ខ្ញុំនៅតែគិតក្នុងចិត្តថា សង្គ្រាមនៅក្នុងប្រទេសរបស់យើងនៅមិនទាន់បញ្ចប់ទាំងស្រុងនោះទេ។ ក្រោយមក ខ្មែរក្រហមបានជម្លៀសខ្ញុំ និងប្រជាជនរាប់ពាន់នាក់ដោយថ្មើជើងចេញពីភូមិកំណើតទៅកាន់ស្គន់ ក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម។



*ទីតាំងការដ្ឋានជីកជញ្ជូន ឬ ឃ្លាំងកណ្តាលរបស់ តាម៉ុក នៅឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (អ៊ូច មករា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

បន្ទាប់ពីទៅដល់ទីនោះភ្លាម ខ្មែរក្រហមបានចាត់តាំងខ្ញុំ និងប្រជាជនរាប់ពាន់នាក់ផ្សេងទៀតឲ្យធ្វើការងារក្នុងកងចល័ត។ ជារៀងរាល់ថ្ងៃ យើងបានជីកប្រឡាយ និងលើកទំនប់។ ខ្មែរក្រហមបានជំរុញឲ្យប្រជាជនទាំងអស់ដែលរស់នៅក្រោមការគ្រប់គ្រងរបស់ខ្លួនសម្រេចតាមគម្រោងផែនការមុនពេលរដូវវស្សាឈានចូលមកដល់។ យើងបានជួបការលំបាកយ៉ាងខ្លាំងអំឡុងពេលលើកទំនប់ និង ជីកដី ព្រោះជាកិច្ចការងារដែលយើងមិនធ្លាប់ធ្វើពីមុនមក។ យើងបាននាំគ្នាធ្វើការតាំងពីព្រលឹមទល់ព្រលប់ ដោយគ្មានពេលសម្រាក ហើយការហូបចុករបស់យើងក៏មិនបានប្រសើរឡើងដែរ។ ជារៀងរាល់ថ្ងៃ យើងត្រូវហូបបបរជន្លួសបាយ។ នៅពេលមួយចុងភៅបានរម្ងាស់ក្រពះ ជ្រូកជាមួយប្រហុកដ៏គួរឲ្យខ្ពើមមកឲ្យយើងហូប។ យើងពិបាកលេបណាស់ ហើយជារឿយៗ យើងបានស្វែងរកដំឡូងព្រៃ និងបន្លែបៃតងដើម្បីយកផ្សែផ្សំធ្វើអាហារបរិភោគបម្រែតក្រពះដោយលួចលាក់។ យើងរស់នៅក្រោមភាពភ័យខ្លាច ព្រោះប្រធានកងរបស់យើងដែលជាមេភូមិកាចសាហាវ និងតឹងរឹងខ្លាំង។ នៅពេលគាត់កំណត់គោលដៅ និងសង្ស័យទៅលើនរណាម្នាក់ ឬក្រុមណាមួយ អ្នកទាំងនោះ កម្ររួចខ្លួនណាស់។ ប្រជាជនជាច្រើនត្រូវបានធ្វើទារុណកម្ម នៅក្រោមការត្រួតត្រារបស់គាត់។ គាត់តែងបើកការប្រជុំបូកសរុបលទ្ធផលជារៀងរាល់ពេលល្ងាចបន្ទាប់ពីយើងសម្រាកពីការងារនៅតាមដ្ឋាន។ ខ្ញុំចាំបានថា យើងត្រូវបានប្រធានសហករណ៍ស្តីបន្ទោស និងជេរប្រមាថខ្លាំងៗ នៅពេលមានអ្នករាយការណ៍ថាមានលាក់កម្លាំងនៅក្នុងការដ្ឋាន។

រហូតដល់ឆ្នាំ១៩៧៧ ខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យចូលរៀនខាងផ្នែកវេជ្ជសាស្ត្រដើម្បីព្យាបាលជំងឺប្រជាជននៅតាមការដ្ឋាន និងនៅតាមភូមិៗ ខ្ញុំបានជួបនូវផលលំបាកច្រើននៅអំឡុងពេលនោះដោយសារខ្ញុំមិនចេះអានអក្សរ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ខ្មែរក្រហមពុំបានឲ្យតម្លៃទៅលើក្រុមបញ្ញវន្ត ឬអ្នកចេះដឹងឡើយ។ ខ្ញុំបានរៀនសូត្រពីរបៀបចាក់ថ្នាំ លាងរបួស និងព្យួរសេរ៉ូមឲ្យអ្នកជំងឺ។ តាស្រ៊ុន គឺជាគ្រូពេទ្យមួយរូបដែលត្រូវបានថ្នាក់លើខ្មែរក្រហមចាត់តាំងឲ្យមកបណ្ដុះបណ្ដាលដល់ខ្ញុំ។ តាស្រ៊ុន ត្រូវបានចាប់ខ្លួន និងសម្លាប់យ៉ាងអាថ៌កំបាំង បន្ទាប់ពីខ្មែរក្រហមបានចោទប្រកាន់គាត់ថា មានទំនាក់ទំនង និងបានផ្ដល់ថ្នាំពេទ្យមួយចំនួនទៅឲ្យខ្មែរក្បត់។ ចាប់តាំងពីពេលនោះមក យើងមិនដែលបានជួបគាត់ទៀតទេ។

ក្រោយពីបានបណ្ដុះបណ្ដាលក្នុងរយៈពេលខ្លី យើងបានយកចំណេះវិជ្ជាបន្តិចបន្តួចនេះ ដើម្បីជួយសង្គ្រោះជំងឺនៅតាមការដ្ឋាន និងភូមិស្រុក។ ទន្ទឹមនឹងការព្យាបាលអ្នកជំងឺរាប់ពាន់នាក់ ខ្មែរក្រហមនៅតែសង្ស័យ និងធ្វើបាបប្រជាជនរាប់សិបនាក់នៅតាមការដ្ឋាន។ មិនត្រឹមតែជនជាតិខ្មែរប៉ុណ្ណោះទេ ដែលខ្មែរក្រហមធ្វើបាប សូម្បីតែជនជាតិចាម និងជនជាតិដើមភាគតិច ក៏ទទួលរងទុក្ខវេទនាយ៉ាងធ្ងន់ធ្ងរដែរ។ ខ្ញុំចាំបានថា ប្រធានសហករណ៍មួយរូបបានធ្វើទុក្ខបុកម្នេញទៅលើជនជាតិចាមម្នាក់ដែលបានរាប់អានជាមួយម្ដាយរបស់ខ្ញុំដូចបងប្អូនបង្កើត។ គាត់ឈ្មោះ សុះ។ គាត់ត្រូវបានខ្មែរក្រហមឃុំឃាំងនៅក្នុងគុកអស់រយៈពេល១សប្ដាហ៍ ដោយមិនដឹងមូលហេតុ។ ដោយសារការអត់ឃ្លាន និងការវាយធ្វើបាបខ្លាំងពេក គាត់ក៏បានសម្រេចចិត្តវាយជាមួយឆ្មាំគុក ដើម្បីដណ្ដើមយកកាំភ្លើងនៅក្បែរនោះ ហើយបាញ់ស្រោចទៅលើឆ្មាំគុកខ្មែរក្រហមស្លាប់បួននាក់។ បន្ទាប់មកគាត់បានរត់គេចខ្លួននៅក្នុងគ្រានោះ ។

មកដល់ឆ្នាំ១៩៧៨ ខ្ញុំបានធ្វើដំណើរទៅកាន់មន្ទីរមួយនៅស្គន់ នៅវេលាម៉ោងប្រហែល៤ល្ងាច ដើម្បីបើកថ្នាំមកយកព្យាបាលអ្នកជំងឺ។ នៅទីនោះមានសភាពស្ងាត់ជ្រងំ និងគ្មានអ្នកយាមការពារឡើយ។ ខ្ញុំបានរង់ចាំអស់រយៈពេលមួយស្របក់ធំ ក៏ឮចម្រៀងចលនាបដិវត្តន៍



បរិវេណការដ្ឋានដឹកជញ្ជូន ឬ ឃ្លាំងកណ្ដាល របស់ តាម៉ុក នៅឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្ដរមានជ័យ។ (ស្ងួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្មែរក្រហម ដែលបន្លឺឡើងយ៉ាងខ្លាំងៗនៅមិនឆ្ងាយពីទីកន្លែងនោះ។ ខ្ញុំមានការងឿងឆ្ងល់ថាហេតុអ្វីបានជាខ្មែរក្រហមចាក់ចម្រៀងឮខ្លាំងៗ ដូច្នេះខ្ញុំក៏ដើរទៅរកតាមរកសំឡេងក្នុងព្រៃក្បែរនោះ។ នៅពេលទៅដល់ភ្លាម ខ្ញុំបានឃើញមនុស្សជាច្រើននាក់ រួមមានទាំងសមាជិកពេទ្យនៅកងជាមួយខ្ញុំ ត្រូវបានខ្មែរក្រហមដឹកយកមកសម្លាប់យ៉ាងអនោចអធមនៅក្បែរវត្តស្គន់ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។ តាមខ្ញុំចាំ មានមនុស្សចាស់ និងក្មេងៗ ត្រូវបានសម្លាប់ជាបន្តបន្ទាប់ រួចទម្លាក់ចូលក្នុងអណ្ដូងទឹកដែលមានដើមកណ្ដុរដុះនៅក្បែរនោះ។ មនុស្សចាស់ត្រូវបានខ្មែរក្រហមសម្លាប់ដោយវាយនឹងត្បូងចប ចំណែកកុមារ



ដែលមានអាយុចាប់ពី៨ខែ រហូតដល់១ឆ្នាំ ត្រូវបានខ្មែរក្រហមបោកខ្ទប់នឹងដើមកណ្តុរយ៉ាងព្រៃផ្សៃ។ សាកសពជាច្រើននាក់ ត្រូវបានខ្មែរក្រហមបោះចូលទៅក្នុងអណ្តូងទឹក។ ខ្ញុំមានការភ័យខ្លាច និងតក់ស្លុតយ៉ាងខ្លាំង បន្ទាប់ពីបានឃើញហេតុការណ៍ដ៏សោកសង្រេងនេះ។ ខ្ញុំបានប្រញាប់ប្រញាល់គេចខ្លួនចេញពីទីនោះ។ ខ្ញុំបានមកដល់អង្គភាពនៅប៉ុន្មានម៉ោងក្រោយមក។ នៅយប់នោះខ្ញុំដេកមិនលក់ទេព្រោះនឹកឃើញរឿងរ៉ាវដែលកើតឡើងកាលពីវេលាល្ងាច។ ចាប់តាំងពីពេលនោះមក ខ្ញុំបានរស់នៅក្នុងភាពភ័យខ្លាច និងមានគំនិតចង់ផ្តាច់ខ្លួនចេញពីខ្មែរក្រហម។ ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំមិនអាចរក



ស្លាកសញ្ញាបង្ហាញទីតាំងការដ្ឋានដឹកជញ្ជូន ឬ ឃ្លាំងកណ្តាល របស់ តាម៉ុក។ (សួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ឱកាសគេចខ្លួន ពីព្រោះស្ថានការណ៍នៅពេលនោះតឹងតែង។ ខ្ញុំបានរស់នៅជាមួយខ្មែរក្រហម រហូតដល់ពេលកងទ័ពរណសិរ្សសាមគ្គីសង្រ្គោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាមបានចូលមកដល់ទីក្រុងភ្នំពេញ នៅដើមឆ្នាំ១៩៧៩។

ខ្ញុំមិនខ្លាចកងទ័ពរដ្ឋាភិបាល និងវៀតណាមទេ ប៉ុន្តែខ្ញុំមានក្តីរំភើបចិត្តជាខ្លាំង។ ប្រធានសហករណ៍របស់ខ្ញុំដែលធ្លាប់ធ្វើទុក្ខបុកម្នេញទៅលើប្រជាជនស្លូតត្រង់ទៅលើជនជាតិដើមភាគតិច និងជនជាតិចាម ត្រូវបានក្រុមសាច់ញាតិជនរងគ្រោះ និងអ្នកធ្លាប់ទទួលរងការឈឺចាប់បាន កាត់ម្រាមដៃ ម្រាមជើង និងផ្នែកផ្សេងៗទៀតនៃរូបរាងកាយរបស់គាត់បន្តិចម្តងៗ រហូតដល់ដាច់ខ្យល់ស្លាប់នៅនឹងកន្លែង។

ពេលដែលសង្រ្គាមបានបញ្ចប់ ហើយប្រទេសទទួលបានសុខសន្តិភាព នៅអំឡុងឆ្នាំ ២០០០ ខ្ញុំក៏បានមករស់នៅតំបន់អន្លង់វែង ដោយសារនៅតំបន់នេះមានផ្ទៃដីធំទូលាយ និងអាចធ្វើស្រែចម្ការ តាមរយៈប្អូនប្រុសរបស់ខ្ញុំដែលជាអតីតយោធាខ្មែរក្រហម និងធ្លាប់ឈរជើងនៅទីនេះផ្ទាល់។

# វ៉ាន់ វឿន
## អតីតពេទ្យស្រុកពាមព្រួសក្នុងរបបខ្មែរក្រហម

*រី លក្ខិណា*



*វ៉ាន់ វឿន អាយុ៦១ឆ្នាំ នៅក្រោមផ្ទះរបស់គាត់ស្ថិតនៅ ភូមិព្រែក ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ វ៉ាន់ វឿន ភេទប្រុស មានអាយុ ៦១ ឆ្នាំ។ ខ្ញុំគឺជាជនជាតិភាគតិចជនខ្ទងភ្នំ។ ខ្ញុំមានស្រុកកំណើតនៅភូមិវាលវែង ឃុំត្រពាំងពង្រ ស្រុកភ្នំក្រវាញ ដែលបច្ចុប្បន្នស្រុកវាលវែង ខេត្តពោធិ៍សាត់។ សព្វថ្ងៃខ្ញុំរស់នៅភូមិព្រែក ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ប្រពន្ធរបស់ខ្ញុំឈ្មោះ ហ សាវ៉ាន់។ ខ្ញុំមានកូនចំនួនបួននាក់ ប្រុសចំនួនពីរនាក់ និងស្រីចំនួនពីរនាក់។ ឪពុករបស់ខ្ញុំឈ្មោះ សុខ វ៉ាន់ និងម្តាយឈ្មោះ ប្រាញ់ សុខ។

កាលពីខ្ញុំនៅតូចចាស់ៗ នៅក្នុងភូមិបានដំណាលមកថា នៅសម័យអាណានិគមនិយមបារាំង មានព្រានព្រៃមកពីខេត្តពោធិ៍សាត់ និងខេត្តកំពង់ស្ពឺ បានដើរបរបាញ់សត្វ និងស្វែងរកខ្លឹមចន្ទន៍ក្រឹស្នានៅក្នុងព្រៃរហូតមកដល់ភូមិវាលវែង និងតំបន់អូរសោម។ ព្រានព្រៃទាំងនោះបានចូលព្រៃម្តងៗ មានរយៈពេលប្រាំទៅប្រាំមួយខែ ហើយមានព្រានព្រៃមួយចំនួនបានជួបកូនក្រមុំជនជាតិជនខ្ទងភ្នំនៅភូមិវាលវែង ក៏បានស្រឡាញ់គ្នា និងបានរៀបការជាប្តីប្រពន្ធទៀតផង។ មុននឹងរៀបការឪពុកម្តាយខាងស្រីបង្គាប់ឲ្យសង់ផ្ទះឈើ ប្រក់ស្លឹកសោម ចងជាមួយវល្លិ ឬផ្តៅ។

កាលពីដំនាន់ដើមជនជាតិជនខ្ទងភ្នំបានប្រកបរបរធ្វើចម្ការ គឺដាំស្រូវវិលជុំ។ ជនជាតិជនខ្ទងភ្នំរស់នៅភូមិវាលវែង និងតំបន់អូរសោម មានជំនឿលើព្រះពុទ្ធសាសនា និងបានទៅវត្តថ្វាយបង្គំព្រះសង្ឃដូចបងប្អូនខ្មែរទូទៅដែរ។ បងប្អូនជនជាតិជនខ្ទងភ្នំក៏បានគោរពនិងមានជំនឿលើអារក្ខអ្នកតាថែមទៀត។

បងប្អូនជនជាតិជនខ្ទងភ្នំនៅភូមិវាលវែង និងតំបន់អូរសោមទៅផ្សារទិញសម្ភារម្តងៗ គឺត្រូវដើរថ្មើរជើងរយៈពេលមួយសប្តាហ៍ទើបដល់ផ្សារក្រវាញ។ អ្នកភូមិខ្លះដែលមានដំរី ក៏បានជិះដំរី។ នៅពេលណាដែលបរបាញ់សត្វព្រៃបានជនជាតិជនខ្ទងភ្នំមិនបានលក់ដូរទេ គឺកាប់ចែកគ្នាហូបៗ ចំពោះខ្លឹមច័ន្ទក្រឹស្នាដែលរកបាន ជនជាតិភាគតិចជនខ្ទងភ្នំបានយកទៅលក់នៅប្រទេសថៃ និងទិញអំបិលត្រឡប់យកមកផ្ទះវិញ។ អំបិល គឺមានសារសំខាន់ណាស់ ពីព្រោះត្រូវទុកហូបនៅរដូវវស្សាពេលមានភ្លៀងធ្លាក់ច្រើន និងទឹកជន់មិនអាចធ្វើដំណើរបាន។ នៅពេលឈឺថ្កាត់ មិនមានមន្ទីរពេទ្យទេ គឺជនជាតិភាគតិចជនខ្ទងភ្នំព្យាបាលតាមរបៀបផ្សំថ្នាំបុរាណ។ នៅពេលខ្ញុំឈឺគ្រុនញាក់ ចាស់ៗនៅភូមិហៅថា គ្រុនអណ្តើក។ ម្តាយខ្ញុំបានយកសម្បកដើមថ្កូវ និងស្លឹកម្លូទុំដែលជ្រុះមកដុតកម្ទេចរួចយកមកត្រាំទឹកឲ្យខ្ញុំផឹក។ ពេលខ្លះខ្ញុំបានជាសះស្បើយពីជំងឺ។

កាលពីតូចខ្ញុំរៀនសូត្របានតិចប៉ុណ្ណោះ គឺនៅមុនឆ្នាំ១៩៧០ ខ្ញុំបានរៀនជាមួយលោកគ្រូឈ្មោះ សំ បានរយៈពេលប្រាំមួយខែ។ លោកគ្រូសំត្រូវបានខ្មែរក្រហមសម្លាប់ នៅពេលគាត់ធ្វើដំណើរទៅស្រុកភ្នំក្រវាញ។ ខ្មែរក្រហមចោទថា លោកគ្រូ សំ គឺជា សេ.អ៊ី.អា ពីព្រោះពេលធ្វើដំណើរគាត់ចូលចិត្តដាក់សៀវភៅ ប៊ិក ជាប់នឹងខ្លួន។ ក្រោយមកខ្ញុំបានទៅរស់នៅជាមួយឪពុកចិញ្ចឹម។ ឪពុកចិញ្ចឹមបានឲ្យខ្ញុំបួស និងរៀនអក្សរបាលី។ ខ្ញុំអាចអាន និងសរសេរអក្សរបានចាប់តាំងពីពេលនោះ។

នៅពេលកើតមានរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ មានយន្តហោះទម្លាក់គ្រាប់បែកជាច្រើនហោះឆ្វែលលើភូមិ។ ពេលនោះខ្ញុំនៅក្មេងមិនបានដឹងថាអាចនឹងកើតមានគ្រោះថ្នាក់ទេ គឺខ្ញុំនៅលេងសប្បាយជាមួយក្មេងៗនៅក្នុងភូមិ។ ចាស់ៗនៅក្នុងភូមិតែងតែហាមឃាត់មិនឲ្យខ្ញុំចេញមកខាងក្រៅ គឺឲ្យខ្ញុំចូលទៅពួននៅក្នុងព្រៃរហូតដល់ពេលសភាពការណ៍ស្ងប់ស្ងាត់ទើបចាស់ៗអនុញ្ញាតឲ្យខ្ញុំចូលមកក្នុងភូមិវិញ។

នៅឆ្នាំ១៩៧៤ យោធាខ្មែរក្រហមបានជ្រើសរើសកម្លាំងយុវជន យុវនារី ក្នុងភូមិឲ្យទៅនៅក្នុងកងចល័ត និងធ្វើការងារលើកភ្លឺស្រែនិងច្រូតស្រូវពេលរដូវប្រមូលផល។ ពេលនោះខ្ញុំនៅតូចនៅឡើយ ដូច្នេះខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យឃ្វាលក្របី។ បន្ទាប់មកនៅរដូវប្រាំង ខ្ញុំត្រូវបានចាត់តាំងឲ្យលើកទំនប់នៅការដ្ឋាន និងលើកផ្លូវចាប់ពីភូមិរវៀងរហូតដល់ស្រុកពាមព្រួស។ ឈ្មោះ យាម រឹម គឺជាប្រធានកង និងដឹកនាំកងចល័តរបស់ខ្ញុំ។

នៅពេលខ្មែរក្រហមទទួលជ័យជម្នះ នៅទីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ភូមិវាលវែងស្ថិតនៅក្នុងស្រុកពាមព្រួស តំបន់៦ ភូមិភាគពាយ័ព្យ។ មន្ទីរស្រុកពាមព្រួស ស្ថិតនៅក្នុងភូមិទួលគ្រួស ដែលសព្វថ្ងៃស្ថិតនៅភូមិស្ទឹងថ្មី ឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ចំណែកមន្ទីរតំបន់ ៦ ស្ថិតនៅក្នុងភូមិរវៀង ស្រុកលាច ដែលសព្វថ្ងៃស្ថិតនៅក្នុងស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការងារនៅក្នុងកងចល័តរហូតដល់ឆ្នាំ១៩៧៦។

ថ្ងៃមួយខ្ញុំមានជំងឺ និងត្រូវបានបញ្ជូនដេកពេទ្យនៅមន្ទីរពេទ្យស្រុកពាមព្រួស។ សំណាងល្អ ខ្ញុំបានជួបម្តាយមីងខ្ញុំធ្វើការនៅមន្ទីរពេទ្យនោះ។ គាត់កាន់ខាងសេដ្ឋកិច្ច ដោយទទួលខុសត្រូវខាងឃ្លាំងថ្នាំ និងឃ្លាំងអង្ករ។ បន្ទាប់ពីខ្ញុំបានជាសះស្បើយ ម្តាយមីងរបស់ខ្ញុំមិនឲ្យខ្ញុំត្រឡប់មកអង្គភាពកងចល័តវិញទេ គឺគាត់ឲ្យខ្ញុំនៅធ្វើការនៅមន្ទីរពេទ្យស្រុកពាមព្រួស ខាងផ្នែកសេដ្ឋកិច្ចឃ្លាំងថ្នាំពេទ្យជាមួយគាត់។ នៅពេលនោះមានអ្នកជំងឺគ្រុនចាញ់ច្រើនណាស់។ ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យដើរចាប់មូសដែកគោលនៅពេលយប់។ អង្គការបានចាត់តាំងឲ្យចាប់មូសដែកគោល ដើម្បីយកមកពិសោធន៍សម្រាប់ផលិតថ្នាំគ្រុនចាញ់។ នៅខណៈពេលដែលខ្ញុំធ្វើការនៅមន្ទីរពេទ្យស្រុកពាមព្រួស ធ្លាប់បានឃើញអ្នកជំងឺហើមច្រើន ពីព្រោះអ្នកជំងឺទាំងនោះខ្វះជីវជាតិ និងអាហារ។ ពេលប្រជាជនមានជំងឺហើមមកសម្រាកព្យាបាលនៅ

មន្ទីរពេទ្យ គ្រូពេទ្យខ្មែរក្រហមបានផ្តល់ថ្នាំអាចម៍ទន្សាយឲ្យអ្នកជំងឺទាំងនោះលេប។ ប្រធានមន្ទីរពេទ្យស្រុកពេលនោះមានឈ្មោះ នារីស៊ឹម ចំណែកគណៈស្រុកពាមព្រួសឈ្មោះ តាកើន។

នៅឆ្នាំ១៩៧៧ ប្រជាជនដែលរស់នៅភូមិវាលវែងត្រូវបានជម្លៀសមកនៅស្រុកលាចទាំងអស់។ ភូមិវាលវែង និងតំបន់អូរសោមមិនមានប្រជាជនរស់នៅទេ គឺមានតែយោធាខ្មែរក្រហមបោះទីតាំងប៉ុណ្ណោះ។ ចំណែកស្រុកពាមព្រួស និងតំបន់៦ ត្រូវបានខ្មែរក្រហមរំលាយចោល។ ខ្ញុំត្រូវបានខ្មែរក្រហមផ្លាស់ឲ្យទៅធ្វើជាពេទ្យកងទ័ពប្រចាំការនៅព្រំដែនខ្មែរ-ថៃ ដែលមានឈ្មោះ លឿម គឺជាប្រធានពេទ្យយោធាតំបន់ពោធិ៍សាត់។ ពេលនោះអគ្គភាពពេទ្យរបស់ខ្ញុំប្រចាំការនៅម្តុំថ្មដាធំ និងនៅស្ទឹងមេទឹក។ ខ្ញុំធ្វើការនៅអគ្គភាពពេទ្យយោធារហូតដល់កងទ័ពវៀតណាមវាយចូលមកប្រទេសកម្ពុជានៅឆ្នាំ១៩៧៩។ បន្ទាប់មកខ្ញុំត្រឡប់មកភូមិព្រែកស្រុកលាច ដើម្បីស្វែងរកម្តាយ និងក្រុមគ្រួសាររបស់ខ្ញុំ។ ក្រោយមកខ្ញុំបានរៀបការ និងបន្តរស់នៅភូមិព្រែក ឃុំសំរោង ស្រុកភ្នំក្រវាញ រហូតដល់សព្វថ្ងៃ។





ផ្លូវពីស្រុកភ្នំក្រវាញ ទៅស្រុកវាលវែង ក្នុងខេត្តពោធិ៍សាត់។ (ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)













# ការិយាល័យ ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ធនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល៖

truthchenda.s@dccam.org

សូមអរគុណ!












# សាលក្រមសំណុំរឿង០០២/០២

## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

(តពីលេខមុន)

### ៤.៣.២. សំអាងច្បាប់

#### ៤.៣.២.១. *អត្ថិភាពនៃជម្លោះប្រដាប់អាវុធជាអន្តរជាតិ*

**៣៣៦.** *ផ្អែកតាមភស្តុតាងដែលបានរៀបរាប់ខាងលើ អង្គជំនុំជម្រះយល់ឃើញថា ជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យវៀតណាមបានកើតឡើងចាប់ពីខែឧសភា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ ទោះបីជាយ៉ាងណាដីកាដំណោះស្រាយបានចោទប្រកាន់ថា ជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យវៀតណាត បានកើតឡើងនៅពេញមួយរបបនៃកម្ពុជាប្រជាធិបតេយ្យ ពោលគឺចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៧៥ ខែមករា ឆ្នាំ១៩៧៩។ យ៉ាងណាមិញអង្គជំនុំជម្រះមិនអាចជឿឲ្យហួសពីវិមតិសង្ស័យបានថា ជម្លោះប្រដាប់អាវុធជាអន្តរជាតិរវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាមបានកើតឡើងនៅក្នុងខែមេសា ឆ្នាំ១៩៧៥ ពោលគឺមុនពេលវៀតណាមខាងជើងវាយកាន់កាប់ក្រុងព្រៃនគរនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៥ នោះទេ។ ជម្លោះលើកដំបូងរវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាមបានកើតឡើនៅខែឧសភា ឆ្នាំ១៩៧៥ នៅដែនទឹក មុំតំបន់កោះដែលមានជម្លោះរវាងប្រទេសកម្ពុជានិងវៀតណាម។*

*ជម្លោះជាបន្តបន្ទាប់ដែលបានប៉ះទង្គិចគ្នា នៅតាមព្រំដែននិងការវាយប្រយុទ្ធចូលក្នុងទឹកដីគ្នាទៅវិញទៅមករវាងកម្ពុជានិងវៀតណាមបានកើតឡើងពីខែឧសភា ឆ្នាំ១៩៧៥ រហូតដល់ចុងរបបកម្ពុជាប្រជាធិបតេយ្យ។ សេចក្តីសន្និដ្ឋាននេះមិនពាក់ព័ន្ធនិងបញ្ហាដែលថាកម្ពុជាប្រជាធិបតេយ្យនិងវៀតណាមមិនបានស្គាល់ស្ថានភាពសង្គ្រាមនេះ រហូតដល់ប្រទេសទាំងពីរបានកាត់ផ្តាច់ចំណងការទូតរវាងគ្នានៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ នោះទេ។*

#### ៤.៣.២.២. ឋានៈជា «បុគ្គលដែលទទួលបានការការពារ» ក្រោមអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩

**៣៣៧.** *ចំពោះបទឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់អនុលោមតាមមាត្រា៦ នៃច្បាប់ អ.វ.ត.ក. ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខស-២១ និងមន្ទីរសន្តិសុខអូរកន្សែង អង្គជំនុំជម្រះបានពិនិត្យលើឋានៈរបស់ជនរងគ្រោះនិងសេចក្តីសន្និដ្ឋាននៅផ្នែកដែលពាក់ព័ន្ធនៅក្នុងសាលក្រមនេះ។ ត្រង់ចំណុចនេះអង្គជំនុំជម្រះកត់សម្គាល់ថា ទាក់ទងនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នៅមន្ទីរសន្តិសុខអូរកន្សែង អង្គជំនុំជម្រះមិនអាចជឿឲ្យហួសពីវិមតិសង្ស័យថា ជនជាតិចារ៉ាយ គឺជា«បុគ្គលដែលត្រូវទទួលបានការការពារ» ស្របតាមខ្លឹមសារនៃអនុសញ្ញាទីក្រុងហ្សឺណែវនោះទេ។ ផ្ទុយទៅវិញទាក់ទិនបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នៅក្នុងមន្ទីរសន្តិសុខស-២១ អង្គជំនុំជម្រះជឿជាក់ថាជនរងគ្រោះពីបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទាំងនេះ គឺជនស៊ីវិលឬឈ្លើយសឹកវៀតណាម ហេតុដូច្នេះ ពួកគេគឺជាបុគ្គលដែលត្រូវទទួលបានការការពារ ស្របតាមគោលបំណងនៃអនុសញ្ញាទីក្រុងហ្សឺណែវ។ ហេតុដូច្នេះ អង្គជំនុំជម្រះនឹងពិចារណាលើលក្ខខណ្ឌសេសសល់សម្រាប់តែអង្គហេតុពាក់ព័ន្ធនិងមន្ទីរសន្តិសុខ ស-២១ប៉ុណ្ណោះ។*

### ៤.៣.២.៣. ទំនាក់ទំនងរវាងអំពើរបស់ជនជាប់ចោទ និងជម្លោះប្រដាប់អាវុធ

**៣៣៨.** *អង្គជំនុំជម្រះរកឃើញថា បទឧក្រិដ្ឋដែលបានប្រព្រឹត្តទៅលើបុគ្គលដែលត្រូវបានការការពារនៅមន្ទីរសន្តិសុខស-២១ មានទំនាក់ទំនងគ្នាយ៉ាងខ្លាំងជាមួយនឹងជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យ វៀតណាម។ ត្រង់ចំណុចនេះ អង្គជំនុំជម្រះពិចារណាដូចតទៅ៖ អ្នកជាប់ឃុំជនជាតិវៀតណាម បង្កើតបានជាក្រុមជនបរទេសធំជាងគេ ដែលត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខ ស-២១ ហើយចំនួនអ្នកជាប់ឃុំជនជាតិវៀតណាមបានកើនឡើងនៅពេលដែលជម្លោះរវាងរដ្ឋទាំងពីរកាន់តែកើតឡើងខ្លាំង។ រូបថតអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ ដែលនៅសេសសល់បានបង្ហាញពីអ្នកជាប់ឃុំស្លៀកពាក់ឯកសណ្ឋានកងទ័ពវៀតណាម អ្នកជាប់ឃុំជនជាតិវៀតណាមត្រូវបានគេបញ្ជាឲ្យអានចម្លើយសារភាពដែលបានរៀបចំរួចជាស្រេច។ ក្នុងចម្លើយសារភាព ពួកគេត្រូវបានបង្ខំឲ្យឆ្លើយថា ពួកគេបានចូលនៅក្នុងទឹកដីប្រទេសកម្ពុជាដើម្បីមកស៊ើបការណ៍និងឈ្លានពានកម្ពុជា និងចម្លើយសារភាពទាំងនោះត្រូវបានយកទៅផ្សព្វផ្សាយតាមវិទ្យុ (កម្មវិធីព័ត៌មានក្នុងស្រុកនៃវិទ្យុភ្នំពេញ)។ ចម្លើយសារភាពទាំងនេះក៏ត្រូវបានគេយកទៅប្រើប្រាស់នៅក្នុងឯកសារបោះពុម្ពផ្សាយរបស់កម្ពុជាប្រជាធិបតេយ្យ ដូចជា សៀវភៅខ្មៅដែលបានលើកឡើងខាងលើ និងសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាល ដើម្បីយកធ្វើជាភស្តុតាងពាក់ព័ន្ធនឹងការឈ្លានពានរបស់វៀតណាមនៅក្នុងប្រទេសកម្ពុជា ចម្លើយសារភាពទាំងនោះរួមមានចម្លើយសារភាពរបស់សមាជិកកងកម្លាំងប្រដាប់អាវុធវៀតណាម ដូចជា មេបញ្ជាការវរសេនីយ៍ឯក អនុសេនីយ៍ទោ និងពលទាហានផងដែរ។ ជាចុងក្រោយ រូបថតនិងខ្សែភាពយន្តអំពីអ្នកជាប់ឃុំជនជាតិវៀតណាមដែលត្រូវបានគេជាប់ខ្លួនក្នុងឯកសណ្ឋានជាកងទ័ពត្រូវបានបញ្ចាំងបង្ហាញដល់បុគ្គលិកមន្ទីរសន្តិសុខ ស-២១ នៅក្នុងវគ្គអប់រំរៀនសូត្រ ដើម្បីអបអរសាទរខួបជ័យជម្នះថ្ងៃទី១៧ ខែមេសា។*



*កងទ័ពវៀតណាមដែលត្រូវបានយោធាខ្មែរក្រហមចាប់ខ្លួន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

### ៤.៣.២.៤. ការដឹងឮរបស់ជនជាប់ចោទ

**៣៣៩.** *អង្គជំនុំយល់ឃើញថា ជនជាប់ចោទទាំងពីរនាក់បានដឹងអំពីជម្លោះប្រដាប់អាវុធជាមួយនឹងប្រទេសវៀតណាម។ ត្រង់ចំណុចនេះអង្គជំនុំជម្រះពិចារណាទៅលើតួនាទីរបស់ នួន ជា សមាជិកប្រតិភូរបស់កម្ពុជាប្រជាធិបតេយ្យដែលបានចូលរួមក្នុងការបំពេញទស្សនកិច្ចទៅទីក្រុង ហាណូយ នៅក្នុងខែមិថុនា ឆ្នាំ១៩៧៥ ដើម្បីពិភាក្សាពីជម្លោះនៅតាមព្រំដែនជាមួយនឹងមេដឹកនាំវៀតណាម ផ្ទៀន វ៉ាន់លិញ ហេតុដូច្នេះគាត់បានដឹងអំពីជម្លោះប្រដាប់អាវុធជាមួយវៀតណាមតាំងពីដំបូងមកម្ល៉េះ។ ពាក់ព័ន្ធនឹងការដឹងឮរបស់ ខៀវ សំផន ពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធជាមួយនឹងវៀតណាម អង្គជំនុំ*

ជម្រះពិចារណាដូចតទៅ៖ ក្នុងអំឡុងឆ្នាំ១៩៧៥ ខៀវ សំផន បានពន្យល់នៅពេលក្រោយមកថាគាត់ «ត្រូវតែដឹង ដើម្បីអាចជម្រាប [អំពីការពិភាក្សាបញ្ហាការពារជាតិនិងវៀតណាម] ជូនទៅអ្នកការទូតៗ ជាក់ស្តែង ខៀវ សំផន ពិតជាបានបំពេញមុខងារខាងការទូត គាត់មិនត្រឹមតែបានបំពេញទស្សនកិច្ចនៅប្រទេសវៀតណាម ក្នុងខែសីហា និងខែកញ្ញា ឆ្នាំ១៩៧៥ ដើម្បីចូលរួមអបអរសាទរខួបលើកទី៣០ នៃការចាប់ផ្តើមចលនាទាមទារឯករាជ្យរបស់វៀតណាមប៉ុណ្ណោះទេ ប៉ុន្តែគាត់ក៏បានធ្វើដំណើរទៅបំពេញទស្សនកិច្ចនៅក្នុងប្រទេសចិន និងប្រទេសកូរ៉េខាងជើងនៅក្នុងឆ្នាំ១៩៧៥ ផងដែរ។ ខៀវ សំផន ទទួលបានរបាយការណ៍អំពីបញ្ហាការពារជាតិដូចតទៅ៖ គាត់បានចូលរួមនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលក្នុងចំណោមនោះរួមមាន កិច្ចប្រជុំនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៧៥ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ និងនៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦ ដែលក្នុងអំឡុងពេលនោះមានការពិភាក្សាអំពីបញ្ហាជម្លោះជាមួយនឹងវៀតណាម ព្រមទាំងជាមួយនឹងការខិតខំព្យាយាមចរចារលើបញ្ហាព្រំដែនផងដែរ។ ចុងក្រោយ នៅក្នុងសេចក្តីថ្លែងការណ៍ពេលក្រោយ មកទៀត ខៀវ សំផន បានទទួលស្គាល់ថា ជម្លោះប្រដាប់អាវុធជាមួយនឹងវៀតណាមបានកើតឡើងនៅក្នុងឆ្នាំ១៩៧៥។ អង្គជំនុំជម្រះសន្និដ្ឋានដែលសមហេតុផលតែមួយគត់ដែលអាចទាញបាននោះគឺថា ខៀវ សំផន មិនគួរមិនបានដឹងពីអំពីហេតុការណ៍ជម្លោះប្រដាប់អាវុធជាមួយនឹងវៀតណាមដែលបានកើតឡើងចាប់ពីខែឧសភា ឆ្នាំ១៩៧៥ តមកនោះឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន បានដឹងពីជម្លោះប្រដាប់អាវុធជាមួយនឹងវៀតណាម តាំងពីដំបូងមកម្ល៉េះ។

**៣៤០.** អង្គជំនុំជម្រះយល់ឃើញថា នួន ជា បានដឹងពីឋានៈដែលត្រូវទទួលបានការការពាររបស់ជនរងគ្រោះនៅមន្ទីរសន្តិសុខស-២១។ ត្រង់ចំណុចនេះអង្គជំនុំជម្រះបានពិចារណាដូចតទៅ៖ នួន ជា គឺជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ដែលមានតួនាទីគ្រប់គ្រងមន្ទីរសន្តិសុខស-២១។ នួន ជា បានចូលរួមយ៉ាងសំខាន់នៅក្នុងបញ្ហាកិច្ចការយោធាៗ ជាងនេះទៅទៀត នួន ជា បានអនុវត្តតួនាទីយ៉ាងសកម្មនៅក្នុងកិច្ចការមន្ទីរសន្តិសុខស-២១ ព្រោះគាត់បានផ្តល់ការណែនាំ និងការសម្រេចពាក់ព័ន្ធនឹងអ្នកត្រូវបានចាប់ខ្លួន ហើយចាប់ពីខែសីហា ឆ្នាំ១៩៧៧ គាត់មានតួនាទីជាអ្នកគ្រប់គ្រងពីលើ ឌុច នៅមន្ទីរសន្តិសុខ ស-២១។ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន បានចូលរួមតិចតួចនៅក្នុងកិច្ចការគ្រប់គ្រងមន្ទីរសន្តិសុខ ដែលស្ថិតនៅក្នុងមន្ទីរសន្តិសុខ ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០២/០២ ក៏ដោយ ប៉ុន្តែគាត់ក៏បានដឹងអំពីឋានៈរបស់ជនរងគ្រោះដែលទទួលបានការការពារនៅក្នុងមន្ទីរសន្តិសុខ ស-២១ ផងដែរ។ ត្រង់



កងទ័ពវៀតណាមដែលត្រូវបានយោធាខ្មែរក្រហមចាប់ខ្លួន។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចំណុចនេះអង្គជំនុំជម្រះបានពិចារណាដូចតទៅ៖ ខៀវ សំផន ពុំមែនត្រឹមតែស្ថិតនៅក្នុងចំណោមសមាជិក ប.ក.ក. មួយក្រុមតូចដែលបានទទួលព័ត៌មានពេញលេញ ដោយសារតែគាត់គឺជាសមាជិកគណៈកម្មាធិការមជ្ឈិម និងមន្ទីរ៨៧០ ប៉ុណ្ណោះទេ ប៉ុន្តែគាត់ក៏មានមុខតំណែងពិសេសនៅក្នុងជួរបក្ស និងបានចូលរួមក្នុងកិច្ចប្រជុំជាច្រើនរបស់ គណៈកម្មាធិការអចិន្ត្រៃយ៍។ ទំនងជានៅថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ខៀវ សំផន បានជួបជាមួយនឹង កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលជាប្រធានមន្ទីរ ស-២១ មិនគួរតក់ស្លុតចំពោះការវាយប្រហាររបស់វៀតណាមចូលក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យនោះទេ ចម្លើយសារភាព រូបថត និងខ្សែភាពយន្តអំពីឈ្លើយសឹកវៀតណាម ត្រូវបានយកទៅប្រើប្រាស់យ៉ាងទូលំទូលាយក្នុងគោលបំណងឃោសនានិងអប់រំរៀនសូត្រ ហេតុដូច្នេះ បញ្ហានេះមិនគួរផុតពីការចាប់អារម្មណ៍របស់មេដឹកនាំជាន់ខ្ពស់ ប.ក.ក. ដូចជាខៀវ សំផន ដែលមានវត្តមាននៅក្នុងវគ្គអប់រំរៀនសូត្រនយោបាយច្រើន ហើយខ្លួនគាត់ផ្ទាល់ក៏ធ្លាប់ថ្លែងសុន្ទរកថាជាច្រើនទាក់ទងនឹងការប្រុងប្រយ័ត្នខ្ពស់ចំពោះខ្មាំងវៀតណាម។

## ៥ រចនាសម្ព័ន្ធរដ្ឋបាល

**៣៤១.** ឯកសារសំខាន់ៗស្ដីពីការគ្រប់គ្រងរបបកម្ពុជាប្រជាធិបតេយ្យ រួមមាន រដ្ឋធម្មនុញ្ញកម្ពុជា ប្រជាធិបតេយ្យ និងលក្ខន្តិកៈ ប.ក.ក.។ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យបានផ្ដល់អំណាចសំខាន់ៗដល់ស្ថាប័ននីតិប្បញ្ញត្តិដែលត្រូវបានហៅថាសភាតំណាងប្រជាជន ប៉ុន្តែជាក់ស្ដែងអំណាចមិនត្រូវបានផ្ដល់ឲ្យស្ថាប័ននេះបានពេញលេញនោះទេ។ ផ្ទុយទៅវិញ លក្ខន្តិកៈ ប.ក.ក. បានផ្ដល់អំណាចធ្វើសេចក្ដីសម្រេចទៅឲ្យសមាជិក ប.ក.ក. ដែលអំណាចនេះត្រូវបានកម្រិតដោយប្រព័ន្ធត្រួតពិនិត្យជាច្រើនថ្នាក់។ ដោយសារ ប.ក.ក. ជាបក្សនយោបាយតែមួយគត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយរាល់សេចក្ដីសម្រេចទាំងអស់ពាក់ព័ន្ធនឹងការគ្រប់គ្រងនិងកងកម្លាំងយោធាត្រូវបានធ្វើឡើងដោយគណៈកម្មាធិការមជ្ឈិម ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ថ្នាក់ដឹកនាំភូមិភាគក្រសួង និងកងកម្លាំងយោធានោះៗ ហេតុដូច្នេះ ប.ក.ក. គឺជារចនាសម្ព័ន្ធរដ្ឋបាលកម្ពុជាដ៏សំខាន់បំផុតពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩។

### ៥.១ រចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា

**៣៤២.** ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ រចនាសម្ព័ន្ធប្រតិបត្តិការជាក់លាក់របស់ ប.ក.ក. ត្រូវបានរក្សាការសម្ងាត់។ នៅដំណាក់កាលដំបូងនៃការវិវឌ្ឍរបស់បក្ស ការសម្ងាត់មានសារសំខាន់ចំពោះការរស់រានរបស់បក្សដែលដំណើរការជាចលនាបដិវត្តន៍សម្ងាត់។ បើទោះបីជាក្រោយចូលកាន់អំណាចក្នុងឆ្នាំ១៩៧៥ ហើយក៏ដោយ ប.ក.ក. នៅតែបន្តអនុវត្តកិច្ចការផ្ទៃក្នុងជាសម្ងាត់និងលាក់កំបាំង ដើម្បីការពារខ្លួនពីខ្មាំងតាមការសន្មតខាងក្រៅ។ អត្តិភាពរបស់ ប.ក.ក. និងថ្នាក់ដឹកនាំបក្ស ត្រូវបានបង្ហាញជាចំហឲ្យសាធារណជននៅកម្ពុជា (ក្រៅពីសមាជិក ប.ក.ក.) និងថ្នាក់ដឹកនាំបក្ស ត្រូវបានបង្ហាញជាចំហឲ្យសាធារណជននៅកម្ពុជា (ក្រៅពីសមាជិក ប.ក.ក.) និងពិភពលោកខាងក្រៅបានស្គាល់នៅក្នុងពិធីគម្រប់ខួបលើកទី១៧ របស់បក្សក្នុងខែកញ្ញា ឆ្នាំ១៩៧៧។ ហេតុនេះហើយ មានព័ត៌មានអំពីរចនាសម្ព័ន្ធថ្នាក់ដឹកនាំតិចតួចប៉ុណ្ណោះ ដែលជាប្រជាជនសាមញ្ញអាចដឹងបាន ដោយសារពួកគាត់ត្រូវគោរពតាមសេចក្ដីសម្រេចរបស់ «អង្គការ» ដោយគ្មានលក្ខខណ្ឌ ហើយអង្គការដែលជាស្ថាប័នអនាមិកនេះត្រូវបានមើលឃើញថាមានអំណាចគ្រប់គ្រងសង្គមទាំងមូល។ ក្នុងករណីខ្លះ កម្មាភិបាលថ្នាក់ក្រោមមានការយល់ដឹងតិចតួចអំពីការចាត់ចែងអំណាចនៅក្នុង ប.ក.ក.។ ប៉ុន្តែជារួម ភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះអាចឲ្យអង្គជំនុំជម្រះពិពណ៌នាអំពីមាគ៌ាចាត់តាំងរបស់ ប.ក.ក. នៅក្នុងអំឡុងពេលពាក់ព័ន្ធ។

**៣៤៣.** *រចនាសម្ព័ន្ធរដ្ឋបាលរបស់ ប.ក.ក. ត្រូវបានបង្កើតឡើងជាផ្លូវការលើកដំបូងនៅក្នុងលក្ខន្តិកៈដែលត្រូវបានអនុម័តដោយសន្និបាតបក្សលើកទីមួយ នៅក្នុងខែកញ្ញា និងខែតុលា ឆ្នាំ១៩៦០ ដែលនៅពេលនោះបក្សមានឈ្មោះថា «បក្សពលករកម្ពុជា»។ លក្ខន្តិកៈបក្សទីពីរ ទំនងជាត្រូវបានអនុម័តនៅក្នុងសន្និបាតបក្សលើកទីបី ក្នុងអំឡុងខែកញ្ញា ឆ្នាំ១៩៧១។ លក្ខន្តិកៈបក្សមួយទៀតត្រូវបានអនុម័តនៅក្នុងសន្និបាតបក្សលើកទីបួន នៅក្នុងខែមករា ឆ្នាំ១៩៧៦។ លក្ខន្តិកៈបក្សទាំងអស់នោះមានខ្លឹមសារស្រដៀងគ្នា យ៉ាងហោចណាស់ចំពោះបញ្ហាពាក់ព័ន្ធនិងរចនាសម្ព័ន្ធផ្ទៃក្នុងនិងឋានានុក្រមរបស់ ប.ក.ក.។*

### ៥.១.១. សន្និបាតបក្ស

**៣៤៤.** *ជាបញ្ហាបឋម អង្គជំនុំជម្រះកត់សម្គាល់ថា នៅចំពោះមុខអង្គជំនុំជម្រះមានលក្ខន្តិកៈ ប.ក.ក. ឆ្នាំ១៩៧១ និងឆ្នាំ១៩៧៦។ លក្ខន្តិកៈឆ្នាំ១៩៧៦ នៅក្នុងសំណុំរឿង គឺជាលក្ខន្តិកៈពេញលេញដែលជាសំណៅវាយអង្គលីលេខនៃឯកសារបង្កើត ប.ក.ក. ហើយសាក្សីជាច្រើន រួមទាំង ឌុច និង នួន ជា បានបញ្ជាក់ពីយថាភាពនៃលក្ខន្តិកៈនេះផងដែរ។ លក្ខន្តិកៈបក្សឆ្នាំ១៩៧៦ នៅក្នុងសំណុំរឿងមានទម្រង់ជាកំណត់ហេតុសរសេរដោយដៃ ដែលបានបង្ហាញថាជា «សេចក្ដីព្រាង» ហើយលក្ខន្តិកៈបក្សនេះត្រូវបានសរសេរចម្លងដោយដៃ ចុះខែកក្កដា ឆ្នាំ១៩៧២។ បើទោះបីជាលក្ខន្តិកៈបក្សឆ្នាំ១៩៧៦ បានប្រើប្រាស់ពាក្យពេចន៍ជាច្រើនដូចគ្នាទៅនឹងលក្ខន្តិកៈបក្សឆ្នាំ១៩៧១ ក៏ដោយប៉ុន្តែអត្តសញ្ញាណរបស់អ្នកសរសេរកំណត់ហេតុឆ្នាំ១៩៧២ ដែលមានបញ្ចូលសេចក្ដីព្រាងលក្ខន្តិកៈបក្សឆ្នាំ១៩៧១ មិនត្រូវបានគេស្គាល់នោះទេ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះនឹងប្រើប្រាស់លក្ខន្តិកៈបក្សឆ្នាំ១៩៧១ ដោយប្រុងប្រយ័ត្ន ហើយអង្គជំនុំជម្រះនិងលើកយកខ្លឹមសារនៃកំណត់ហេតុនេះមកធ្វើជាសំអាងហេតុ តែក្នុងករណីដែលខ្លឹមសារទាំងនោះត្រូវបានគាំទ្រដោយភស្តុតាងដទៃទៀតប៉ុណ្ណោះ។*

**៣៤៥.** *លក្ខន្តិកៈបក្សឆ្នាំ១៩៧១ និងឆ្នាំ១៩៧៦ បានកំណត់អំពីមាគ៌ាទាំងឡាយដែលជាមូលដ្ឋាននៃប្រកាសបង្កើតបក្សជាផ្លូវការ។ «សិទ្ធិអំណាចធំជាងគេបំផុតសម្រាប់ទូទាំងប្រទេស» ត្រូវបានប្រគល់ឲ្យមហាសន្និបាត ឬសន្និបាតបក្ស។ ទោះបីជាយ៉ាងណា សន្និបាតបក្សត្រូវរៀបចំធ្វើរៀងរាល់បួនឆ្នាំម្ដង ហើយនៅក្នុងចន្លោះពេលនៃសន្និបាតបក្សទាំងនោះ គណៈកម្មាធិការមជ្ឈិម គឺជាអង្គការប្រតិបត្តិការខ្ពស់ជាងគេនៅក្នុងប្រទេស។ តួនាទីរបស់សន្និបាតគឺដើម្បី «កំណត់មាគ៌ានយោបាយ និងលក្ខន្តិកៈរបស់បក្ស» និងជ្រើសរើសតាំងសមាជិកគណៈកម្មាធិការមជ្ឈិម។ ក្រៅពីសន្និបាតបក្សលើកទីមួយ, ទីពីរ,ទីបី និងទីបួន ដែលបានលើកឡើងខាងលើ សន្និបាតលើកទីប្រាំត្រូវបានកោះប្រជុំនៅចុងឆ្នាំ១៩៧៨ ។ សន្និបាតបក្សឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៨ មានប្រជាជនចូលរួមប្រជុំរាប់រយនាក់ ក្នុងនោះមានតំណាងមកពីគ្រប់តំបន់ និងគ្រប់កងពលទាំងអស់ ក៏ដូចជាបណ្ដាសមាជិកគណៈកម្មាធិការមជ្ឈិម ប.ក.ក. ផងដែរ។*

### ៥.១.២. គណៈកម្មាធិការអចិន្ត្រៃយ៍និងគណៈកម្មាធិការមជ្ឈិម

**៣៤៦.** *ដូចកត់សម្គាល់នៅក្នុងផ្នែកខាងក្រោម គណៈកម្មាធិការអចិន្ត្រៃយ៍ គឺជាស្ថាប័នសម្រេចកំពូលរបស់ ប.ក.ក. ដែលជួបប្រជុំគ្នាជាញឹកញាប់ ដើម្បីសម្រេចរាល់បញ្ហាគោលនយោបាយនិងអនុវត្តទាំងអស់ដែលមានឥទ្ធិពលមកលើរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងបញ្ហាគោលនយោបាយនិង អនុវត្តទាំងអស់ដែលមានឥទ្ធិពលមកលើរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងកិច្ចការខាងផ្នែកស៊ីវិលនិងផ្នែកយោធា។ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ត្រូវបានជ្រើសរើសចេញពីគណៈកម្មាធិការមជ្ឈិមដែលជាស្ថាប័នមានសមាជិកច្រើនជាងនិងមិនសូវជួបប្រជុំគ្នាញឹកញាប់ដូចគណៈកម្មាធិការអចិន្ត្រៃយ៍នោះទេ។*

#### ៥.១.២.១. បញ្ហាបឋមពាក់ព័ន្ធនឹងកំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍

**៣៤៧.** *នៅចំពោះមុខអង្គជំនុំជម្រះ មានកំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍មួយចំនួនធំ រួមទាំងកំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ៣៨ (រួមទាំងសម្រង់កំណត់ហេតុ) ដែលក្នុងចំណោមនោះ កំណត់ហេតុចំនួន២៦ មាននៅក្នុងសំណុំរឿងតាំងពីមុនពេលចប់ផ្តើមកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង០០២/០២។ អង្គជំនុំជម្រះធ្លាប់បានសម្រេចរួចមកហើយថា កំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន២៦ ត្រូវបានកំណត់ថាជាការសន្មតហេតុនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ២៦ ត្រូវបានកំណត់ថា ជាការសន្មតបឋមនៃភាពអាចជឿជាក់បាន (រួមទាំងយថាភាព) ដោយសារវិធីសាស្ត្រដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រើក្នុងការវាយតម្លៃ និងការរក្សាទុកឯកសារទាំងនោះ និង/ឬដោយសារសហចៅក្រមស៊ើបអង្កេតបានយោងទៅឯកសារទាំងនោះនៅក្នុងដីកាដំណោះស្រាយ។ ទោះបីជាយ៉ាងណាក្តី នាពេលនេះអង្គជំនុំជម្រះត្រូវសន្មតថា តើឯកសារទាំងនេះមានភាពអាចជឿជាក់បានគ្រប់គ្រាន់ (រួមទាំងយថាភាព) ដើម្បីយកមកធ្វើជាមូលដ្ឋានសម្រាប់សេចក្តីសន្និដ្ឋានលើហេតុដែរឬទេ។*

**៣៤៨.** *អង្គជំនុំជម្រះរម្លឹកថា នៅពេលពិភាក្សាអំពីការទទួលយកធ្វើជាភស្តុតាងនូវឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបាន ផ្តល់ជូនតុលាការជាទម្រង់ឌីជីថលនោះ អង្គជំនុំជម្រះបានចម្រេចថា «អង្គជំនុំជម្រះជឿជាក់ថា ដំណើរការដែលត្រូវបានអនុវត្តដោយមជ្ឈមណ្ឌលឯកសារកម្ពុជា [ការប្រមូលរក្សាឯកសារ] ពុំផ្តល់នូវការយល់ឃើញសមហេតុផលណាមួយដែលថាឯកសារនានាដែលមានប្រភពចេញពីប្រភពនេះអាចស្ថិតនៅក្រោមការកែ ការក្លែង ការបន្លំ ឬក្លែងក្លាយឡើយ។ អង្គជំនុំជម្រះកត់សម្គាល់ថា បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជាបានរក្សាទុកសំណៅឯកសារដើមជាច្រើនជាពិសេស សំណៅឯកសារដើមនៃកំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍។ ហេតុដូច្នេះ ក្នុងករណីដែលមានបញ្ហាគួរឲ្យបារម្ភជាក់ស្តែងពាក់ព័ន្ធភាពត្រឹមត្រូវនៃឯកសារចម្លងដែលមានក្នុងសំណុំរឿងឬ ពាក់ព័ន្ធនឹងប្រភពឬអាចជឿជាក់បានរបស់ឯកសារណាមួយនោះ ភាគីអាចស្នើសុំពិនិត្យមើលសំណៅឯកសារដើមនៃឯកសារទាំងនេះដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានរក្សាទុក។ ដោយមិនមានភស្តុតាងបន្ថែម ឬអំណះអំណាងថ្មីពាក់ព័ន្ធនិងបញ្ហានេះ អង្គជំនុំជម្រះសន្និដ្ឋានថា ការវិភាគរបស់ខ្លួនពីលើកមុននៅតែមានសុពលភាពនិងយកសំអាងហេតុដដែលមកប្រើ ពាក់ព័ន្ធនឹងភាពអាចជឿជាក់បាននៃឯកសារភស្តុតាងទាំងនេះ។*

**៣៤៩.** *កំណត់ហេតុចំនួន ១៤ មាននៅក្នុងសំណុំរឿងតាំងពីមុនពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធីសវនាការនៅក្នុងសំណុំរឿង០០២/០២ ហើយកំណត់ហេតុទាំងនេះ*



*កងទ័ពវៀតណាមដែលត្រូវបានយោធាខ្មែរក្រហមចាប់ខ្លួន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ទទួលបានមកពីសាស្ត្រាចារ្យ Ben KIERNAN លោក CHANDLER និង លោកខៀវ កាញារីទ្ធ ដែលបច្ចុប្បន្ន គឺជារដ្ឋមន្ត្រីក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា។ លោករដ្ឋមន្ត្រី ខៀវ កាញារីទ្ធ បានលើកឡើងថា គាត់បានឃើញឯកសារទាំងនេះនៅក្នុងអគារគណៈរដ្ឋមន្ត្រីចាស់ និងនៅផ្ទះអតីតកម្មាភិបាលខ្មែរក្រហម នៅតាមបណ្តោយមហាវិថីកម្ពុជាក្រោម។ ក្រុមមេធាវីការពារក្តីទាំងពីរបានយោងទៅឯកសារទាំងនេះ ដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋាននៅក្នុងសារណាបញ្ចប់ពិភាក្សាដេញដោលរបស់ពួកគេនិងនៅក្នុងសវនាការលើការបង្ហាញឯកសារគន្លឹះមួយចំនួន។ មេធាវីការពារក្តីមិនបានលើកឡើងពីបញ្ហាថាភាពបុរាណខ្សែចង្វាក់គ្រប់គ្រងឯកសារទាំងនេះ នៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួននោះទេ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា ឯកសារទាំងនេះមានឃថាភាព និងមានតម្លៃជាភស្តុតាងខ្ពស់ដោយសារតែព្រោះវាគឺជាឯកសារនាសម័យកាលនោះ។

**៣៥០.** កំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន៩ ផ្សេងទៀតដែលមាននៅក្នុងសំណុំរឿងតាំងពីមុនកិច្ចដំណើរការនីតិវិធីសវនាការនៅក្នុងសំណុំរឿង ០០២/០២ ត្រូវបានដាក់ក្នុងសំណុំរឿងដោយប្រភពផ្សេងៗទៀត។ នៅពេលប្រៀបធៀបកំណត់ហេតុដែលមានប្រភពមកពីសាស្ត្រាចារ្យ Ben KIERNAN ជាមួយនឹងកំណត់ហេតុដែលបានមកពីប្រភពផ្សេងៗទៀត អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការប្រើប្រាស់ពាក្យពេចន៍ ភាសា និងទម្រង់នៅក្នុងឯកសារទាំងនេះ (ដូចជា ការប្រើឈ្មោះបដិវត្តន៍) មានលក្ខណៈដូចគ្នា។ ឧទាហរណ៍ កំណត់ហេតុនៃកិច្ចប្រជុំដែលមានការចូលរួមពីសំណាក់សមាជិកបក្សបានកំណត់ត្រាឈ្មោះហៅក្រៅរបស់ពួកគាត់ ដូចជា សមមិត្តលេខា (ប៉ុល ពត), សមមិត្តអនុលេខា (នួន ជា), ខៀវ (ហៅ សុន សេន), ហែម( ហៅ ខៀវ សំផន), វន (ហៅ វន វ៉េត) និង វ៉ាន់( អៀង សារី)។ ឈ្មោះហៅក្រៅទាំងនេះត្រូវបានប្រើនៅក្នុងទូរលេខនានាដែលមាននៅចំពោះមុខអង្គជំនុំជម្រះផងដែរ។ ព្រមជាមួយគ្នានោះ ឌុច ក៏បានបញ្ជាក់ថាឈ្មោះទាំងនេះ គឺជាឈ្មោះហៅក្រៅរបស់សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពីការឃោសនាបានលើកឡើងពីការកសាងប្រទេស «មហាលោតផ្លោះ»។ វាក្យស័ព្ទនេះត្រូវបានប្រើយ៉ាងច្រើននៅក្នុងទស្សនាវដ្តីទង់បដិវត្តន៍ និងការឃោសនាដែលបានផ្សព្វផ្សាយដោយកម្ពុជាប្រជាធិបតេយ្យ ដូចបានកត់ត្រានៅក្នុងកម្រងសារព័ត៌មាន FBIS ។ លើសពីនេះទៀត កំណត់ហេតុទាំងនោះត្រូវបានកត់ត្រាដោយអង្គុលីលេខ ដូចគ្នាទៅនឹងកំណត់ហេតុដែលមានប្រភពពីសាស្ត្រាចារ្យ Ben KIERNAN។ ហេតុដូច្នេះ ផ្អែកលើការវាយតម្លៃជារួមលើភស្តុតាងពាក់ព័ន្ធនឹងប្រភពឯកសារទាំងនោះ ព្រមជាមួយនឹងខ្លឹមសាររបស់វាអង្គជំនុំជម្រះយល់ឃើញថា កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ទាំង២៣ នេះមានឃថាភាពនិងមានតម្លៃជាភស្តុតាងខ្ពស់ព្រោះវាគឺជាឯកសារនាសម័យកាលនោះ។

**៣៥១.** ក្រៅពីកំណត់ហេតុទាំង២៣ ដែលបានកត់សម្គាល់ខាងលើនេះក៏មានសម្រង់កំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍មួយចំនួនដែលលោកស្រី Helen JARVIS និងលោក John QUIGILY បានទទួលដោយឡែកពីគ្នា នៅពេលដែលសម្រង់ទាំងនេះត្រូវបានដាក់បង្ហាញជាភស្តុតាងនៅចំពោះមុខតុលាការប្រជាជនបដិវត្តន៍ឆ្នាំ១៩៧៩។ សវនការនៅក្នុងតុលាការប្រជាជនបដិវត្តន៍ត្រូវបានធ្វើឡើងជាភាសាខ្មែរភាសាអង់គ្លេស និងភាសាបារាំង ហើយសម្រង់កំណត់ហេតុភាគច្រើនដែលលោកស្រី QUIGLEY និង លោកស្រី JARVIS បានទទួលមានបីភាសា។ លោកស្រី JAVIS ឬលោក QUIGLEY មិនបានប្រគល់សម្រង់កំណត់ហេតុទាំងនេះមកឲ្យអង្គជំនុំជម្រះនោះទេប៉ុន្តែយើងអាចរកឯកសារទាំងនេះបាន ដោយសារស្រង់ទាំងនេះត្រូវបានបញ្ចូលទៅក្នុងកំណត់ហេតុសវនាការនៅក្នុងឆ្នាំ១៩៧៩ ដែលបានចុះផ្សាយ។ នៅក្នុងចំណោមកំណត់ហេតុនោះ កំណត់ហេតុមួយចំនួនត្រូវបានបញ្ជាក់ដោយប្រភពភស្តុតាងផ្សេងទៀត។ ឧទាហរណ៍ យ៉ាងហោចណាស់

ផ្នែកខ្លះនៃសម្រង់កំណត់ហេតុជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៧ ពីតុលាការប្រជាជនបដិវត្តន៍ ត្រូវបានបញ្ជាក់ដោយកំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នៅថ្ងៃទី១០ ថ្ងៃទី១១ និងថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៧ ដែលលោក Christopher GOSCHA បានទទួលដូចពិភាក្សានៅផ្នែកខាងក្រោម។ ទោះបីជាយ៉ាងណា បរិបទនៃឯកសារទាំងនេះអាចរងផលប៉ះពាល់ពីបញ្ហានត្ថិភាពនៃកំណត់ហេតុដើមទាំងស្រុង និងនត្ថិភាពនៃព័ត៌មានស្ដីពីទីកន្លែងរក្សាទុកឯកសារដើមទាំងនោះ។ ក៏ប៉ុន្តែ អង្គជំនុំជម្រះបានទទួលព័ត៌មានថា កំណត់ហេតុនៃសវនាការរបស់តុលាការប្រជាជនបដិវត្តន៍ទាំងអស់ ប្រហែលជាត្រូវបានរក្សាទុកនៅក្នុងបណ្ណសាររបស់រដ្ឋាភិបាលវៀតណាម។ ទោះបីជាមានការព្យាយាមជាច្រើនលើកច្រើនសារតាមរយៈទំនាក់ទំនងការទូតក៏ដោយ ប៉ុន្តែគួរឲ្យសោកស្ដាយដែលអង្គជំនុំជម្រះមិនបានទទួលការឆ្លើយតបពីអាជ្ញាធរវៀតណាមពាក់ព័ន្ធនឹងបញ្ហានេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះនឹងពិនិត្យទៅលើសំណៅថតចម្លងនៃឯកសារទាំងនេះដោយប្រុងប្រយ័ត្ន និងពិចារណាតែទៅលើសំណៅថតចម្លងនៃឯកសារទាំងនេះដោយប្រុងប្រយ័ត្ន និងពិចារណាតែទៅលើភស្តុតាងទាំងឡាយណាដែលត្រូវបានគាំទ្រដោយកំណត់ហេតុនានាដែលទទួលបានពីប្រភពផ្សេងទៀតប៉ុណ្ណោះ។

**៣៥២.** ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបានទទួលយកឯកសារថ្មីចំនួន ១៣ ធ្វើជាភស្តុតាង រួមមាន កំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍បន្ថែមទៀត (ក្នុងករណីខ្លះសំណៅថតចម្លងនៃកំណត់ហេតុមកពីប្រភពផ្សេងមាននៅក្នុងសំណុំរឿង) ព្រមទាំងកំណត់ហេតុកិច្ចប្រជុំជាន់ខ្ពស់ផ្សេងទៀត ដូចជា កំណត់ហេតុពីមន្ទីរ ៨៧០ ឬ គណៈកម្មាធិការយោធា។ ឯកសារទាំង ១៣ នេះគឺជាប្រតិចារិកដែលសាស្ត្រាចារ្យ Christopher GOSCHA សរសេរចម្លងដោយដៃចេញពីឯកសារជាភាសាវៀតណាម ដែលត្រូវបានតម្កល់ទុកនៅបណ្ណាល័យកងទ័ពប្រជាជនក្នុងទីក្រុងហាណូយ ហើយបន្ទាប់មកឯកសារទាំងនេះត្រូវបានបកប្រែជាភាសាផ្លូវការរបស់តុលាការ ៣ភាសា ។ ឯកសារទាំងនេះ រួមមាន កំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ដែលរួមមានទាំងកំណត់ហេតុទាំងស្រុងនៃកិច្ចប្រជុំនៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៧ ដែលត្រូវបានយកប្រើនៅក្នុងសវនាការតុលាការប្រជាជនបដិវត្តន៍។ ទោះបីជាពាក្យពេចន៍មិនដូចគ្នាទាំងស្រុងក៏ដោយ ប៉ុន្តែការប្រៀបធៀបបានបង្ហាញថា ឯកសារទាំងពីរបានពិភាក្សាលើកម្មវត្ថុដូចគ្នា ហើយកិច្ចប្រជុំបានចូលរួមដោយសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ដូចគ្នាជាច្រើន ជាពិសេសឯកសារទាំងពីរនោះ បានបញ្ចូលការសម្រេចពាក់ព័ន្ធនឹង «ខ្មាំងខាងក្នុង» ។ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា ខ្លឹមសារនៅក្នុងកំណត់ហេតុមួយចំនួន ក្នុងចំណោមកំណត់ហេតុដែលមានប្រភពពីសាស្ត្រាចារ្យ GOSCHA ត្រូវបានគាំទ្រដោយការផ្សព្វផ្សាយរបស់ទស្សនាវដ្ដីទង់បដិវត្តន៍។

**៣៥៣.** អង្គជំនុំជម្រះទទួលស្គាល់ពីការលំបាកនានាទាក់ទងនឹងការបញ្ជាក់អំពីភាពត្រឹមត្រូវនៃការបកប្រែឯកសារជាច្រើនភាសា ជាពិសេស ឯកសារទាំងនេះគឺជាឯកសារបកប្រែភាសាវៀតណាម ពីឯកសារដើមជាភាសាខ្មែរដែលនាពេលនេះ ឯកសារទាំងនេះត្រូវបានយកមកបកប្រែជាភាសាផ្លូវការរបស់តុលាការ។ អង្គជំនុំជម្រះកត់សម្គាល់ផងដែរថា ឯកសារទាំងនេះត្រូវបានចម្លងដោយដៃដោយសាស្ត្រាចារ្យ Christopher GOSCHA និងមិនមែនជាឯកសារថតចម្លងដែលការសរសេរនេះអាចនាំឲ្យមានកំហុសឆ្គងមួយចំនួន។ អង្គជំនុំជម្រះរម្លឹកថា៖

សាស្ត្រាចារ្យ Goscha បានជូនដំណឹងមកអង្គជំនុំជម្រះថា គាត់បានទៅដល់បណ្ណាល័យកងទ័ពប្រជាជនវៀតណាម និងបានចម្លងតាមនូវឯកសារជាភាសាវៀតណាម។ លោក Philip Short ដែលអង្គជំនុំជម្រះបានចាត់ទុកជាអ្នកជំនាញ បានកត់សម្គាល់ឃើញថា

«សាស្ត្រាចារ្យ Goscha ដែលជាអ្នកជំនាញតែម្នាក់លើបញ្ហាទាំងនេះ ហើយខ្ញុំជឿជាក់ថា គាត់មានភាពត្រឹមត្រូវ ប្រាប់ខ្ញុំថា៖ [...] កន្លែងតែមួយគត់ដែលអ្នកនឹកឃើញកំណត់ហេតុទាំងនោះគឺនៅបណ្ណាល័យយោធានៅហាណូយ ប្រសិនបើពួកគាត់មានបំណងសហការ។ តាមដែលខ្ញុំដឹង គាត់គឺជាអ្នកដែលមិនមែនជាជនជាតិវៀតណាមតែម្នាក់គត់ដែលត្រូវបានអនុញ្ញាតឲ្យធ្វើការនៅទីនោះ [...]»។ កត្តាទាំងនេះគាំទ្រដល់ការអះអាងដែលថា ឯកសារទាំងនេះដែលត្រូវបានប្រទះឃើញនិងចម្លងដោយសាស្ត្រាចារ្យ Goscha គឺជាការបកប្រែតាមលំដាប់លំដោយ ត្រូវរក្សាទុកក្នុងសារមន្ទីរដែលទំនងជារក្សាបាននូវសុចរិតភាពនៃឯកសារទាំងនេះចាប់តាំងពីរបបកម្ពុជាប្រជាធិបតេយ្យ។ ឯកសារទាំងនេះត្រូវបានចងក្រងជាកាតាឡុកតាមរយៈលេខ ហើយឯកសារមួយចំនួនមានឈ្មោះអ្នកបកប្រែនិងកាលបរិច្ឆេទនៃការបកប្រែ ដែលបង្ហាញអំពីដំណើរការជាផ្លូវការនៃឯកសារ។

៣៥៤. ទោះបីជាយ៉ាងណា អង្គជំនុំជម្រះរម្លឹកថាខ្លួនមិនបានដឹងអំពីខ្សែចង្វាក់គ្រប់គ្រងឯកសារមុនពេលឯកសារទាំងនេះមកដល់បណ្ណាល័យកងទ័ពប្រជាជនវៀតណាមនោះទេ និងមិនបានទទួលសំណេរឯកសារដើមជាភាសាខ្មែរនោះឡើយ។ លើសពីនេះទៀតអង្គជំនុំជម្រះរម្លឹកទៀតថា ការបកប្រែភាសាវៀតណាម និងភាពពេញលេញនៃប្រតិចារិកមិនត្រូវបានផ្ទៀងផ្ទាត់ ដែលករណីនេះអាចប៉ះពាល់ដល់ភាពអាចជឿជាក់បាននៃឯកសារទាំងនេះផងដែរ។ ជាថ្មីម្តងទៀត អង្គជំនុំជម្រះមានការសោកស្តាយដែលខ្លួនមិនបានទទួលកិច្ចសហការពីសំណាក់អាជ្ញាធរវៀតណាម និងមិនអាចពិនិត្យលើកំណត់ហេតុនាសម័យកម្ពុជាប្រជាធិបតេយ្យទាំងស្រុង ជាពិសេស កំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នេះបាន។ ហេតុដូច្នេះ អង្គជំនុំជម្រះនឹងពិចារណាលើកំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ដែលបានមកពីសាស្ត្រាចារ្យ GOSCHA ដើម្បីធ្វើការគាំទ្រលើភស្តុតាងដទៃទៀតតែប៉ុណ្ណោះ។

### ៥.១.២.២. សំអាងហេតុ

៣៥៥. ជាគោលការណ៍ គណៈកម្មាធិការមជ្ឈិមមានភារកិច្ចអនុវត្តមាគ៌ានយោបាយនិង លក្ខន្តិកៈរបស់បក្សនៅក្នុង ប.ក.ក.ទាំងមូល ណែនាំអង្គការភូមិភាគ អង្គការតំបន់និងអង្គការបក្សទទួលខុសត្រូវផ្នែកផ្សេងៗទៀត «ឲ្យធ្វើសកម្មភាពស្របតាមមាគ៌ានយោបាយ គោលជំហរសតិអារម្មណ៍និងមាគ៌ាចាត់តាំងរបស់បក្ស» ដើម្បីគ្រប់គ្រងនិងចាត់ចែងកម្មាភិបាល និងបក្ខជននិងទាក់ទងជាមួយបណ្តាលបក្សម៉ាក្សលេនីនជាមួយបងប្អូន»។ គណៈកម្មាធិការមជ្ឈិមត្រូវជួបជុំយ៉ាងហោចណាស់ប្រាំមួយខែម្តង ដូចបានកំណត់នៅក្នុងលក្ខន្តិកៈ ប.ក.ក.។ អត្តសញ្ញាណនិងចំនួនសមាជិកត្រូវបានផ្លាស់ប្តូរជាហូរហែរនៅចន្លោះពីឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៧៩ ប៉ុន្តែនៅពេលឈានដល់ចំណុចកំពូលរបស់ខ្លួនក្នុងទសវត្សរ៍ឆ្នាំ១៩៧០ គណៈកម្មាធិការមជ្ឈិមមានសមាជិកចន្លោះពី២០ទៅ៣០នាក់។ សមាជិកទាំងនោះរួមមាន ទូ សាមុត ដែលបានធ្វើជាលេខា ប.ក.ក. ចាប់ពីឆ្នាំ១៩៦០ រហូតដល់ពេលគាត់បាត់ខ្លួននៅក្នុងឆ្នាំ១៩៦២ ប៉ុល ពត ដែលបានចូលរួមក្នុងគណៈកម្មាធិការមជ្ឈិមបន្ទាប់ពីការបង្កើតគណៈកម្មាធិការនេះនៅក្នុងឆ្នាំ១៩៦០មកនិងបានចូលមកកាន់តំណែងជាលេខា ប.ក.ក. នៅក្នុងឆ្នាំ១៩៦៣ និង នួន ជា ដែលត្រូវបានជ្រើសតាំងនៅក្នុងគណៈកម្មាធិការមជ្ឈិមក្នុងឋានៈជាអនុលេខា ប.ក.ក. នៅក្នុងឆ្នាំ១៩៦០។ សមាជិកផ្សេងៗទៀតមាន មូល សំបាត់ ហៅ ញឹម រស់ ជាលេខាភូមិភាគពាយព្យ, កុយ ធួន ជាលេខាភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) ពីដំបូង, ជូ ជេត ហៅ ស៊ុំ ជាលេខាភូមិភាគបច្ចិម,កង ចាប ហៅ សែ ជាលេខាភូមិភាគឧត្តរថ្មី,ហ៊ូ នឹម ហៅ ភាស់ ជាលេខាក្រសួងឃោសនាការ, ណៃ សារ៉ាន់ ហៅ យ៉ា ជាលេខាភូមិភាគឦសាន, សឿ វ៉ាសុី ហៅ ឌឿន ជាប្រធានមន្ទីរ៨៧០ និងក្រោយមកក្លាយជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម, ឈឹម សំអោក ហៅ ប៉ង់ ប្រធានមន្ទីរស-៧១, វន វ៉ែត និង កែវ មាស។ ខៀវ សំផន បានចូលរួមក្នុងគណៈ

កម្មាធិការមជ្ឈិមក្នុងនាមជាសមាជិកត្រៀមនៅឆ្នាំ ១៩៧១ ហើយបានក្លាយជាសមាជិកពេញសិទ្ធិនៅឆ្នាំ ១៩៧៦។ យោងតាមលក្ខន្តិកៈ ប.ក.ក. សមាជិកត្រៀម អាច «ចូលរួមប្រជុំគណៈកម្មាធិការមជ្ឈិមបាន តែមិនមានសិទ្ធិសម្រេចទេ»។

**៣៥៦**. ឌុច បានលើកឡើងថា « ជំនួយការ» នៃគណៈកម្មាធិការមជ្ឈិម គឺជាក្រុមមនុស្សប្រភេទទីបួនដែលបានចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការមជ្ឈិម ហើយគាត់បានប៉ាន់ប្រមាណទៀតថា បើរួមបញ្ចូលទាំងក្រុមនេះផងដែរនោះ គណៈកម្មាធិការមជ្ឈិមមានសមាជិក ១០០នាក់ ក្នុងពេលដែលគណៈកម្មាធិការនេះមានសមាជិកច្រើនបំផុតនោះ។ ពុំមានភស្តុតាងផ្សេងទៀតដែលលើកឡើងថាជំនួយនៃគណៈកម្មាធិការមជ្ឈិមគឺជាអង្គភាពដោយឡែកនោះឡើយ ចំណែកឯលក្ខន្តិកៈ ប.ក.ក. មិនបានលើកឡើងពីស្ថាប័ននេះនោះទេ។ អង្គជំនុំជម្រះយល់ឃើញថា មិនមានភស្តុតាងគ្រប់គ្រាន់ក្នុងការកំណត់អំពីចំនួនជំនួយការនៃគណៈកម្មាធិការមជ្ឈិម ឬតួនាទីជាក់លាក់របស់ពួកគេនោះឡើយ។ ទោះបីជាយ៉ាងណា ផ្អែកលើភស្តុតាងទាំងអស់ដែលមានចំពោះមុខ អង្គជំនុំជម្រះសន្និដ្ឋានថា ចំនួនសមាជិកគណៈកម្មាធិការមជ្ឈិម និងសមាជិកត្រៀមមានចំនួនប្រមាណពី ២០ ទៅ ៣០នាក់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

**៣៥៧**. ទោះបីជាលក្ខន្តិៈ ប.ក.ក. ផ្តល់អំណាចប្រតិបត្តិការខ្ពស់បំផុតឲ្យទៅគណៈកម្មាធិការមជ្ឈិមក៏ដោយ ក៏ការត្រួតត្រាពិតប្រាកដទៅលើ ប.ក.ក. ត្រូវបានអនុវត្តដោយគណៈកម្មាធិការអចិន្ត្រៃយ៍របស់គណៈកម្មាធិការមជ្ឈិម (ដែលគេស្គាល់ថាជា គណៈកម្មាធិការអចិន្ត្រៃយ៍)។ គណៈកម្មាធិការអចិន្ត្រៃយ៍ បានចាប់ផ្តើមមានអត្ថិភាពក្នុងពេលជាមួយគ្នានឹងអត្ថិភាពនៃគណៈកម្មាធិការមជ្ឈិមនៅក្នុងឆ្នាំ១៩៦០ផងដែរ។ បើតាមកំណត់ហេតុនានាដែលបង្ហាញពីខ្លឹមសារនៃលក្ខន្តិកៈបក្សឆ្នាំ១៩៧១ គណៈកម្មាធិការមជ្ឈិមបក្សមានតួនាទីចាប់តាំងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ព្រមទាំងលេខា និងអនុលេខា។ គណៈកម្មាធិការអចិន្ត្រៃយ៍ជួបជុំគ្នាប្រហែលពី ៧ថ្ងៃទៅ ១០ថ្ងៃម្តង ឬក៏ជួបប្រជុំញឹកញាប់ជាងនេះ ប្រសិនបើមានការលៈទេសៈតម្រូវ ហើយគណៈកម្មាធិការនេះទទួលខុសត្រូវដឹកនាំការងារប្រចាំថ្ងៃរបស់បក្ស។ គណៈកម្មាធិការអចិន្ត្រៃយ៍មានសមាជិក ៧រូប ដោយសមាជិកទាំងអស់នេះត្រូវបានចាត់តាំងចេញពីគណៈកម្មាធិការមជ្ឈិមទោះបីជាយ៉ាងណាក្តីសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ មួយចំនួនមិនបានឈរជើងនៅក្រុងភ្នំពេញនោះទេរួមមាន សោ ភឹម (ភូមិភាគបូព៌ា)និង តាម៉ុក ( ភូមិភាគនិរតី)។ ដូចគ្នានឹងគណៈកម្មាធិការមជ្ឈិមដែរ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ត្រូវបានផ្លាស់ប្តូរពីពេលមួយទៅពេលមួយ។ ប៉ុល ពត, អៀង សារី, សោ ភឹម, និង នួន ជា គឺជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៅក្នុងឆ្នាំ១៩៦៣។ សុន សេន ហៅ ខៀវ គឺជាសមាជិកត្រៀមបម្រុង ឬ សមាជិកបម្រុង (មិនមែនជាសមាជិកពេញសិទ្ធិ) នៃគណៈកម្មាធិការអចិន្ត្រៃយ៍ទេ ហើយ សុខ ធួក ហៅ វន វ៉ែត អាចជាសមាជិកពេញសិទ្ធិ ឬ ជាសមាជិកត្រៀម។ សឿនវ៉ា ស៊ី ហៅ ឌឿន និង ខៀវ សំផន មិនធ្លាប់ជាសមាជិកផ្លូវការនៃគណៈកម្មាធិការអចិន្ត្រៃយ៍ឡើយ ប៉ុន្តែគេបានចូលរួមនៅក្នុងកិច្ចប្រជុំមួយចំនួនរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ផងដែរ។ កិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍អាច (និងជាញឹកញាប់គឺដូច្នេះ) ត្រូវបានធ្វើឡើងដោយអវត្តមានសមាជិកមួយរូបឬច្រើនរូបនៃគណៈកម្មាធិការនេះ។

**៣៥៨**. សមាជិកគណៈ

កម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ជាច្រើនត្រូវបានបោសសម្អាតចេញពីបក្ស ក្រោយពួកគេត្រូវបានចោទប្រកាន់ថា ជាខ្មាំងនៅក្នុងចម្លើយសារភាពនៅមន្ទីរសន្តិសុខស-២១។ ឧទាហរណ៍ កុយ ធួន ត្រូវបានបញ្ជូនមកភ្នំពេញ ហើយគាត់ត្រូវបានឃុំខ្លួននៅក្នុងផ្ទះអស់រយៈពេល ៨ខែ មុនពេលបញ្ជូនទៅមន្ទីរសន្តិសុខស-២១ នៅខែមករា ឆ្នាំ១៩៧៧។ ហ៊ូ នឹម ហៅភាស់ ត្រូវបានចាប់ខ្លួននៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៧។ ក្នុងពេលដំណាលគ្នានោះ

*សឿ វ៉ាស៊ី ហៅ ឌឿន ក៏ត្រូវបានបញ្ជូនមកមន្ទីរសន្តិសុខ ស-២១ដែរ។ ឈីម សំអោក ហៅ ប៉ុន ត្រូវបានចាប់ខ្លួននៅខែមេសា ឆ្នាំ១៩៧៨។ កង ចាប ហៅ សែ ត្រូវបានចាប់ខ្លួននៅខែតុលា ឆ្នាំ១៩៧៨។ ជូ ជេត ហៅ ស៊ី,ហ៊ូ នឹម ហៅ ភាស់, ណៃ សារ៉ាន់ ហៅ យ៉ា, សឿ វ៉ា ស៊ី ហៅ ឌឿន, ឈីម សំអោក ហៅ ប៉ុន, រស់ ញឹម និង កែវ មាស សុទ្ធតែត្រូវបានបញ្ជូនមកមន្ទីរសន្តិសុខ ស-២១ យកទៅសួរចម្លើយនិង ត្រូវបានយកទៅសម្លាប់។ សោ ភឹម ត្រូវបានកំណត់អត្តសញ្ញាណថាត្រូវចាប់ខ្លួន ប៉ុន្តែគាត់បានធ្វើអត្តឃាតនៅខែមិថុនា ឆ្នាំ១៩៧៨ មុនពេលនិងត្រូវចាប់ខ្លួន។ ចុងក្រោយ វន វេត ត្រូវបាននាំទៅមន្ទីរសន្តិសុខ ស-២១ នៅខែវិច្ឆិកា ឆ្នាំ១៩៧៨ ហើយគាត់ត្រូវបានគេធ្វើទារុណកម្ម និងសម្លាប់ជាមួយគ្រួសាររបស់គាត់។*

### ៥.១.៣. គណៈកម្មាធិការយោធា

**៣៥៩.** *គណៈកម្មាធិការយោធាគឺជាអនុគណៈកម្មាធិការ (ក្រោមលក្ខន្តិកៈដោយឡែក) របស់គណៈកម្មាធិការមជ្ឈិម។ ទោះបីជាយ៉ាងណា ផ្អែកតាមកំណត់ហេតុដែលបង្ហាញពីខ្លឹមសារនៃលក្ខន្តិកៈបក្សឆ្នាំ១៩៧១ កងកម្លាំងប្រដាប់អាវុធជាតិរំដោះប្រជាជនកម្ពុជា (CPNLAF) ចំណុះឲ្យបក្ស ហើយគណៈកម្មាធិការដឹកនាំអង្គការត្រូវបានបង្កើតឡើងឲ្យស្របទៅតាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ។ គណៈកម្មាធិការយោធាត្រូវបានដឹកនាំដោយ ប៉ុល ពត និង ទទួលខុសត្រូវចំពោះកិច្ចការយោធា និងសន្តិសុខ។ សុន សេន ក៏ជាសមាជិកគណៈកម្មាធិការយោធានេះដែរ។ ផ្អែកលើភស្តុតាងដែលមានអង្គជំនុំជម្រះជឿជាក់ថា នួន ជា ពុំមែនជាសមាជិកគណៈកម្មាធិការយោធានោះឡើយ។ ទោះបីជាយ៉ាងណាក្តី អង្គជំនុំជម្រះយល់ឃើញថា នួន ជា មានឥទ្ធិពលយ៉ាងខ្លាំងទៅលើគោលនយោបាយខាងយោធានៃរបបកម្ពុជាប្រជាធិបតេយ្យ និងការអនុវត្តគោលនយោបាយ។*

### ៥.១.៤. គណៈកម្មាធិការមជ្ឈិមបក្ស

**៣៦០.** *សាក្សីនិងអ្នកជំនាញជាច្រើនដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះបានប្រើពាក្យថា «មជ្ឈិមបក្ស» ដោយសំដៅទៅលើថ្នាក់ដឹកនាំជាន់ខ្ពស់របស់ ប.ក.ក.។ ប៉ុន្តែដូចដែលសាក្សី Stephen HEDER បានបញ្ជាក់រួចហើយថា «មជ្ឈិមបក្ស» គឺជាពាក្យដែលមិនច្បាស់លាស់។*

*ពេលខ្លះពាក្យនេះត្រូវបានប្រើនៅក្នុងន័យរួម ដើម្បីសំដៅទៅលើ «កម្រិតទាំងមូលនៅក្នុងឋានានុក្រមបក្ស» ហើយពេលខ្លះទៀតត្រូវបានប្រើសំដៅទៅលើអង្គភាព ឬស្ថាប័នជាក់លាក់ណាមួយនៅថ្នាក់លើរបស់ ប.ក.ក. (ដូចជា គណៈកម្មាធិការមជ្ឈិមគណៈកម្មាធិការអចិន្ត្រៃយ៍ ឬ មន្ទីរពាក់ព័ន្ធរបស់ខ្លួនណា ឬក៏ ប៉ុល ពត តែម្តង)។ ពាក្យថា «មជ្ឈិមបក្ស» ក៏ត្រូវបានលើកឡើងនៅក្នុងឯកសារមួយចំនួនដែលត្រូវបានដាក់ដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ រួមទាំង ឯកសារសម័យកម្ពុជាប្រជាធិបតេយ្យ និង សេចក្តីអត្ថាធិប្បាយរបស់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយៗមក ដោយមិនមានកំណត់និយមន័យនោះទេ ប៉ុន្តែត្រូវបានប្រើនៅក្នុងបរិបទមួយដែលបានបង្ហាញច្បាស់លាស់ថា ពាក្យនេះគឺសំដៅទៅលើថ្នាក់កំពូលនៃឋានានុក្រមប.ក.ក.(ផ្នែកសំខាន់ៗខ្លះ)។*

**៣៦១.** *នៅក្នុងសាលក្រមនេះ អង្គជំនុំជម្រះប្រើពាក្យថា «មជ្ឈិមបក្ស» សំដៅរួមទៅលើស្ថាប័ននីតិប្រតិបត្តិជាន់ខ្ពស់របស់ ប.ក.ក. ដែលមានមូលដ្ឋាននៅទីក្រុងភ្នំពេញ ដូចជា គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មាធិការមជ្ឈិម គណៈកម្មាធិការយោធាមន្ទីរ ៨៧០ មន្ទីររដ្ឋាភិបាល (មន្ទីរស-៧១) និងមន្ទីរចំណុះឲ្យមន្ទីររដ្ឋាភិបាល។*

### ៥.១.៥. មន្ទីរ៨៧០

**៣៦២.** *នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យលេខកូដ «៨៧០» មិនត្រូវបានប្រើប្រាស់ច្បាស់លាស់ដើម្បីសំដៅទៅលើបុគ្គលនិង អង្គភាពនានាដែលជាប់ទាក់ទងនិងមជ្ឈិមបក្សទេ។ សាក្សីផ្សេងគ្នាបានផ្តល់នូវការយល់ដឹងខុសៗគ្នាពាក់ព័ន្ធនឹងលេខកូដ«៨៧០» នេះប៉ុន្តែជាទូទៅពួកគេបានឯកភាពថាវាត្រូវបានប្រើសំដៅទៅអង្គភាពនានាដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ថ្នាក់ដឹកនាំ*

ប.ក.កៗ យោងតាមកសាក្សី Stephen HEDER លេខកូដ «៨៧០» ត្រូវបានជ្រើសតាំងឆ្នាំ១៩៧១មកម្ល៉េះ ហើយត្រូវបានគេកំណត់ថាជា «ថ្នាក់ដឹកនាំមជ្ឈិមបក្ស» ។ អ្នកជំនាញ Philip SHORT បានលើកឡើងថា «៨៧០» គឺជា «ឈ្មោះលេខកូដសម្រាប់គណៈកម្មាធិការអចិន្ត្រៃយ៍» ។ ភាពមិនច្បាស់លាស់ពាក់ព័ន្ធនិងអត្ថបទនៃលេខកូដ «៨៧០» នេះគឺស៊ីចង្វាក់គ្នាជាមួយនឹងការព្យាយាមរក្សាការសម្ងាត់ជាទូទៅរបស់ ប.ក.ក.។ ដូចដែលអ្នកជំនាញ David CHANDLER បានធ្វើការកត់សម្គាល់ថា ប.ក.ក. ចេតនានៃការប្រើលេខកូដនេះគឺដើម្បីលាក់បាំង ឬកុំឲ្យអ្នកដទៃបានយល់ពីលក្ខណៈពិតប្រាកដនៃថ្នាក់ដឹកនាំរបស់ ប.ក.ក.។ ខៀវ សំផន បានប្រាប់សហចៅក្រមស៊ើបអង្កេតថា គណៈកម្មាធិការ «៨៧០»ឬ «៨៧»។ ខៀវ សំផន បានប្រាប់សហចៅក្រមស៊ើបអង្កេតថា គណៈកម្មាធិការ ៨៧០ សំដៅលើបក្សនិងមានន័យថា ប៉ុល ពត ដែលបានចុះហត្ថលេខាលើឯកសារដោយឈ្មោះថា«៨៧០» ឬ «៨៧»។ ឌុច បានផ្តល់សក្ខីកម្មថា នៅមន្ទីរសន្តិសុខស-២១ គាត់បានទទួលការណែនាំមន្ទីរ៨៧០ និងបានជូនរបាយការណ៍ (រួមទាំងចម្លើយសារភាព) ត្រឡប់មន្ទីរ៨៧០ វិញតាមរយៈនីរសារ។ សៅ សារុន ដែលជាអតីតលេខាតំបន់ ១០៥ បានផ្តល់សក្ខីកម្មដូចគ្នាថាគាត់បានរាយការណ៍ទៅមន្ទីរ ៨៧០ ជារៀងរាល់ថ្ងៃ និងបានទទួលការណែនាំ និងទទួលព័ត៌មានពីមន្ទីរ ៨៧០ ប្រមាណជាពីរទៅបីដងក្នុងមួយខែៗ។ ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ដែលទទួលបន្ទុកក្នុងការបញ្ជូនឯកសារទៅមន្ទីរ ៨៧០ បានលើកឡើងថា ថ្នាក់ដឹកនាំភូមិភាគបានប្រាប់គាត់ថាមន្ទីរ៨៧០ គឺជាមន្ទីរមជ្ឈិមរបស់ ប.ក.ក.។

**៣៦៣**. គណៈកម្មាធិការ៨៧០ និង «មន្ទីរ៨៧០» ជាអង្គភាពពីរដាច់ដោយឡែកពីគ្នាដែលមន្ទីរ៨៧០ក៏មានឈ្មោះជា « មន្ទីរយោធា៨៧០» «ម-៨៧០» (អក្សរ «ម» ជំនួសឲ្យពាក្យថា «មន្ទីរ» ដែលជាពាក្យខ្មែរប្រើជំនួសពាក្យ «ការិយាល័យ») ឬ «មន្ទីររបស់គណៈកម្មាធិការអចិន្ត្រៃយ៍» («មន្ទីរ៨៧០»)។ តាមសម្តីរបស់លោក Philip SHORT មន្ទីរ៨៧០ បានបំពេញមុខងារជា «ស្ថាប័នប្រតិបត្តិ» របស់គណៈកម្មាធិការអចិន្ត្រៃយ៍។ មន្ទីរនេះមានភារកិច្ចអនុវត្តតាមដានការអនុវត្តសេចក្តីសម្រេចនានារបស់គណៈកម្មាធិការអចិន្ត្រៃយ៍ដើម្បី «ទំនាក់ទំនងទៅវិញទៅមកជាមួយនីមួយៗ» របស់ថ្នាក់លើនៃ ប.ក.ក. ក្នុងនាមគណៈកម្មាធិការអចិន្ត្រៃយ៍។ ទាំងលោក Philip SHORT និងលោក David CHANDLER បានប្រើឃ្លាថា «មន្ទីរសរសៃឈាមដ៏សំខាន់» ដើម្បីរៀបរាប់អំពីតួនាទីដ៏សំខាន់បំផុតរបស់មន្ទីរ ៨៧០ ក្នុងការបញ្ជូនព័ត៌មានចេញនិងចូលមកគណៈកម្មាធិការអចិន្ត្រៃយ៍។

**៣៦៤**. ដូចបានពិភាក្សាលម្អិតបន្ថែមនៅផ្នែកខាងក្រោម អង្គជំនុំជម្រះសន្និដ្ឋានថា មន្ទី ៨៧០ បានគ្រប់គ្រងនិងត្រួតពិនិត្យលើការអនុវត្តសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ហើយកាលដំបូងមន្ទីរនេះមានសមាជិកជំនួនពីរនាក់យ៉ាងតិចគឺ សឿ វ៉ាស៊ី ហៅ ឌឿន ដែលត្រូវបានចាត់តាំងនៅខែតុលា ឆ្នាំ១៩៧៥ និង ខៀវ សំផន ដែលត្រូវបានចាត់តាំងនៅពេលដំណាក់ណាលគ្នានោះ។ ខៀវ សំផន បានរម្លឹកថា ឌឿន បានអវត្តមានជាញឹកញាប់ ដោយសារគាត់ត្រូវធ្វើដំណើរ ត្រូវទទួលរបាយការណ៍ពីភូមិភាគ និង «ទទួលខុសត្រូវកិច្ចការនយោបាយ»។ ក្រោយពេល ឌឿន ត្រូវបានចាប់ខ្លួននៅចុងខែមករា ឬ ខែកុម្ភៈឆ្នាំ ១៩៧៧ មន្ទីរ៨៧០ នៅបន្តធ្វើប្រតិបត្តិការដដែល។ ខៀវ សំផន បានលើកឡើងដោយស្មានថា ឈឹម សំអោក ហៅ ប៉ង់ បានបន្តការងារជំនួស ឌឿន ក្នុងឋានៈជាប្រធានមន្ទីរ៨៧០ ប៉ុន្តែផ្អែកលើភស្តុតាងដែលមានស្រាប់នៅក្នុងសំណុំរឿង អង្គជំនុំជម្រះជឿជាក់ថា ការលើកឡើងនេះមិនត្រឹមត្រូវនោះទេ។ ដូចគ្នានេះដងដែរ ផ្អែកលើបទដ្ឋានតម្រូវអង្គជំនុំជម្រះមិនជឿថា ខៀវ សំផន បានបន្តការងារជំនួស ឌឿន ក្នុងឋានៈជាប្រធានមន្ទីរ ៨៧០ នោះឡើយ។

**៣៦៥**. កំណត់ហេតុអង្គជំនុំជម្រះរបស់គណៈកម្មាធិការអចិន្ត្រៃយ៍មួយច្បាប់ បានលើកឡើងពីអង្គភាពដាច់ដោយឡែកមួយ (ដែលគេហៅជាភាសាខ្មែរថា «ការិយាល័យ

៨៧០» ជំនួសឲ្យ «មន្ទីរ៨៧០» ។ ទោះបីជាយ៉ាងណា ខៀវ សំផនបានប្រាប់ថាសហចៅក្រមស៊ើបអង្កេតថា ពាក្យទាំង ពីរនេះ គឺសំដៅទៅលើមន្ទីរតែមួយ។ កំណត់ហេតុនៃកិច្ច ប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៅខែតុលា ឆ្នាំ ១៩៧៥បានបង្ហាញថា ការិយាល័យ៨៧០ ត្រូវបានដឹកនាំ ដោយឈ្មោះ ស៊ឹម សុន ហៅយ៉ែម។ ប៉ុន្តែ យ៉ែម ក៏បាន កាន់តួនាទីជាលេខាតំបន់ ៥០៥ នៅក្នុងឆ្នាំ១៩៧៥ មុន ពេលគាត់ត្រូវបានចាត់តាំងជាឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំ សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េនៅឆ្នាំ ១៩៧៦។ ហេតុនេះ មុខងារជាក់លាក់របស់ការិយាល័យ ៨៧០ ឬ ថាតើការិយាល័យនេះជាអង្គភាពដាច់ដោយ ឡែកឬទេនោះតែមិនមានភាពច្បាស់លាស់ដដែល។

## ៥.១.៦.មន្ទីររដ្ឋាភិបាល (ស-៧១) និងមន្ទីរចំណុះ ផ្សេងៗទៀត

**៣៣៦.** ដូចគ្នានឹងមន្ទីរ ៨៧០ ដែរមជ្ឈិមបក្សបានដំណើរ ការមន្ទីររដ្ឋបាលមួយដែលត្រូវបានលើកឡើងនៅក្នុង កំណត់ហេតុអង្គប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ជា «មន្ទីររដ្ឋាភិបាល» ។ រហូតមកទល់នឹងខែតុលា ឆ្នាំ១៩៧៥ មន្ទីររដ្ឋាភិបាលនេះត្រូវបានដឹកនាំដោយឈ្មោះ ឈឹម សំអោក ហៅ ប៉ាង ជាសមាជិកគណៈកម្មាធិការមជ្ឈិម។ សាក្សីជាច្រើនបានហៅអង្គភាពដែលដឹកនាំដោយ ប៉ាង ថាជា« ស-៧១» ហើយស្ថាប័ន ឬក្រសួងដែលត្រូវបាន កំណត់ថាជា«ស-៧១» ត្រូវបានគេសរសេរជាញឹកញាប់ នៅក្នុងឈ្មោះអ្នកជាប់ឃុំ ដែលត្រូវបានបញ្ជូនខ្លួនមកកាន់ មន្ទីរសន្តិសុខស-២១ ដែលបញ្ជាក់ថា «ស-៧១» គឺជា លេខកូដរបស់មន្ទីររដ្ឋាភិបាលនេះ។

**៣៦៧.** មន្ទីរស-៧១ អាចជាផ្នែកនៃមន្ទីរ៨៧០ ឬក៏អាច ជាអង្គភាពដាច់ដោយឡែកមួយ។ បើទោះបីជាកំណត់ ហេតុនៃកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍បញ្ជាក់ ថាមន្ទីរទាំងនោះផ្សេងពីគ្នាក៏ដោយក៏សាក្សី Stephen HEDER បានរម្លឹកថាបុគ្គលជាច្រើននាក់ដែលគាត់បាន សម្ភាសមានការយល់ច្រឡំទៅលើមន្ទីរទាំងពីរនេះ ហើយ តាមពិតទៅសាក្សីជាច្រើនដែលបានផ្ដល់សក្ខីកម្មនៅ ចំពោះមុខអង្គជំនុំជម្រះ បានហៅអង្គភាពដែលដឹកនាំ ដោយ ឈឹម សំអោកហៅ ប៉ាង ប្រើលេខកូដ «៨៧០» ។ ប៉ុន្តែយោងតាមសក្ខីកម្មផ្សេងទៀត មន្ទីរស-៧១ ដែល ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ប៉ាង បានបំពេញមុខងារ ផ្សេងពីមន្ទីរ៨៧០ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ស៊ឿ វ៉ាស៊ី ហៅ ឌឿន។ មន្ទីរ៨៧០ របស់ឌឿន ពាក់ព័ន្ធនឹង ការអនុវត្តគោលនយោបាយ ចំណែកឯមន្ទីរស-៧១ របស់ ប៉ាង ពាក់ព័ន្ធជាចម្បងទៅនឹងកិច្ចខាងភស្តុភារ ការងារអនុវត្ត និងការងាររដ្ឋបាល។

**៣៦៨.** ជាពិសេស មន្ទីរស-៧១ បានគ្រប់គ្រងទៅលើមន្ទីរ ចំណុះនិងអង្គភាពផ្សេងៗ ដែលបំពេញមុខងារជួយគាំទ្រ ដល់មជ្ឈិមបក្ស។ ហើយដែលភាគច្រើនត្រូវបានកំណត់ ឈ្មោះជាលេខកូដដែលចាប់ផ្ដើមចេញដោយអក្សរ «ក»។ មន្ទីរក-១ មានទីតាំងស្ថិតនៅក្រុងភ្នំពេញ ដែលជាទីកន្លែង ធ្វើការនិងកន្លែងស្នាក់នៅរបស់ ប៉ុល ពត។ ក-៣ គឺជាមន្ទីរ និងជាកន្លែងស្នាក់នៅមួយផ្សេងទៀតដែលស្ថិតនៅទី ក្រុងភ្នំពេញសម្រាប់មេដឹកនាំជាន់ខ្ពស់របស់ ប.ក.ក. រួមទាំង នួន ជា និង ខៀវ សំផន ផងដែរ។ មន្ទីរក-៦ គឺជា សាលានយោបាយរបស់ ប.ក.ក. ដែលស្ថិតនៅឯបុរីកីឡា ទីក្រុងភ្នំពេញ។ មន្ទីរក-៧ គឺជាអង្គភាពនីរសារ។ មន្ទីរ ក-៨ គឺជាអង្គភាពទទួលខុសត្រូវខាងដាំបន្លែ។ មន្ទីរក-៩ ជារោងចក្រវាយនភ័ណ្ឌ។ មន្ទីក-១១ គឺជាកន្លែងផលិតថ្នាំ ពេទ្យ។ មន្ទីរក-១២ គឺជាអង្គភាពរៀបចំចាត់ចែងយាន ជំនិះអ្នកបើកបរ។ មន្ទីរក-១៥ជាសាលាបណ្ដុះបណ្ដាល នយោបាយជាសំខាន់ (ប៉ុន្តែមិនដូច្នេះទាំងអស់ទេ) សម្រាប់ខ្មែរដែលត្រឡប់មកពីបរទេសវិញ។ មន្ទីរក-១៨ គឺជាមន្ទីរទូរលេខ។

**(តនៅលេខក្រោយ)**

# ការចងចាំអំពីអំពើប្រល័យពូជសាសន៍នៅក្នុងប្រវត្តិសាស្ត្រពិភពលោក

*សូវិចិត្រ មេត្តា*



*អដ្ឋិធាតុរបស់ជនរងគ្រោះត្រូវបានគាស់ក្រោយពេលរបបខ្មែរក្រហមដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ជារៀងរាល់ឆ្នាំនៅថ្ងៃទី២៧ ខែមករា ប្រទេសនានានៅជុំវិញពិភពលោកចូលរួមគោរពវិញ្ញាណក្ខន្ធជនរងគ្រោះដែលបានស្លាប់ដោយសារការកាប់សម្លាប់រង្គាលនៅអឺរ៉ុប ឬហូឡូខស្ត៍។ នៅថ្ងៃនេះ កាលពី៧៦ឆ្នាំមុននៅក្នុងឆ្នាំ១៩៤៥ ទាហានអង់អាចក្លាហានដែលបានលះបង់ជីវិតដើម្បីជួយសង្គ្រោះមនុស្សរាប់លាននាក់ទៀតបានធ្វើសង្គ្រាមជាមួយនឹងអាឡឺម៉ង់ និងបានសម្រុកចូលទៅក្នុងជំរំឃុំឃាំងរបស់ណាហ្ស៊ីដ៏ធំបំផុតដែលមានឈ្មោះថា អូសឈ្វិច-បឺកខេណូ និងបានដោះលែងអ្នកទោសជាង៧,០០០នាក់ នៅទីនោះ ដែលនៅរស់រានមានជីវិត។ នៅក្នុងជំរំនោះមានជនជាតិជ្វីហ្វចំនួនជាងមួយលាន ត្រូវបានណាហ្ស៊ីសម្លាប់ដោយបញ្ជូនទៅបន្ទប់ផ្សែងពុល និងមានជនរងគ្រោះដែលមកពីប្រទេសផ្សេងៗ ដូចជា រុស្ស៊ី ប៉ូឡូញ ជាង ១០០,០០០ នាក់ទៀត។

នៅថ្ងៃទី១ ខែវិច្ឆិកាឆ្នាំ ២០០៥ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តលើអនុសញ្ញាលេខ ៦០/៧ ដើម្បីកំណត់យកថ្ងៃទី២៧ ខែមករា ជាទិវាបុណ្យអន្តរជាតិដើម្បីរំឭកដល់ជនរងគ្រោះនៅក្នុងការកាប់សម្លាប់រង្គាលនៅអឺរ៉ុប ឬ ហូឡូខស្ទ៍ ដែលនឹងប្រព្រឹត្តធ្វើជារៀងរាល់ឆ្នាំៗ ទោះបីជាយ៉ាងណាក៏ដោយ ការកាប់សម្លាប់រង្គាលនៅអឺរ៉ុបមិនមែនជាអំពើប្រល័យពូជសាសន៍តែមួយគត់នៅក្នុងពិភពលោកនោះទេ។ ដូច្នេះហើយ នៅថ្ងៃនេះយើងក៏ធ្វើការចងចាំនិងគោរពដល់មនុស្សរាប់លាននាក់ទៀត ដែលត្រូវបានសម្លាប់ និងអ្នកដែលនៅរស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា ប្រទេសរ្វាន់ដា ប្រទេសបូស្នី-ហឺហ្សីហ្គោវីន និងប្រទេសដាហ្វួ។

នៅក្នុងសប្តាហ៍នេះអង្គការសហប្រជាជាតិ និងយូណេស្កូបានសហការរៀបចំព្រឹត្តិការណ៍ជាច្រើន រួមមានការពិភាក្សាជាក្រុម ការប្រារព្ធពិធីចងចាំ, ការប្រគុំតន្ត្រីតាមរយៈប្រព័ន្ធអ៊ីនធើណែត និងការបញ្ចាំងខ្សែភាពយន្ត សម្រាប់ទិវាបុណ្យអន្តរជាតិដើម្បីរំឭកដល់ជនរងគ្រោះនៅក្នុងការកាប់សម្លាប់រង្គាលនៅអឺរ៉ុប ឬ ហូឡូខស្ទ៍។ យោងតាមគេហទំព័ររបស់អង្គការសហប្រជាជាតិ ប្រធានបទផ្លូវការសម្រាប់ការចងចាំ និងការអប់រំអំពីការសម្លាប់រង្គាលនៅអឺរ៉ុបសម្រាប់ឆ្នាំ ២០២១ គឺ "ប្រឈមមុខនឹងផលប៉ះពាល់ ៖ ការស្តារឡើងវិញនិងការធ្វើនីតិសម្បទាបន្ទាប់ពីការសម្លាប់រង្គាលនៅអឺរ៉ុប" ។ ដើម្បីធ្វើឲ្យប្រជាជនយល់ដឹងអំពី "គ្រោះថ្នាក់អំពីការបដិសេធនិងការក្លែងបន្លំព័ត៌មាន", អង្គការសហប្រជាជាតិ និងយូណេស្កូក៏កំពុងធ្វើយុទ្ធនាការតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមដោយប្រើសញ្ញា ទ្រុងជ្រូក (#) ជាមួយនឹងពាក្យថា ការពារការពិត ។

ការចងចាំអំពីជនរងគ្រោះនៃការសម្លាប់រង្គាល និងអំពើឃោរឃៅដទៃទៀត និងគោរពអ្នករស់រានមានជីវិតដែលជីវិតរបស់អ្នកទាំងនោះបានផ្លាស់ប្តូរលើសពីពាក្យបរិយាយ គឺពិតជាមានសារសំខាន់យ៉ាងធំធេង។ ប៉ុន្តែវាក៏ចាំបាច់ផងដែរដែលមានការធានាថា ការចងចាំនឹងមានស្ថិរភាព ដើម្បីការពារកុំឲ្យមានទម្រង់មួយទៀតនៃអំពើប្រល័យពូជសាសន៍ និងអំពើឃោរឃៅកើតមានឡើងម្តងទៀត។ បន្ទាប់ពីការកាប់សម្លាប់រង្គាលនៅអឺរ៉ុបបានបញ្ចប់ទៅ យើងនៅតែបន្តឃើញការកើនឡើងនូវករណីប្រល័យពូជសាសន៍ និងអំពើឃោរឃៅដ៏ដទៃទៀតជាបន្តបន្ទាប់ ដែលអំពើប្រល័យពូជសាសន៍មួយចំនួនត្រូវបានបដិសេធដោយរដ្ឋាភិបាលមួយចំនួន ដូចជាការប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិរ៉ូហ៊ីងយ៉ានៅប្រទេសមីយ៉ាន់ម៉ា និងការគៀបសង្កត់របស់រដ្ឋាភិបាលចិនទៅលើជនជាតិមូស្លីមអ៊ុយហ្គួរនៅស៊ីនជាំង ព្រមទាំងអំពើប្រល័យពូជសាសន៍ទៅលើជនជាតិអាមេនីដែលបានកើតឡើងមុនការកាប់សម្លាប់រង្គាលនៅអឺរ៉ុប និងមុនការបង្កើតនិយមន័យនៃ "អំពើប្រល័យពូជសាសន៍"។ ហេតុអ្វីបានជាមានការកើនឡើងនូវអំពើប្រល័យពូជសាសន៍? តើយើងគួរចងចាំអំពើប្រល័យពូជសាសន៍យ៉ាងដូចម្តេច?

ក្នុងរយៈពេលសាមសិបឆ្នាំបន្ទាប់ពីការសម្លាប់រង្គាលនៅអឺរ៉ុប ខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញនៅក្នុងប្រទេសកម្ពុជា ហើយក្នុងរយៈពេល ៣ឆ្នាំ ៨ ខែ ២០ ថ្ងៃបានសម្លាប់ប្រជាជនរបស់ខ្លួនយ៉ាងហោចណាស់ ២លាននាក់ និងធ្វើទារុណកម្មរាប់លាននាក់ទៀត។ ខ្មែរក្រហមបានកាន់កាប់ប្រទេសកម្ពុជានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥។ "ខ្មែរក្រហម" គឺជាឈ្មោះដែលព្រះបាទ នរោត្តម សីហនុបានដាក់ឲ្យគូប្រជែងរបស់ទ្រង់ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០។ នៅពេលឡើងកាន់អំណាច ខ្មែរក្រហមបានចាប់ផ្តើមអនុវត្តផ្លាស់ប្តូរការដឹកនាំប្រទេស ដោយដើរតាមលទ្ធិម៉ៅនិយម និងម៉ាក្ស-លេនីននិយម ក្នុងគោលបំណងបង្កើតសង្គមកសិកម្មនិយម។ ខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំប្រហែលជាង២លាននាក់ពីទីក្រុងភ្នំពេញ និងទីក្រុងដទៃទៀតទៅតាមតំបន់ជនបទដើម្បីបំពេញការងារកសិកម្ម។

ដប់ប្រាំឆ្នាំក្រោយមក នៅក្នុងឆ្នាំ ១៩៩៤ ក្នុងរយៈពេលត្រឹមតែ ១០០ ថ្ងៃប្រជាជនប្រមាណ ៨០០.០០០ នាក់ត្រូវបានសម្លាប់ដោយក្រុមជ្រុលនិយមជនជាតិហ៊ូទូ

នៅរ៉្វាន់ដា និងប្រជាជនប្រហែល ១០០.០០០-២០០.០០០ នាក់ត្រូវបានរំលោភ និងទទួលរងពីអំពើហិង្សាផ្លូវភេទ។ បន្ទាប់មកនៅក្នុងឆ្នាំ១៩៩៥ កងកម្លាំងបូស្នី - ស៊ែប៊ី បានសម្រុកចូលទៅកាន់ទីក្រុងស្រីប្រ៊ីនីសា ហើយបានរំលោភសេពសន្ថវៈ ធ្វើទារុណកម្មស្រ្តីជនជាតិបូស្នី-មូស្លីម និងបានសម្លាប់ជាប្រព័ន្ធលើបុរស និងកុមារាពីចន្លោះ ពី ៧.០០០ នាក់ទៅជាង ៨០០០ នាក់។ រហូតមកដល់សព្វថ្ងៃនេះរណ្តៅសាកសពថ្មី និងសាកសពជនរងគ្រោះនៅតែត្រូវបានគេរកឃើញថ្មីៗ ឬក៏កំពុងស្វែងរកដោយក្រុមគ្រួសារ។

ប៉ុន្មានឆ្នាំក្រោយមក អំពើប្រល័យពូជសាសន៍លើកដំបូងនៃសតវត្សរ៍ទី២១ បានកើតឡើង នោះគឺអំពើប្រល័យពូជសាសន៍នៅដាហ្វួ ដែលបណ្តាលឲ្យមានមនុស្សស្លាប់យ៉ាងតិច ៤ សែននាក់ និងបានផ្លាស់ទីលំនៅជាង ៣ លាននាក់។ ដើម្បីអាចទប់ស្កាត់អំពើប្រល័យពូជសាសន៍ យើងទាំងអស់គ្នាត្រូវមានទំនួលខុសត្រូវក្នុងការចងចាំ និងបន្តរក្សាការចងចាំដោយធ្វើការចែករំលែកចំណេះដឹង ធ្វើការស្រាវជ្រាវរៀនសូត្រ និងបន្តបង្រៀនដល់មនុស្សជំនាន់ក្រោយ។ ការចងចាំអំពីអំពើប្រល័យពូជសាសន៍ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍គួរតែមានការចូលរួមពីគ្រប់កម្រិតនៃសង្គម និងនៅក្នុងកម្រិតមួយដែលសមស្រប ដោយចាប់ពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់កំពូលរបស់រដ្ឋាភិបាល។ នៅក្នុងថ្នាក់មូលដ្ឋាន ប្រធានសហគមន៍ចាំបាច់ត្រូវប្រយ័ត្នអំពីអ្វីដែលកំពុងកើតឡើងនៅក្នុងសហគមន៍ និងធ្វើអន្តរាគមន៍ក្នុងពេលវេលាសមស្របនៅពេលណាដែលមានសញ្ញាព្រមាន ព្រោះអំពើប្រល័យពូជសាសន៍ និងអំពើឃោរឃៅមិនកើតឡើងដោយឯកឯងនោះទេ។ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលអាចនឹងបង្កើតកម្មវិធីផ្សព្វផ្សាយដល់ប្រជាជនជាពិសេសយុវជនជំនាន់ក្រោយ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសារសំខាន់នៃសន្តិភាព ការអត់ឱន និងតម្លៃនៃលទ្ធិប្រជាធិបតេយ្យ ក្នុងពេលនោះដែរក៏និយាយប្រឆាំងនឹងការរើសអើងជាតិសាសន៍ និងការ



មេដឹកនាំខ្មែរក្រហមនៅព្រលានយន្តហោះអន្តរជាតិពោធិ៍ចិនតុង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្អប់ខ្ពើម។ ជាងនេះទៅទៀត សាលារៀនអាចបង្កើតកម្មវិធីសិក្សាដែលរួមបញ្ចូលប្រធានបទអំពីលទ្ធិប្រជាធិបតេយ្យ យុត្តិធម៌ និងអំពើឃោរឃៅសម្រាប់បង្រៀនសិស្សនៅក្នុងកម្រិតណាមួយដែលសមស្រប និងដើម្បីជំរុញឲ្យមានការពិភាក្សាអន្តរជំនាន់ សាលារៀនក៏អាចបង្កើតកម្មវិធីដែលអាចឲ្យសិស្សនិយាយជាមួយអ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍។ រដ្ឋាភិបាលត្រូវតែដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារអំពើប្រល័យពូជសាសន៍។ ដូចលោកអាដាម៉ា ឌីង ទីប្រឹក្សាពិសេសរបស់អង្គការសហប្រជាជាតិបានមានប្រសាសន៍ថា "គ្មានសង្គមណាដែលរួចផុតពីអំពើឧក្រិដ្ឋកម្មឃោរឃៅ



និងកត្តាហានិភ័យឡើយ មានតែការការពារដែលប្រព្រឹត្តទៅទាន់ពេលវេលា និងរឹងមាំប៉ុណ្ណោះ ដែលអាចធ្វើឲ្យសង្គមមួយមានសុវត្ថិភាព និងស្ថិរភាព"។ រដ្ឋាភិបាលចាំបាច់ត្រូវតែគោរពតាមអនុសញ្ញាស្តីពីការការពារ និងការដាក់ទណ្ឌកម្មឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងជំរុញឲ្យមានការផ្តល់សច្ចាប័នជាសកលនៃអនុសញ្ញានេះ។ តាមរយៈការផ្តល់សច្ចាប័ន រដ្ឋាភិបាលនឹងអាចទទួលបានការគាំទ្រសម្រាប់កិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តកាតព្វកិច្ចនៅក្រោមអនុសញ្ញា យន្តការដើម្បីតាមដានគណនេយ្យភាពសម្រាប់ការការពារអំពើឃោរឃៅ និងការបណ្តុះបណ្តាលស្តីពីការការពារនៅថ្នាក់ជាតិឬថ្នាក់តំបន់។ ជាចុងក្រោយខ្ញុំពិតជាយល់ស្រប នឹងអ្វីដែលលោក អាដាម៉ា ឌី បានសរសេរនៅក្នុងរបាយការណ៍របស់លោកទៅកាន់អង្គការសហប្រជាជាតិថា អាទិភាពខ្ពស់បំផុតរបស់លោកនៅក្នុងអំឡុងពេលកាន់ដំណែងគឺ "ដើម្បីប្រែក្លាយគំនិតនៃការការពារអំពើប្រល័យពូជសាសន៍ដែលជាបទដ្ឋានអន្តរជាតិទៅជាការពិតជាក់ស្តែងដែលអាចត្រូវបានអនុវត្តនៅថ្នាក់ជាតិ និងកម្រិតតំបន់"។

«ផេះផង់ធូលី»

# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# ឡៅ ស៊ុនថារ៉េត ៖ សិស្ស

ខ្ញុំកើតនៅក្នុងគ្រួសារថ្នាក់កណ្តាលមួយ ហើយយើងមានឡាន។ ឪពុករបស់ខ្ញុំឈ្មោះ ឡៅ ឆេង ស៊ិន ធ្វើការនៅមន្ទីរពិសោធន៍នៃមន្ទីរពេទ្យឯកជនមួយកន្លែងក្នុងទីក្រុងភ្នំពេញ ហើយទទួលបានប្រាក់ខែពី៦ ទៅ៧ពាន់រៀលក្នុងមួយខែ។ ប្រាក់ខែរបស់គាត់ខ្ពស់សមល្មម ដូច្នេះក្មួយប្រុស និងក្មួយស្រីរបស់គាត់បានមករស់នៅជាមួយយើង។

នៅពេលខ្ញុំធំដឹងក្តី ខ្ញុំបានជ្រើសរើសសកលវិទ្យាល័យដែលខ្ញុំប្រាថ្នាចង់ទៅរៀន ព្រោះមិនមានមនុស្សច្រើនទេដែលប្រឡងជាប់ថ្នាក់វិទ្យាល័យ។ ដូច្នេះ បន្ទាប់ពីខ្ញុំបានបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យក្នុងឆ្នាំ១៩៧១ ខ្ញុំក៏សម្រេចចិត្តសិក្សាខាងផ្នែកឱសថសាស្ត្រ។ សញ្ញាប័ត្រដែលចេញពីសាលាដែលខ្ញុំជ្រើសត្រូវបានទទួលស្គាល់ដោយប្រព័ន្ធសិក្សាអប់រំរបស់ប្រទេសបារាំង។



ឪពុករបស់ ឡៅ សុនថារ៉េត (រូបអង្គុយ) និងកូនរបស់គាត់ ឡៅ ឆេង ស៊ិន (រូបទីពីររាប់ពីឆ្វេង) នៅខេត្តកណ្តាល ឆ្នាំ១៩៥៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

គ្រួសាររបស់ខ្ញុំមានស្រុកកំណើតនៅស្រុកស្អាង ខេត្តកណ្តាល គឺជាផ្នែកមួយនៃប្រទេសដែលត្រូវបានកាន់កាប់ដោយខ្មែរក្រហម។ បន្ទាប់ពីស្រុកស្អាងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ខ្មែរក្រហមបានកាត់ផ្តាច់ទំនាក់ទំនងរវាងស្រុកនេះជាមួយផ្នែកផ្សេងទៀតនៃប្រទេសកម្ពុជា ដែលស្ថិតក្រោមការគ្រប់គ្រងរបស់របប លន់ នល់។ បងប្អូនប្រុសស្រីរបស់ខ្ញុំខ្លះរស់នៅទីនេះ ប៉ុន្តែយើងកម្របានឃើញអ្នកទាំងនោះណាស់។ ជាពិសេស បន្ទាប់ពីចាប់ផ្តើមមានការទម្លាក់គ្រាប់បែក។

នៅពេលដែលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ ខ្ញុំកំពុងតែសិក្សានៅសកលវិទ្យាល័យ។ នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានបើកឡានទៅលេងពូរបស់ខ្ញុំនៅខេត្តកណ្តាល។ ដោយសារតែពូរបស់ខ្ញុំជាមន្ត្រីប៉ូលីសទាហាន លន់ នល់ ដែលស្គាល់គាត់បានបើកផ្លូវឲ្យ ដូច្នេះយើងអាចត្រឡប់មកទីក្រុងភ្នំពេញវិញបាន។ នៅពេលដែលយើងមកដល់ទីក្រុង យើងមិនបានទៅផ្ទះទេ ប៉ុន្តែយើងបានទៅផ្ទះបងប្អូនជីដូនមួយជីទួសវិញ។ ខ្ញុំមិនមានអីវ៉ាន់ច្រើនភ្ជាប់មកជាមួយទេ មានតែសម្លៀកបំពាក់នៅក្នុងកាតាប។

យើងធ្វើដំណើរទៅស្រុកស្អាងក្នុងអំឡុងពេលនៃការជម្លៀស។ វាមិនឆ្ងាយពីទីក្រុងភ្នំពេញប៉ុន្មានទេ ដូច្នេះយើងអាចបើកឡានទៅបាន។ នៅពេលដែលយើងមកដល់ យើងបានទុកឡានរបស់

យើងចោលនៅក្រោមដើមស្វាយ។ វានៅរហូតមកដល់សព្វថ្ងៃ ប៉ុន្តែមើលទៅមិនដូចជាឡានច្រើនជាង។ ខ្មែរក្រហមបានដោះយកសំបកកង់ឡានខ្ញុំទៅធ្វើជាស្បែកជើង ហើយបានយកម៉ាស៊ីនវាផងដែរ។

សំណាងល្អបងប្អូនបង្កើតរបស់ខ្ញុំដែលជាអ្នករស់នៅក្នុងស្រុកនោះ បានឲ្យសម្លៀកបំពាក់ និងរបស់ប្រើប្រាស់ផ្សេងៗមកយើង។ គ្រួសាររបស់យើងស្នាក់នៅក្នុងខ្ទមមួយដែលមានទីតាំងឆ្ងាយពីប្រជាជនដទៃទៀត។ នៅពេលដំបូង អង្គការមិនអនុញ្ញាតឲ្យប្រជាជនមូលដ្ឋាននិយាយមកកាន់យើង ឬរស់ក្បែរយើងទេ បើទោះបីជាបងប្អូនរបស់ខ្ញុំខ្លះ គឺជាប្រជាជនមូលដ្ឋាន។ ក្រោយមកខ្មែរក្រហមបានបន្ធូរបន្ថយខ្លះ និងបានអនុញ្ញាតឲ្យយើងដដែកគ្នាលេង។

ក្រោយមកបាន៨ខែ យើងត្រូវបានជម្លៀសចេញទៅខេត្តបាត់ដំបង។ ខ្មែរក្រហមបាននិយាយថា នៅទីនោះមានការប្រមូលផលស្រូវដ៏ច្រើនជារៀងរាល់ឆ្នាំ ប៉ុន្តែមានតែរដូវប្រូតប៉ុណ្ណោះដែលយើងមានបាយហូប។ ក្រៅពីនេះ យើងត្រូវហូបបបរ។

ប្រជាជននៅខេត្តបាត់ដំបងស្ទើរតែទាំងអស់នៅពេលនោះ គឺជាប្រជាជនដែលរស់នៅទីនោះយូរយាណាស់មកហើយ ហើយភាគច្រើនធ្លាប់ជាម្ចាស់ដីឡូត៍ធំៗ។ ប៉ុន្តែ អំឡុងពេលរបបខ្មែរក្រហមប្រជាជនទាំងនោះត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះដ៏ធំស្កឹមស្កៃរបស់ខ្លួន ទៅរស់នៅក្នុងខ្ទមជំនួសវិញ។ ពេលវេលាចេះតែកន្លងផុតទៅ ប្រជាជននៅខេត្តបាត់ដំបងក៏ដូចជាប្រជាជនថ្មីជាច្រើនដែលបានផ្លាស់ទីមកកាន់ទីនេះ អត់ឃ្លានជាបន្តបន្ទាប់។

ខ្មែរក្រហមនៅក្នុងខេត្តបាត់ដំបងមិនសូវតឹងរ៉ឹងតែងដូចនៅស្រុកស្អាងទេ។ ប្រជាជននៅបាត់ដំបង មិនបានស្លៀកសម្លៀកបំពាក់ខ្មៅគ្រប់ពេលទេ។ ពេលខ្លះប្រជាជននៅខេត្តបាត់ដំបងស្លៀកសម្លៀកបំពាក់មានពណ៌។

ឪពុកម្តាយរបស់ខ្ញុំធ្វើការនៅក្នុងកងចល័តមនុស្សចាស់។ ឪពុករបស់ខ្ញុំបានធ្វើត្បាល់កិនស្រូវ ហើយម្តាយរបស់ខ្ញុំធ្វើការនៅផ្នែករោងម៉ាស៊ីនកិនស្រូវ។ បងប្រុសរបស់ខ្ញុំឈ្មោះ សុធារ៉ា ធ្វើការនៅក្នុងកងចល័ត ប៉ុន្តែគាត់បានបាត់ខ្លួនបន្ទាប់ពីអង្គការស្នើគាត់ទៅធ្វើការនៅក្នុងព្រៃ។ គាត់ និងអតីតទាហានលន់ នល់ ម្នាក់បានលាក់អាហារខ្លះនៅទីនោះ ដោយមានគម្រោងហូបវានៅពេលដែលគាត់រត់គេចខ្លួនទៅប្រទេសថៃ។ អង្គការបានដឹងអំពីរឿងលាក់អាហារនេះ។

នៅក្នុងឆ្នាំ១៩៧៩ នៅពេលកងទ័ពវៀតណាម ចាប់ផ្តើមចូលមកក្នុងប្រទេសកម្ពុជា យោធាខ្មែរក្រហមដែលគ្រប់គ្រងនៅភូមិរបស់យើងចាប់ផ្តើមរត់គេចខ្លួន។ មួយសប្តាហ៍ក្រោយមកក្រុមគ្រួសាររបស់យើងបានចាកចេញពីភូមិ ហើយត្រឡប់ទៅភ្នំពេញវិញ។ នៅចុងបញ្ចប់ ខ្ញុំគឺជាមនុស្សដែលមានសំណាង។ បន្ទាប់ពីឆ្នាំ១៩៧៩ ខ្ញុំចាប់ផ្តើមចូលរៀនម្តងទៀត ហើយបច្ចុប្បន្ន ខ្ញុំគឺជាគ្រូពេទ្យវះកាត់ម្នាក់។

**ប៉ាង ពីច័ន្ទ និង ទេរី ខកហ្គៀល**



រូបរាប់ពីខាងឆ្វេង៖ ឡៅ សុនថារ៉ែត ជាមួយឪពុកម្តាយរបស់គាត់ នូវ ភូមសែន និង ឡៅ ឆេង ស៊ិន និងបងប្អូនបង្កើតរបស់គាត់ ឡៅ ស៊ីសុផល, ឡៅ សាវត្ថី និង ឡៅ សុធារ៉ា នៅខេត្តកណ្តាល ឆ្នាំ១៩៥៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## «ផេះផង់ធូលី»
# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ
# អែម ផល ៖ លេខាធិការ
# សា សុន ៖ អ្នកបច្ចេកទេសកុន

**រៀបរាប់ដោយ អែម ផាន**
**ប្អូនស្រីរបស់ អែម ផល៖**

*បងស្រីរបស់ខ្ញុំ ស្រស់ស្អាតណាស់ ហើយគាត់មានរាងខ្ពស់ស្រឡះជាងគេក្នុងចំណោមកូនស្រីទាំងបួននាក់នៅក្នុងគ្រួសារ។ ក្នុងចំណោមកូនទាំង ៦ នាក់ ម្តាយរបស់ខ្ញុំស្រឡាញ់បងស្រីរបស់ខ្ញុំខ្លាំងជាងគេ ហើយតែងតែយក ផល តាមទៅជាមួយនៅពេលម្តាយរបស់ខ្ញុំទៅណាមកណា។*

*កាលនៅពីក្មេង ផលបានសិក្សានៅសាលាបឋមសិក្សាគការកោង និងជាអ្នកលេងបាល់ទះ។ ផល បានឈប់រៀនត្រឹមអនុវិទ្យាល័យ ហើយផ្លាស់ទៅរស់នៅក្នុងទីក្រុងភ្នំពេញក្នុងអំឡុងឆ្នាំ ១៩៧០ ជាមួយបងប្រុសរបស់ខ្ញុំឈ្មោះ ភួង។ ភួង បានឲ្យលុយមួយចំនួនទៅ ផល ហើយផ្តល់ការងារជាលេខាធិការផ្នែកភាសាបារាំងនៅក្នុងបន្ទាយទាហាននៃក្រសួងការពារជាតិ។*

*នៅពេលកំពុងរៀននៅក្នុងវត្តដីរីស ផល បានចាប់ផ្តើមស្គាល់គ្នាជាមួយ សា សុន ដែលបានស្រឡាញ់ ផល។ បន្ទាប់មក ផល និង សុន បានស្រឡាញ់គ្នាទៅវិញទៅមក។ សុន បានសិក្សាអំពីបច្ចេកទេសកុននៅឯប្រទេសបារាំងអស់រយៈពេល២ឆ្នាំ ហើយទន្ទឹមគ្នានោះ សុន បានសរសេរសំបុត្រ និងផ្ញើមទាំងផ្ញើអំណោយឲ្យទៅ ផល ដែរ។*



*អែម ផល រូបខាងឆ្វេង និងមិត្តភក្តិ នៅទីក្រុងភ្នំពេញ ឆ្នាំ១៩៧៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*សុន បានបញ្ចប់ការសិក្សានៅក្នុងឆ្នាំ១៩៧២ បន្ទាប់មកគាត់ក៏ត្រឡប់មកប្រទេសកម្ពុជាវិញ។ សុន និង ផល បានត្រឡប់មករស់នៅនិងធ្វើការនៅក្នុងទីក្រុងភ្នំពេញបន្ទាប់ពីរៀបការរួច។ ផល ទទួលបានការងារ ខណៈពេលដែល សុន ធ្វើជាអ្នកថតរូបសម្រាប់កម្មវិធីព័ត៌មានទូរទស្សន៍នៅក្នុងក្រសួងឃោសនាការភ្នំពេញ។*

*សុន បានទំនាក់ទំនងជាសម្ងាត់ជាមួយខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៤។ សុន ត្រូវបានចាប់ខ្លួននិងដាក់គុកនៅក្នុងគុកនយោបាយដោយសារតែគាត់បានក្បត់ទៅនឹងរបប លន់ នល់។ ការឃុំឃាំងខ្លួនរបស់ សុន ត្រូវបានបោះពុម្ពផ្សាយនៅក្នុងកាសែត។ នៅពេលដែល សុន ចាប់ផ្តើមទាក់ទងជាមួយនឹងក្រុមកុម្មុយនីស ផល ក៏បានដឹងរឿងទាំងអស់នេះដែរ។ ជារឿយៗ ផល និងខ្ញុំបានទៅសួរសុខទុក្ខ សុន នៅក្នុងគុក ជាកន្លែងដែល សុន គ្មានអ្វីហូបគ្រប់គ្រាន់ និងគ្មានកន្លែងសម្រាកត្រឹមត្រូវ ឡើយ។ សុន គឺជាជាងកាត់សក់នៅក្នុងគុក។*

*នៅពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ សុន ត្រូវបានដោះលែង។ យើងទាំងអស់គ្នាធ្វើដំណើរជាមួយគ្នា និងទៅកាន់ទិសដៅតែមួយ គឺត្រឡប់ទៅកាន់ស្រុកកំណើតរបស់យើងវិញ។ នៅតាមផ្លូវ ខ្មែរក្រហមបន្តសួរសំណួរអំពីជីវប្រវត្តិរបស់យើង ហើយបងប្អូនរបស់ខ្ញុំ ៥*

នាក់ បានប្រាប់ការពិតដល់ខ្មែរក្រហម។ ប្តីរបស់ខ្ញុំ និងខ្ញុំមានគំនិតមួយថាយើងត្រូវតែកុហកខ្មែរក្រហមដើម្បីរស់។ ដូច្នេះ ប្តីរបស់ខ្ញុំបានប្រាប់ខ្មែរក្រហមថា គាត់គឺជាអ្នកធាក់ស៊ីក្លូ។ ជារៀងរាល់យប់ យោធាខ្មែរក្រហមបានមកសួរអំពីប្រវត្តិរបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនបានប្រាប់ការពិតដល់អ្នកទាំងនោះទេ។

រយៈពេលប្រហែល៣ទៅ ៤ខែក្រោយមក សុន ត្រូវបានចាប់ខ្លួន។ មុនពេល សុន ត្រូវបានចាប់ខ្លួន ខ្មែរក្រហមបាននិយាយថា ពួកគេចង់ឲ្យ សុន វិលត្រឡប់ទៅធ្វើការងារដូចពីមុននៅឯទីក្រុងភ្នំពេញវិញ។ ដោយមិនបានដឹងទាល់តែសោះថាខ្មែរក្រហមនិយាយកុហក សុន បានប្រាប់ ផល ឲ្យរង់ចាំគាត់នៅឯរការកោង។ ក្រោយមក សុន ក៏បានបាត់ខ្លួន។

ក្រោយមក អង្គការបានហៅ ផល និងកូនប្រុសទៅភ្នំពេញ។ យោធាខ្មែរក្រហមបាននិយាយថា ពួកគេចង់នាំផលទៅជួប សុន ហើយក្រោយមក ផល មិនដែលត្រឡប់មកវិញឡើយ។

បងប្អូនខ្ញុំ៣នាក់ ប្តី ប្រពន្ធ និងកូនរបស់ពួកគេ ត្រូវបានអង្គការចាប់ខ្លួនដោយសារតែមានទំនាក់ទំនងជាមួយនឹង ផល។

អែម ភួង ជាបងស្រីច្បងបង្អស់របស់យើង ដែលមានប្តីជាប៉ូលីស ក៏ត្រូវបាននាំយកទៅសម្លាប់ជាមួយនឹងក្រុមគ្រួសារនៅពេលដែលជម្លៀសទៅខេត្តព្រៃវែងដែរ។ ផល្លា ប្អូនស្រីរបស់យើង និងក្រុមគ្រួសារបានស្លាប់នៅក្នុងខេត្តពោធិ៍សាត់ ដោយសារតែអត់អាហារ។ សាមុន ប្អូនប្រុសពៅ និងជាអតីតទាហាន លន់ នល់ ក៏ត្រូវបានអង្គការសម្លាប់ដែរ។

ប្អូនប្រុសម្នាក់ទៀតរបស់ខ្ញុំឈ្មោះ អែម សាមុត ត្រូវខ្មែរក្រហមឲ្យចូលធ្វើជាយោធានៅក្នុងឆ្នាំ១៩៧៣។ ខ្មែរក្រហមបានចាប់ខ្លួន សាមុត នៅពេលរត់ទៅកាន់ទីក្រុងភ្នំពេញ ហើយដាក់នៅក្នុងគុកជំរឹសអស់រយៈពេល៣ថ្ងៃមុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥។ ខ្មែរក្រហមបានសម្លាប់ សាមុត នៅឯកោះរការកោង។ នៅសល់តែខ្ញុំម្នាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិតនៅក្នុងចំណោមបងប្អូនរបស់ខ្ញុំទាំងអស់។

នៅក្នុងឆ្នាំ១៩៨០ ប្រធានភូមិរបស់ខ្ញុំ បានធ្វើដំណើរទៅកាន់គុកទួលស្លែងនៅទីក្រុងភ្នំពេញ។ នៅពេលដែលត្រឡប់មកវិញ គាត់បាននិយាយថា គាត់បានឃើញរូបថតរបស់ ផល នៅទីនោះដោយមានស្លាកសញ្ញាមួយសរសេរថា «ស្ត្រីនៅក្នុងឃុំរការកោង ១»។ ប៉ុន្តែ ប្រធានភូមិមិនបានឃើញរូបថតបងថ្លៃរបស់ខ្ញុំឈ្មោះ សា សុន នោះទេ។ ម្តាយរបស់ខ្ញុំក៏បានទៅទស្សនាគុកទួលស្លែងដែរ ហើយនៅពេលដែលយើងត្រឡប់មកផ្ទះវិញ ម្តាយរបស់ខ្ញុំសម្រាន្តមិនលក់ និងបានធ្លាក់ខ្លួនឈឺ។ ម្តាយរបស់ខ្ញុំបានស្លាប់នៅក្នុងឆ្នាំ១៩៨៣ ព្រោះគាត់នឹករឭកដល់ ផល ខ្លាំងពេក។

អែម ផល និង សា សុន ត្រូវបានសម្លាប់នៅក្នុងគុកទួលស្លែង។ ប្រវត្តិរូបនិងចម្លើយសារភាពរបស់ សា សុន បានបញ្ជាក់ថា គាត់ធ្លាប់ធ្វើជាអ្នកផលិតខ្សែភាពយន្តនៅក្នុងក្រសួងឃោសនាការ។ គាត់ត្រូវបានចាប់ខ្លួននៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៥ និងបញ្ជូនមកគុកទួលស្លែងនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៦។ នៅទំព័រចុងក្រោយនៃចម្លើយសារភាពរបស់ សុន បានចុះនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៧៦។

អែម ផល ត្រូវបានចាប់ខ្លួននៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៧៥។ ឌុច ដែលជាប្រធានគុកទួលស្លែងបានសរសេរនៅលើចម្លើយសារភាពរបស់ ផល ថា «សួររកចម្លើយពិត និងអាសយដ្ឋានបច្ចុប្បន្ន ដើម្បីចាប់ខ្លួនមនុស្សណាដែលខ្លាំងបានឆ្លើយដាក់»។

**បាន ពីរ័ន្ត និង ទេនី ខករហ្សៀល**




សា សុន នៅប្រទេសបារាំង ឆ្នាំ១៩៧៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# រឿងពិតរបស់ខ្ញុំ

## ជីវិតក្រោយថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥

(តចប់)

ថ្ងៃ ៣រោជ រាត្រីនៅមានខែភ្លឺច្បាស់នៅឡើយខ្ញុំក៏បន្តការប្រក់ដំបូលផ្ទះខ្ញុំម្ដាងទៀតឲ្យហើយ។ ម៉ោងប្រមាណជា១១យប់ខ្ញុំប្រក់រួចៗ ខ្ញុំក៏ចុះទៅងូតទឹកដើម្បីសម្រាកៗ ដោយអត់ឯកុយផង ណាមួយហត់នឿយជាមួយការងារផង ខ្ញុំក៏ប្រះខ្លួនលើកន្ទេលស្លឹកត្នោតក្បែរអង្រឹងកូនលក់មួយភ្លឹបៗ គ្រាន់តែដេកលក់ខ្ញុំហាក់ស្រមៃឃើញមនុស្សប្រុសម្នាក់ស្លៀកពាក់ខោអាវខ្មៅបម្រុងចាប់ខ្ញុំរំលោភៗ ពេលនោះខ្ញុំមានស្មារតីស្ទុះវឹងទាញកាំបិតបន្ទោះយ៉ាងមុតដែលប្តីខ្ញុំធ្វើត្នោតកាលគាត់នៅរស់ៗ ខ្ញុំយកកាំបិតមកកាប់ជននោះៗ យកដៃរង្វួចស្រែក អូយ! ជននោះហក់ចុះពីលើខ្លួមខ្ញុំទៅ។ ខ្ញុំមើលពុំស្គាល់ជននោះដែរ ព្រោះពេលនោះមេឃមានពពកខ្មៅៗ បាំងព្រះខែធ្វើឲ្យងងឹងៗ មេឃខែនោះមិនភ្លឺប៉ុន្មានទេ ព្រោះនៅក្នុងរដូវភ្លៀងនៅឡើយដែរ។

ខ្ញុំមានអារម្មណ៍ព្រួយ លាយ ឡំនិងភ័យនឹកថានឹងមានរឿងធំដល់ជីវិត។ ខ្ញុំទៅអង្គុយយោលអង្រឹងកូនទល់ម៉ោង៤ជិតភ្លឺ ស្រាប់តែឮសូររទេះសេះកុបៗមកឈប់នៅមុខខ្ទមខ្ញុំ ហើយសំឡេងមនុស្សប្រុសៗអាយុប្រហែលជា១៧-១៨ឆ្នាំប៉ុណ្ណោះបានស្រែកហៅខ្ញុំពីខាងក្រៅខ្លាំងៗ និងគំហកៗ។

-អើ អ៊ីម៉ែអាវង!

ចុះមកជាមួយពួកខ្ញុំឆាប់ឡើង! មិនគោរពតាមអង្គការដាក់កំហិតទេឬយ៉ាងណា? ម៉េចមិនទាន់ស្គាល់ថ្នាំខ្លាំងទេឬ? ខ្ញុំចុះមកស្គាល់ជាក់ថាជាកូនប្រុសរបស់នាយគី គឺជាឈ្លបឃុំ។ អ្នកទាំងនោះបង្ខំខ្ញុំឲ្យយកកូនទៅផ្ញើយាយៗនៅរោងបាយ ហើយឲ្យខ្ញុំទៅតែម្នាក់ឯង។ ពេលនោះខ្ញុំមានទឹកចិត្តរន្ធត់ដោយឃើញក្មេងៗជំទង់ដែលជាឈ្លប់ពាក់អាវខ្មៅនិងស្ពាយកាំភ្លើងពីរដើម។

-មិត្ត! ខ្ញុំសុំយកកូនខ្ញុំទៅតាមផងព្រោះវាមានជំងឺ ពុំអាចទុកវាចោលនឹងយាយៗបានទេ! ឈ្លបទាំងពីរក៏ព្រមឲ្យខ្ញុំយកកូនទៅជាមួយ។

ខ្ញុំបានគិតជាស្រេចថា ប្រសិនឈ្លបយកខ្ញុំទៅសម្លាប់! ខ្ញុំតស៊ូស្លាប់ទាំងជាមួយកូន ព្រោះអត់ពីឪពុកទៅហើយអត់ម្ដាយទៀត តើកូនរបស់ខ្ញុំមានអ្នកណាមើលថែវា។ គ្រាន់តែខ្ញុំឡើងដល់រទេះសេះភ្លាម ឈ្លបចងស្លាបសេកខ្ញុំភ្លាម ឯកូនខ្ញុំឈ្លបពុំចងឡើយ។

រទេះសេះបរទៅមុខមួយសន្ទុះ ហើយប្រហែលជាកន្លះម៉ោងក្រោយមកខ្ញុំបានទៅដល់កន្លែងមួយ បុហៅថាមន្ទីរឃុំក្បែរផ្ទល់ទល់មុខវត្តនារាយណ៍។ ខ្ញុំស្លុតចិត្តភ្លាមព្រោះឃើញ គី អង្គុយកៅអីក្បែរខ្លួនបងប្រុសរបស់វាឈ្មោះសាក់ គឺជាគណៈឃុំមានជ័យ។

ឈ្លបបណ្ដើរខ្ញុំចុះពីរទេះសេះមកជួបគណៈឃុំ និងជួប គី។ សាក់ បើកភ្នែកធំៗដែលមានពណ៌ក្រហមសម្លក់ខ្ញុំស្ទើរស៊ីសាច់ទាំងៗ

-ម៉េច! នារីល្អ! នាងឯងហ៊ានកាប់កម្មាភិបាលបដិវត្តន៍យើងផងឬ? នាងឯងដឹងទេ នាងឯងគិញសម្លាត់ឬក៏ កា.ហេ្ស.បេ? នាងឯងត្រូវដឹងណាកង់ប្រវត្តិសាស្ត្រវិលទៅមុខហើយ បើប៉ះដៃកិនដៃ ប៉ះជើងកិនជើង ! មុខនាងឯងនេះ ប្រហែលជាប្រពន្ធពួកអា សេ.អ៊ី.អា ពីថ្ងៃមុននោះហើយបានជាចង់សម្លាប់កម្មាភិបាលបដិវត្តន៍ដ៏ល្អរបស់យើងដូច្នេះ? អា្ហ! ឆ្លើយមកមើល៍ !--

គ្រាន់តែឮពាក្យថាពួកគិញ សេ.អ៊ី.អា សម្លាប់ពីថ្ងៃមុនភ្លាមខ្ញុំភ្ញាក់ព្រើត គឺពិតជាប្តីខ្ញុំហើយដែល គេចោទថាជាគិញអាមេរិក។

-ចាស៎! មិត្តបងខ្ញុំគ្មានគំនិតដូចមិត្តបងចោទខ្ញុំទេ។ ខ្ញុំពុំទាន់និយាយបង្ហើយផង! គឺ បានឆ្លើយកាត់ភ្លាមៗ

-មិត្តបងកុំជឿ មីស្រីសាហាវនេះឲ្យសោះ!វានេះមានគំនិតអាក្រក់ណាស់ ទើបមកពីចល័តនៅវាលត្បាល់! ពេលអង្គការដាក់ទិសតម្រូវឲ្យទៅច្រូតស្រូវនៅក្រោមទំនប់ឃ្មៃ និងស្រូវ៣ខែនៅវត្តទល់ទៀត! ខ្ញុំទៅប្រាប់ តែស្រែកហៅពីខាងក្រៅផ្ទះ នារីបើកទ្វារឲ្យខ្ញុំ រួចអត់មានពាក្យអ្វីក្រៅពីថាខ្ញុំទើបមកពីវាលត្បាល់។ ឥឡូវឲ្យខ្ញុំទៅវត្តទល់ទៀត? ខ្ញុំពុំចង់ទៅសោះ សុំមិត្តឲ្យខ្ញុំនៅស្រោចដំណាំក្បែររោងបាយបានទេ? ខ្ញុំក៏ថាមិនបានព្រោះអង្គការចាត់តាំងទៅណាគឺគ្មានប្រកែកតវ៉ាឡើយ។ ស្រាប់តែនាងនោះប្រឡោតស្ទុះមកកាប់ខ្ញុំ ខ្ញុំក៏ប្រតាយជាមួយហើយវាស្រែកថាឯងយកប្តីអញទៅណា? សងប្តីអញវិញមកអាគិរច្ឆាន !

-ទេ! ទេ! មិនពិតដូចពាក្យគាត់មួលបង្កាច់ខ្ញុំឡើយមិត្តបង! ពាក្យនេះគឺជាពាក្យដោះសាអំពើអាក្រក់មកលើរូបខ្ញុំប៉ុណ្ណោះ! ខ្ញុំឯណាមានចិត្តដូចគាត់ចោទប្រកាន់ខ្ញុំនោះ។

-ឈប់និយាយ! តាសាក់គោះតុផង! ភស្តុតាងនៅនឹងភ្នែកមើលដៃអាគីវាដាច់ម្រាមពីរ នេះជាស្នាដៃអ្នកណាថាមើល៍!

-ខ្ញុំមិនមានចិត្តដូចគាត់ចោទឡើយ! ខ្ញុំបានការពារខ្លួនខ្ញុំ! ការពិតគាត់បានមកលែបខាយដាក់ខ្ញុំមុននេះប៉ុន្មានថ្ងៃមកហើយ! យប់នោះគាត់បានបម្រុងចាប់រំលោភធ្វើបាបខ្ញុំ! ខ្ញុំត្រដររួចខ្លួនហើយខ្ញុំគ្មានអីការពារខ្លួនឡើយ។ ខ្ញុំបានទាញយកកាំបិតបន្ទោះធ្វើត្នោតរបស់ប្តីខ្ញុំកាប់គាត់ទៅ! ខ្ញុំហ៊ានស្បថថាពុំដូចពាក្យគាត់បង្កាច់ខ្ញុំឡើយ!

- កម្មាភិបាលបដិវត្តន៍យើងយល់ជ្រួតជ្រាបណាស់ពីបញ្ហាមាគ៌ាដឹកនាំរបស់បក្សដ៏មហាអស្ចារ្យពុំដែលមានបុគ្គលណាមួយបង្កហេតុពីបញ្ហាខុសសីលធម៌នេះទេ នាងឯងកុំដោះសា! តាសាក់ ទះតុរួចគំហកដាក់ខ្ញុំខ្លាំងៗ។

-តាសាក់ ហៅ វ៉ាន់ ដែលជាឈ្លបមកជិតគាត់ដើម្បីខ្សឹបប្រាប់ៗ នាងឯងត្រូវតែទៅរៀនសូត្រទៀតដើម្បីឲ្យកាន់តែយល់ច្បាស់ពីមាគ៌ារបស់អង្គការ។ ប្រសិនបើកុំតែយើងយល់ថានាងឯងធ្លាប់បានជួយសង្គ្រោះប្រពន្ធយើងនោះ!

នាយគឺ កាលពីអ្នក១៧មេសា មកដល់ភូមិព្រៃស្បូវដំបូង ឆ្នាំ១៩៧៥ បានរំលោភនារី១៧មេសាពីររូបឈ្មោះធុល និង ភ្លីង ប៉ុន្តែខ្មែរក្រហមយក គី ទៅរៀនសូត្រនៅស្រុកតែមួយអាទិត្យប៉ុណ្ណោះ។ គី ពុំខ្លាចឡើយ ព្រោះគិតថាបងប្អូនអ្នក១៧ពុំហ៊ានតវ៉ាជាមួយវា។ ប្រសិនបើអ្នក១៧មេសាហ៊ាននិយាយ គីនឹងរាយការណ៍ និងយកអ្នកថ្មីនោះទៅសម្លាប់ដោយគ្មានរកខុសត្រូវឡើយ។

ភាពសាហាវព្រៃផ្សៃរបស់ គី ក៏កាន់តែធ្វើឲ្យប្រជាជនភ័យខ្លាច គី ដូចខ្លា ហើយ គី ក៏កាន់តែបានចិត្តសំដែងភាពឃោរឃៅនេះរឹតតែខ្លាំងឡើងៗ ចំពោះប្រជាជនថ្មី។

ខ្ញុំត្រូវឈ្លបចងស្លាប់សេកទៅក្រោយឲ្យដើររទេះទៅម្នាក់ឯង ដោយទុកកូនឲ្យនៅមន្ទីរឃុំដើម្បីគេយកទៅឲ្យយាយៗតាមភូមិមើលថែ។ ខ្ញុំបានយំក្រាញនៀលលោតពីរទេះសេះដែលកំពុងបរចេញតិចៗ។ តាសាក់ឃើញដូច្នេះក៏យល់ព្រមឲ្យកូនខ្ញុំទៅជាមួយដែរ។

រទេះសេះនាំរូបខ្ញុំចេញផុតពីទីកដីឃុំនារាយណ៍។ ម៉ោង៧កន្លះ ខ្ញុំត្រូវបានឈ្លបនាំខ្លួនចូលមកដល់ក្នុងស្រុកឈូក។ ឈ្លបយកខ្ញុំមកដាក់ឲ្យអង្គុយក្បែរជញ្ជាំងផ្ទះថ្មមួយ ដែលខ្មែរក្រហមដាក់អំបិល និងមានយុទ្ធនារីៗ៨-១០នាក់ យុទ្ធជន៨-១០នាក់ដែរ។ ឈ្លបឲ្យនាងខ្ញុំនៅទីនោះដោយស្រាយចំណងចេញ។ ថ្ងៃត្រង់យុទ្ធនារីបានយកបាយជ្រាយៗមួយចានឲ្យខ្ញុំហូប។ បន្ទាប់មកឈ្លបចាប់ផ្តើមសួរខ្ញុំតាមសេចក្តីរាយការណ៍ពីឃុំមក។ ខ្ញុំត្រូវពួកកងទ័ពស្រុកម្នាក់សប្បុរខ្មៅមាឌមាំ ឈ្មោះ អាហម វាយខ្ញុំនឹងរំពាត់សម្រាប់វាយគោក្របី។ ខ្ញុំឈឺចាប់ស្ទើរផុតដង្ហើម។ ខ្ញុំពុំចង់រស់ទេ ខ្ញុំបន់ស្រន់ឲ្យខ្ញុំស្លាប់ទៅតាមប្តីរបស់ខ្ញុំ។ ពេលឈ្លបវាយខ្ញុំ កូនប្រុសខ្ញុំយំរត់ឱបខ្ញុំ។ ខ្ញុំខំឱនកុំឲ្យរំពាត់ត្រូវកូនខ្ញុំ ព្រោះកូនខ្ញុំនៅតូចណាស់ និងមានជំងឺទៀតផង។

ខ្ញុំទទួលរងទារុណកម្មនៅស្នាក់ការស្រុកឈូកអស់រយៈពេលមួយអាទិត្យ ទើបឈ្លបបញ្ជូនខ្ញុំទៅគុកធំនៅល្អាងក្បែររោងចក្រស៊ីម៉ងចក្រីទីង។

## ល្អាងភ្នំជាវិមានខ្ញុំ

មកដល់ល្អាងភ្លាម ខ្ញុំភ័យរន្ធត់ដោយឃើញអ្នកទោសពី ៣០ ទៅ៤០ នាក់នៅក្នុងបន្ទប់មួយ។ អ្នកទោសខ្លះដេក ខ្លះអង្គុយ និងមានតែស្បែកដណ្តប់ឆ្អឹង។ ឆ្មាំគុកឲ្យចូលក្នុងបន្ទប់ ហើយ

ដាក់ខ្នោះជើងទាំងពីរ ឯកូនខ្ញុំឈ្លបពុំដាក់ខ្នោះឡើយ។

មុនពេលឈ្លបនិងឆ្មាំគុកចាកចេញ ក៏បានចាក់សោបន្ទប់វិញ។ អ្នកទោសខ្លះងើបមើលមកខ្ញុំ ខ្លះខ្សិបខ្សៀបៗតិចៗសួរខ្ញុំ តើមានរឿងអ្វីបានជាមកដល់ទីនេះ។ ខ្ញុំបានប្រាប់តាមដំណើររឿងរហូតមក ប៉ុន្តែពុំហ៊ាននិយាយឮទេព្រោះខ្លាចឈ្លបលួចស្តាប់។ យើងពុំហ៊ាននិយាយ និងសួរគ្នាច្រើន ឬជួយអ្វីគ្នាបានឡើយព្រោះជាប់ខ្នោះរៀងខ្លួន។ ពេលទៅធ្វើការ អ្នកទោសថ្មីត្រូវដាក់ប្រវ៉ាក់ដៃឯអ្នកទោសចាស់ពុំដាក់ទេ។

ពេលព្រឹកឆ្មាំគុកបានបញ្ជូនខ្ញុំទៅធ្វើការនៅជើងភ្នំ គឺកាប់គាស់ដើមឈើរំលើងគល់ឈើធំៗ អូសនង្គ័លរនាស់ជំនួសគោ។ ឆ្មាំគុកចាប់អ្នកទោសទឹមប្រៀបដូចជាសត្វធាតុឲ្យអូសរនាស់កៀរដីព្រៃឲ្យស្អាតដើម្បីដាំដំឡូងមី។ ថ្ងៃមួយខ្ញុំនឹកអាសូរលោកតាចាស់ម្នាក់ដែលជាជនជាតិចិន។ ប្រជាជនតែងហៅគាត់ថា «ចិនគោជាន់ៗ» ។ តាដែលជាជនជាតិចិនអាយុប្រហែលជាង៦០ឆ្នាំ។ ខ្មែរក្រហមចាត់តាំងគាត់ឲ្យអូសរនាស់ជាមួយខ្ញុំ។ តានោះគឺជាអ្នកទោសដែលជាប់ពាក់ព័ន្ធជាមួយកូនគាត់លួចរត់ពីភូមិទៅស្រុកយួន។ មិនបានប៉ុន្មានដុំផងគាត់ដួលដាច់ខ្យល់ស្លាប់ទៅ ដោយគាត់មានតែស្បែកដណ្តប់ឆ្អឹងប៉ុណ្ណោះ។

ខ្ញុំរស់នៅទាំងភ័យព្រួយ ព្រោះមួយយប់ៗមេគុកគេតែងដើរចូលមករួចហៅឈ្មោះអ្នកទោស ៤-៥ នាក់មួយយប់ៗ យកទៅបាត់។ មេគុកដើរបានចម្ងាយប្រហែលជា ១០០ម៉ែត្រក៏ឮសូរសំឡេងស្រែកលឿយៗ អូយៗ! នេះគឺជាសំឡេងដង្ហើយលឿយៗ កណ្តាលអធ្រាត្រ ពេលគេនាំអ្នកទោសទៅវាយចោល។

ពេលចេញទៅធ្វើការម្តងៗ ខ្ញុំនិងអ្នកទោសទាំងអស់តែងប្រទះក្បាលខ្មោច ដែលឆ្មាំគុកវាយសម្លាប់អ្នកទោសរួចកប់រាក់ៗ។

ជួនកាលយើងឃើញដៃឬជើងជនរងគ្រោះហើម ធុំក្លិនអសោច ព្រោះសាកសពនៅថ្មីៗ។ រាត្រីមួយរឹតតែគួរឲ្យខ្ញុំព្រឺព្រួចនិងភ័យខ្លាចទៀត ពេលឈ្លបបានមកហៅគ្រូបង្រៀនម្នាក់ឈ្មោះគ្រូលាប ទៅសម្លាប់។ ប្រាំប្រាំមួយថ្ងៃក្រោយ ឈ្លប មកប្រពន្ធគាត់ឈឺពោះគ្រប់ខែឆ្លងទន្លេ ខ្ញុំនិងអ្នកទោសដូចគ្នាមិនដឹងជាជួយរបៀបណាឡើយ។ មួយសន្ទុះក្រោយមកស្រាប់តែឈ្លបក្មេងៗ ២នាក់វាចូលមក

- អ៊ី ឯងយ៉ាងម៉េច? បានជានៅពុំស្ងៀម?
- អូនអើយ អ៊ីឈឺពោះណាស់! ជួយរកឆ្មបឲ្យអ៊ីផង! គាត់នៅឯណា? អ៊ីទ្រាំសឹងពុំបានទេ អូន!
- អើបើឈឺខ្លាំងទ្រាំចាំបន្តិច ប្រធានធំមកហើយ!

គាត់និយាយបណ្តើរទ្រាំខាំមាត់ ដោយកូននៅក្នុងផ្ទៃគាត់បម្រះចង់ឃើញពន្លឺព្រះអាទិត្យនឹងគេ។ រំពេចនោះមេគុកធំមកដល់ខ្សិបខ្សៀបដាក់ត្រចៀកឈ្លបទាំងពីរ។ យើងពុំអាចស្តាប់បានថាតើគេចង់និយាយពីអ្វីឡើយ។

-អើបើឈឺខ្លាំង។ មកទៅឯណោះមានយាយម៉ប!

គ្រាន់តែឮពាក្យមានយាយម៉បខ្ញុំក៏ជួយតេក្រអរជាមួយគាត់ដែរ។ ឈ្លបបណ្តើរគាត់ចេញទៅក្រោយគុកបានចម្ងាយប្រមាណ ៥០-៦០ម៉ែត្រក្រោមភ្លើងចន្លុះផ្លុងៗ។ ពេលទៅឆ្ងាយបន្តិចស្រាប់តែឮសូរសំលេងស្រែកអង្វរ។

-ពុទ្ធោអើយកុំធ្វើបាបខ្ញុំអី! អូយ! មួយសន្ទុះក៏ស្ងាត់បាត់សំឡេងឈឹង ដែលបញ្ជាក់ថាឈ្លបវាយសម្លាប់គាត់។

ខ្ញុំនិងអ្នកទោសដែលនៅសល់ប្រហែលជា ៣០នាក់ ដែលពេលខ្ញុំចូលដល់ដំបូងមានចំនួនជាង ៤០ នាំគ្នាសម្ងំពុំហ៊ាននិយាយសួរគ្នា ឬសម្តែងការអាណិតឡើយម្នាក់ៗ។ ពេលយប់ខ្ញុំពុំបានដេកស្កប់ស្កល់ឡើយដោយសារការភិតភ័យ ម្យ៉ាងខ្ញុំដេកផ្ងាល់ឥដ្ឋ ហើយជើងជាប់ខ្នោះ។ ចំណែកកូនប្រុសរបស់ខ្ញុំដេកនៅលើទ្រូងរបស់ខ្ញុំ។ មួយយប់ៗកូនរបស់ខ្ញុំរាកជាប់រហូតព្រោះវាលាប់កញ្ច្រិលកាន់តែខ្លាំងឡើងៗ។ លាមកវាមានសំបោរលាយឈាមស្រស់ប្រឡាក់សំពត់អាវខ្ញុំធុំក្លិនឆ្អេះឆ្អាបពេញខ្លួន។ ខ្ញុំខំស៊ូទ្រាំឲ្យតែកូនរបស់ខ្ញុំបានដេកស្រួល។ ព្រឹកឡើង ឆ្មាំគុកបានដោះលែងខ្ញុំឲ្យទៅធ្វើការ ទើបខ្ញុំបានផ្លាស់សំពត់និងបោកខោអាវហាល។

រូបខ្ញុំស្គមកំព្រឹងមានតែស្បែកនិងឆ្អឹង។ រយៈពេលជិតពីរខែអ្នកទោសនៅសល់តែដប់ប្រាំបីនាក់ប៉ុណ្ណោះ។

## របបបីឆ្នាំប្រាំបីខែម្ភៃថ្ងៃត្រូវរលត់

ថ្ងៃទី២០ខែវិច្ឆិកា ឆ្នាំ ១៩៧៨ ស្នូរកាំភ្លើងបានលាន់ឮលឿយៗនៅខាងកើតព្រំប្រទល់ខេត្តកំពត គឺម្តុំដានគោម និងសំឡាញ ក្នុងស្រុកអង្គរជ័យ១៣។

ពេលនោះនៅសល់អ្នកទោស១៣នាក់រួមទាំងរូបខ្ញុំ។ ខ្ញុំពុំទាន់ដល់ពេលដែលឈ្លបយកទៅសម្លាប់ឡើយ ហេតុតែបុណ្យកុសលទេព្តា និងគុណមាតាបិតាតាមថែរក្សា។ មានក្មេងកងទ័ពម្នាក់ដៃកាន់សោគុកមួយចង្កោមស្ទុះមកចាក់សោគុកបានបីបន្ទប់ រួចហើយនិយាយថា:

-អ៊ី អ៊ំណានៅស្រុកភូមិណាទៅស្រុកហ្នឹងទៅ។ ខ្ញុំអាណិតចាក់សោឲ្យរួចខ្លួន ប្រញាប់ចេញឲ្យឆាប់ៗ ប្រយ័ត្នប្រធានគុកមកទាន់គឺពុំទុកជីវិតឲ្យទេ។ ឆាប់ៗមេគុកមកដល់ឥឡូវហើយ! ចំណែកឯខ្ញុំ ខ្ញុំទៅរកម៉ែឪខ្ញុំឯខេត្តកំពង់ឆ្នាំង! យួនវាបុកមកជិតដល់ហើយ! កងទ័ពយើងពុំដឹងជាឈ្នះឬទប់ជាប់ដែរឬយ៉ាងម៉េចណាទេ!

គ្រាន់តែឮពាក្យក្មេងនេះនិយាយភ្លាមខ្ញុំ ហាក់ដូចជាកើតម្តងទៀត។ ខ្ញុំអរគុណស្ទើរលុត ជង្គង់ថ្វាយបង្គំក្មេងនោះ៖

-អូន! អ៊ុំអរគុណក្មួយណាស់! អ៊ុំលាក្មួយហើយ! សូមក្មួយទៅឲ្យបានសុខ។

-អរគុណអី! មេគុកមកឥឡូវហើយ ខ្ញុំពុំចង់បានអរគុណអីទេ! ទៅ! ទៅ! នាំគ្នាទៅចុះ! ក្មេងចាក់សោបាន ៣ បន្ទប់ប៉ុណ្ណោះ ព្រោះគ្មានសោទៀត។ ក្មេងនោះក៏ស្ពាយស្បោងខោអាវរត់ចេញយ៉ាងប្រញាប់។

ខ្ញុំពកូនប្រុស ខ្ញុំរត់ចេញពីគុកដោយរីករាយលាយឡំទឹកភ្នែក ព្រោះខ្ញុំសង្ឃឹមថា ពិតជាបានជួបអ្នកមានបុណ្យណាមួយមករំដោះរាស្ត្រប្រជាជនកម្ពុជាអោយផុតពីវាលពិឃាតដ៏សាហាវនេះ។ ខ្ញុំដើរកាត់ព្រៃកាត់វាលស្រែ ហើយនៅក្នុងភូមិគ្មានមនុស្សរស់នៅឡើយ។

ខ្ញុំរត់ជងពកូនរយៈពេលពីរយប់ពីរថ្ងៃ ទើបខ្ញុំដាច់ចិត្តត្រឡប់ថយមកភូមិវិញ ក្រែងលោបានជួបអ្នកភូមិខ្លះដែលមានចិត្តល្អ និងអាលបានរួមដំណើរជាមួយគ្នា។

ពេលខ្ញុំចូលមកដល់មន្ទីរពេទ្យពស់ពងដែលកូនខ្ញុំធ្លាប់មកដេកព្យាបាលស្រាប់តែស្ងាត់ឈឹង។ ខ្ញុំឃើញអ្នកជំងឺខ្លះដើរពុំរួចត្រូវបានទុកចោលឯពេទ្យបាននាំគ្នារត់ឡើងភ្នំតាមកងទ័ពខ្មែរក្រហមអស់ហើយ។ ខ្ញុំពកូនរត់ត្រឡប់ឡើងភ្នំតាមប្រជាជនក្រែងលោបានជួបអ្នកភូមិ។ ខ្ញុំសុំបាយកងទ័ពខ្មែរក្រហមដែលជានារីស្នាក់ការជញ្ជូនបាយឲ្យទ័ពសមរភូមិមុខឲ្យកូនហូប។

អ្នកស្រុកភូមិបានរត់ប្រសាច អ្នកភូមិខ្លះមានរទេះគោដឹកស្បៀងអង្ករនិងខ្ទះ។ អ្នកភូមិខ្លះធ្វើការអូស ឯនាងខ្ញុំពុំមានអ្វីទេ គឺរើសបានកញ្ជើរមួយដាក់កូនរែកម្ខាងៗ ដាក់ខោអាវរែករត់តាមគេឯង។ ខ្ញុំមានការភ័យព្រួយ ព្រោះគ្រាប់ផ្លោងធ្លាក់ភឹងៗហុយដីទ្រលោមជួនកាលត្រូវប្រជាជនរងរបួស។ អ្នករបួសត្រូវបានសែងដាក់រទេះនិងមានឈាមដោកគួរឲ្យអាណោចអាធ័ម។ ប្រជាជនខ្លះរងរបួសខ្លាំងក៏ស្លាប់ ហើយបងប្អូនក៏ទុកខ្មោចចោល ហើយរត់ទៅទៀតដើម្បីរស់រៀងៗខ្លួន។

យប់ម៉ោង៩ ដោយអស់កម្លាំងពេក ហើយឮថានៅខាងមុខមានមន្ទីរពេទ្យនៅវត្តស្រះចាស់ក្នុងស្រុកស្រែក្នុង នាងខ្ញុំក៏នាំកូនចូលទៅដេកនៅទីនោះ។ ពេលនោះក្នុងបន្ទប់មួយៗគ្មានមនុស្សរស់នៅទេ។ នៅក្នុងបន្ទប់ងងឹតមើលពុំច្បាស់ទេ ព្រោះគ្មានភ្លើងបំភ្លឺ គឺមានតែពន្លឺព្រះខែប៉ុណ្ណោះ។ នាងខ្ញុំដាក់កូនឲ្យដេក រួចដើររកទឹកក្បែរពេទ្យដែលមានត្រពាំងមួយ។ ខ្ញុំផ្ងូតទឹករួចចូលមកដេកក្បែរកូនវិញដោយពុំនឹកស្មានថាមានមនុស្សប្រហែល ៣-៤ នាក់នៅលើគ្រែដេកឡើយ។ ខ្ញុំនិងកូនក៏លង់លក់ទៅដោយអស់កម្លាំងទោះជាសត្វសង្កើចខាំយ៉ាងណាក៏ពុំរវល់ដែរ។

លុះព្រលឹមឡើងស្រាងៗម៉ោងជិតប្រហែល៦ ទើបមានមនុស្សរត់បណ្តើរៗបន្តគ្នាទៀត សំដៅទៅភ្នំតាមការបន្ទំ និងកៀរប្រមូលរបស់ខ្មែរក្រហម។ ពេលភ្លឺទើបខ្ញុំដឹងថាមនុស្សដេកលើគ្រែអស់នោះ គឺជាសាកសពដែលស្លាប់ដោយសារជំងឺធ្ងន់ធ្ងរហើយពេទ្យទុកចោល។

ខ្ញុំបានជួបជាមួយបងធម៌ខ្ញុំម្នាក់ឈ្មោះ យន។ គាត់ជាអ្នក១៧ដូចខ្ញុំដែរ ចំណែកបងប្អូនរបស់គាត់ គឺជាអ្នកមូលដ្ឋាន។ គាត់និងខ្ញុំស្រឡាញ់រាប់អានគ្នាណាស់។ ខ្ញុំបានមកជួបគាត់នៅទំនប់រំលេច កន្លែងខ្ញុំធ្លាប់ធ្វើការមុនពេលប្តីខ្ញុំត្រូវខ្មែរក្រហមសម្លាប់។ ខ្ញុំរត់បណ្តើរក្រាបគ្រាប់បណ្តើរព្រោះខ្លាចគ្រាប់។ ខ្ញុំដើរស្ទុះសំបកឈើដាំឲ្យកូនផឹកបណ្តើរ។ ខ្ញុំមកជួបជុំគ្នា រកប្រធានក្រុម ប្រធានភូមិ ពេលជួបគ្នាហើយ ប្រធានក្រុមនិងភូមិទាំងអស់ដែលដឹងរឿងនាងខ្ញុំត្រូវខ្មែរក្រហម

បញ្ជូនទៅគុកល្អាង បានហៅខ្ញុំទៅព្រមានស្ងាត់ៗទៀតថាកុំឲ្យនិយាយពីទិដ្ឋភាពនៅកន្លែងគុកនោះប្រាប់អ្នក ១៧ដូចគ្នា។

ខ្មែរក្រហមនៅតែឆ្មៀតប្រើពាក្យដូច្នេះ ហើយប្រធានភូមិថ្មីឈ្មោះ ពូម៉ែន ដឹកនាំប្រជាជន ១៧ ចុះមករំលេច ភ្នំបាក់នឹម រួចចុះមកនារាយណ៍ ដើម្បីបញ្ជូនស្រូវឡើងភ្នំទៀត។ ចំណែកប្រជាជនមូលដ្ឋានខ្មែរក្រហមឲ្យនៅដាំបាយហូបរួមដដែល។ កូនរបស់ខ្ញុំនិងក្មេងៗឯទៀត គឺទុកឲ្យយាយមើលថែ។ ប្រជាជននិងខ្ញុំ បានមករែកស្រូវខ្លះទូលឡើងភ្នំក្នុងមួយថ្ងៃបានពីរជើងទាំងបន្ទុំ និងមានគ្រាប់ផ្លោងធ្លាក់គ្រាំងក្បែរខ្លួន គួរឲ្យរន្ធត់ណាស់ ចំណែកគ្រាប់កាំភ្លើងដៃព្រួសរដូចលាជផ្ទុះ។ ខ្ញុំជញ្ជូនស្រូវរយៈពេលបីថ្ងៃទាំងស្លុតចិត្ត ព្រោះកងទ័ពរណសិរ្សផ្លោងស្កាត់ផ្លូវកុំប្រជាជនឡើងភ្នំតាមខ្មែរក្រហម។ ប្រជាជនមូលដ្ឋានបានរស់ប្រាសអាយុ ចោលក្មេងៗអស់។ ពេលខ្ញុំទូលស្រូវមកដល់ខ្ញុំយំរត់ឱបកូនខ្ញុំ ដែលខ្មែរក្រហមទុកចោល គឺនៅសល់យាយ ១៧ ម្នាក់នៅឱបកូនខ្ញុំ និងកូនបងយន។

-ម៉ែៗ! ខ្ញុំខ្លាចណាស់

-ម៉ែអាវងទៅតាមខ្ញុំទេ ខ្ញុំទៅតាមក្រុមហើយទើបខ្ញុំមានបាយហូបណា។ មួយខ្ញុំខ្លាចគេសម្លាប់ខ្ញុំណាស់ពេលយើងមិនទៅភ្នំនឹងគេ។

-យាយកាបិតៗ ព្រោះកូនគាត់ឈ្មោះបិត។ យាយទៅមុនខ្ញុំចុះ ខ្ញុំអរគុណយាយដែលស៊ូរង់ចាំខ្ញុំពុំហ៊ានទៅចោលកូនខ្ញុំ ខ្ញុំរកអ្នកណាចិត្តដូចយាយពុំបានទេ!

យាយកាបិត ទៅជាមួយកូនចិញ្ចឹមគាត់បាត់ស្រមោលទៅ។ ប្រជាជនបានរត់ឈូរ ខ្លះមានសែងអ្នករបួស ខ្លះត្រូវគ្រាប់ ខ្លះសែងឪពុកម្តាយ យាយតាចាស់ៗ ដើរពុំរួច។ ដល់ស្ថានភាពកាន់តែយ៉ាប់ ហើយអ្នកខ្លះដាច់ចិត្តចោលកូន ឪពុកម្តាយចាស់ពេញព្រៃ ដោយតស៊ូលះបង់ទៅតាមខ្មែរក្រហម។ ខ្ញុំកំពុងពិចារណាជាមួយបង យន កូនខ្ញុំយំរកបាយ។ ខ្ញុំសម្លឹងឃើញរោងបាយយុទ្ធនារីស្នាក់ការដាំដាក់ស្នុកយកឲ្យទ័ពសមរភូមិមុខ ខ្ញុំក៏ផ្ញើកូនបងយនស្ទុះទៅសុំបាយយុទ្ធនារីកងទ័ព។ ខ្ញុំដួសបាយដាក់ពេញស្នុករួចហើយ ខាងយុទ្ធនារីទ័ពដេញខ្ញុំចេញជាប្រញាប់ ខ្លាចព្រោះខ្លាចមេមកទាន់ ហើយកៀរទៅលើ។ គ្រាន់តែខ្ញុំយកបាយចេញផុត និងមកលេណដ្ឋានដែលកូនខ្ញុំកំពុងពួនក៏ឮសំឡេង

វ៉ឺត! គ្រាំង!!

ស្មើរបែកក្រដាសត្រចៀក។

អាយុខ្ញុំថ្លៃ ទឹកដោះម្តាយថ្លៃ គ្រាប់ផ្លោងមួយគ្រាប់ធ្លាក់ចំខ្ទះបាយដែលខ្ញុំទើបដួសរួច។ ខ្ញុំញ័រខ្លួនទទ្រើក ហើយក្រាបពីលើកូនក្នុងលេណដ្ឋាន។ លុះស្ងាត់គ្រាប់ទើបនាំកូនរកទឹកហូបនិងងូត។ ទោះរត់លូនពិបាកយ៉ាងណាក៏ខ្ញុំពុំភ្លេចដាំថ្នាំឲ្យកូនផឹកដែរ ទាល់តែកូនរបស់ខ្ញុំបានជាសះស្បើយ។

កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាសហការជាមួយកងទ័ពវៀតណាមបានសម្រុកទៅមុខរហូតបានកាន់កាប់ស្ទើរគ្រប់ខេត្ត និងក្រុងភ្នំពេញ។ នាងខ្ញុំបានឮសេចក្តីអំពាវនាវរបស់ទ័ពរណសិរ្សសង្គ្រោះជាតិកម្ពុជាប្រកាសតាមវិទ្យុភ្នំពេញ និងតាមមេក្រូឲ្យវិលត្រឡប់មកកាន់ភូមិស្រុកកំណើត ខ្ញុំក៏បានសម្រេចចិត្តត្រឡប់ថយក្រោយវិញ ដោយលែងជឿតាមការឃោសនារបស់ខ្មែរក្រហម។

## រីករាយថ្ងៃទី ៧ មករា

ខ្ញុំដើរតាមផ្លូវបណ្តើរ ផាកខាងម្ខាងផ្លូវឃើញខ្មោចស្លាប់តាមផ្លូវដោយសារគ្រាប់ផ្លោងផង និងគ្រាប់ដៃផង។ ខ្មែរក្រហមបានសម្លាប់ប្រជាជនខ្លះដោយចោទថា ពុំទៅតស៊ូទៅតាមខ្លួននៅព្រៃភ្នំទៀត។ ខ្ញុំបានរែកកូនដើរចុះមកដល់តាមផ្លូវនៅវត្តនារាយណ៍ក៏ឮសូរសំឡេងកងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងទ័ពវៀតណាមស្រែកឃោសនាតាមមេក្រូឲ្យប្រជាជនវិលត្រឡប់មកស្រុកភូមិវិញ។ កុំចាញ់ឧបាយកលរបស់របបប្រល័យពូជសាសន៍ដែលចោទថា យួនអាវកវះពោះញាត់ស្មៅ ឬធ្វើអ៊ីយេវយេវឡើយ។

ខ្ញុំបានមកដល់ភូមិព្រៃស្បូវដែលនាងខ្ញុំរស់នៅកាលពី៧៥ ជាមួយបងធម៌របស់ខ្ញុំ ព្រោះខ្ញុំពុំទាន់មានគោលដៅច្បាស់ឡើយ។ នៅតាមភូមិមានប្រជាជនចាស់ថ្មីប្រហែលជា១០គ្រួសារចុះមក ចំណែកប្រជាជនខ្លះនៅចាញ់ការឃោសនារបស់ខ្មែរក្រហមនៅឡើយ។

មកដល់ភូមិភ្លាមខ្ញុំស្រណោះដល់ប្តីរបស់ខ្ញុំ ព្រោះឃើញគ្រួសារអ្នកផ្សេងនៅជុំប្តីប្រពន្ធ។ ពេលខ្ញុំនឹកដល់

គាត់ពេលណា ទឹកភ្នែកខ្ញុំហូរមកជានិច្ច ព្រោះនៅតែប៉ុន្មានខែទៀតសោះ គាត់បានរស់នឹងដែរ។

ខ្ញុំបានមករស់នៅភូមិប្រាល ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត ហើយបន្ទាប់មកបានធ្វើដំណើរមក រកបងប្អូននៅភ្នំពេញ។ ខ្ញុំបានជួបបងស្រី ប្អូនស្រីបីនាក់ទៀត ចំណែកប៉ាម៉ាក់ខ្ញុំ ព្រមទាំងប្អូនបួននាក់ទៀតត្រូវខ្មែរក្រហមសម្លាប់នៅឆ្នាំ១៩៧៦។ ប្អូនខ្ញុំបានរៀបរាប់ពីទុក្ខសោក ដែលបនប្រល័យពូជសាសន៍បានយកឪពុកម្តាយខ្ញុំទៅសម្លាប់ថា៖

នៅឆ្នាំ ១៩៧៥ ពេលដែលប៉ាខ្ញុំត្រូវជម្លៀសចេញពីក្រុងកំពង់សោម គាត់ត្រូវបានអង្គការឲ្យទៅនៅឃុំស្ទាច់ដែង ស្រុកព្រៃនប់ ខេត្តកំពត (ក្រោយមកខេត្តកំពង់សោម)។ ពេលនោះឪពុកខ្ញុំបានបែកកូនពីរនាក់ គឺខ្ញុំមានប្តី និងបងស្រីរៀននៅភ្នំពេញនៅជាមួយយាយ។

ឪពុកម្តាយខ្ញុំ និងបងប្អូន៧នាក់ចេញដំណើរតាមម៉ារីនចម្ងាយ៧-៨គីឡូម៉ែត្រទៅហើយ គាត់ត្រឡប់មកវិញដោយសារបែកកូនទីមួយនិងទីពីរ។ ឪពុកម្តាយខ្ញុំស្មានថា ស្រុកសន្តិភាពឡើងវិញទៅហើយទើបគាត់មិនដាច់ចិត្តទៅចោល។ ឪពុកម្តាយខ្ញុំមករស់នៅព្រៃនប់ ម្តាយខ្ញុំមានធ្វើការដូចប្រជាជនដទៃដែល គាត់ពុំធ្លាប់ធ្វើពីមុនមកទេ។ ម្តាយខ្ញុំ គឺអ្នកស្រុកស្អាង និងនៅក្នុងក្រុមល្ខោនហ្លួង រាំរបាំព្រះរាជទ្រព្យក្នុងវាំងជាមួយលោកយាយខ្ញុំ។ ចំណែកប៉ា គឺជាក្រឡាបញ្ជីនៅតុលាការ។

នៅឆ្នាំ១៩៧៦ ពេលយប់មួយខ្មែរក្រហមបានហៅឪពុកខ្ញុំថា

-អើ! លោកក្រឡាបញ្ជីតុលាការមកទៅភូមិថ្មី

ពេលនោះឪពុកម្តាយខ្ញុំដឹងភ្លាមហើយនឹកឆ្ងល់ថា តើហេតុអ្វីក៏ខ្មែរក្រហមស្គាល់មុខងាររបស់ខ្ញុំ គឺប្រាកដជាខ្មែរក្រហមស្រាវជ្រាវដឹងពីអ្នក១៧ ដូចគ្នាដែរដែលស្គាល់គ្រួសារខ្ញុំពីដើមមក។ ឪពុកខ្ញុំចេញផុតពីផ្ទះក៏ត្រូវកងឈ្លបហើយបណ្តើរយកទៅដាក់លើរទេះសេះ។ ប្អូនប្រុសខ្ញុំ វ៉ារុធ និងម៉ារ៉ា បានរត់ដេញតាមរទេះសេះរហូតដល់មុខមន្ទីរឃុំឃើញឈ្លបចងក្រណាត់ខ្មៅបិទមុខឪពុកនិងចងស្លាបសេកដៃទៅក្រោយ។ ប្អូនខ្ញុំមើលរួច បាននាំគ្នាយំពីរនាក់បងប្អូនលុះត្រាតែឡានចេញផុត។ ឪពុកខ្ញុំពុំដឹងថាកូនរត់តាមក្រោយទេព្រោះយប់ងងឹតម៉ោងប្រហែល៧ទៅហើយ។ ប្អូនខ្ញុំដើរមកវិញក៏ជួបឈ្លបខ្មែរក្រហមតាមផ្លូវ ឈ្លបបានសួរប្អូនខ្ញុំថា៖

-យីយប់ហើយកុមារឯងទាំងពីរទើបមកពីណា?

ប្អូនខ្ញុំពោលតបភ្លាមកុំឲ្យឈ្លបចាប់អារម្មណ៍

-បាទ

គោខ្ញុំដាច់បាត់ខ្ញុំតាមរកវាពូ!

-អើ យប់ហើយទៅផ្ទះទៅកុំដើរផ្តេសផ្តាសតិចក្រែងគេប្រឡាំថាខ្មាំង។

-បាទៗ ពូខ្ញុំទៅវិញហើយ!

មកដល់ផ្ទះមានតែការសោកសង្រេងយំស្តាយស្រណោះឪពុក ប៉ុណ្ណោះ។ មួយខែកន្លះក្រោយមកទៀត ប្អូនខ្ញុំទីបីបន្ទាប់ខ្ញុំបានមកលេងម្តាយខ្ញុំបានដឹងរឿងនេះ។ ប្អូនខ្ញុំស្លុតស្មារតី យ៉ាងខ្លាំងហើយក៏ប្រញាប់ត្រឡប់ទៅវិញ។ កន្លះខែក្រោយមកទៀត ប្អូនខ្ញុំមកលេងម្តាយខ្ញុំទៀត ពេលនោះវាស្លុតរន្ធត់ចិត្តយ៉ាងខ្លាំង ព្រោះឃើញផ្ទះទ្វារចំហគ្មានសល់អ្វីក្នុងផ្ទះឡើយ។ មាន់ចិញ្ចឹមពេញទ្រុង ព្រោះម្តាយខ្ញុំចូលចិត្តចិញ្ចឹមមាន់ និងខស្សរាហ៍ក្នុងការដាំដំណាំណាស់ បាត់អស់! ទ្រើងត្រឡាចននោងបាក់ទ្រម ផ្ទះអត់មនុស្ស។ លុះប្អូនខ្ញុំឈរយូរទៅទើបមានប្រជាជនថ្មីដូចគ្នាមកខ្សឹបប្រាប់ថា ម្តាយខ្ញុំទៅបាត់កន្លះខែមុននេះ។ ឈ្លបបានចងគាត់ដាក់ឡានរួចដឹកទៅចាក់ទម្លាក់ឯជ្រោះពេជនិលជាមួយប្អូន៨នាក់និងអ្នកថ្មីផ្សេងទៀត។ ប្អូនខ្ញុំឈ្មោះ អាដា រន្ធត់ចិត្តឈរជើងពុំនឹង។ ប្អូនខ្ញុំយំបោកខ្លួនក្នុងផ្ទះដែលខ្យល់បក់ទេត្រស្មើររលាំ។

ខ្ញុំ បងស្រី ប្អូន៣នាក់ទៀតដែលរស់នៅសព្វថ្ងៃគឺដោយសារបែកពីគ្នា ប្រសិនបើនៅជុំគ្នាទាំងអស់ប្រហែលជាខ្មែរក្រហមយកទៅសម្លាប់ទាំងពូជតែម្តង។ ទាំងនេះគឺជាអំពើយ៉ាងព្រៃផ្សៃបំផុតដែលខ្មែរក្រហមសម្លាប់គ្រួសារខ្ញុំ ហើយខ្ញុំសូមអំពាវនាវដល់ប្រជាជនខ្មែរទាំងអស់ សូមកុំភ្លេចឲ្យសោះអតីតកាលដ៏ល្វីងជូរចត់ដែលពុំធ្លាប់មានក្នុងប្រវត្តិសាស្ត្រ។

**ថាតិ ប៉ុណ្ណារី**

*រូបក្របមុខ៖*
*ព្រះឆាយាលក្ខណ៍សម្តេចព្រះមហាក្សត្រ*
*នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*រូបក្របក្រោយ ៖*
*កងសិល្បៈនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 253, January 2021 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.